ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

អាជ្ញាធរសវនកម្មជាតិ

របាយការណ៍សវនកម្ម
លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
ការិយបរិច្ឆេទ២០១៥

លេខ: ១០

ឆ្នាំ២០១៧

អារម្ភកថា

ការគ្រប់គ្រងហិរញ្ញវត្ថុឆ្នាំ២០១៥ នៅព្រះរាជាណាចក្រកម្ពុជា ទទួលបានជោគជ័យប្រកបដោយលទ្ធផលជាផ្លែផ្កាគួរឱ្យកត់សម្គាល់ ដែលសម្រេចបានអត្រាកំណើនសេដ្ឋកិច្ចដ៏រឹងមាំក្នុងរយៈពេលទស្សវត្សរ៍ចុងក្រោយនេះ ដោយអត្រាកំណើនជាមធ្យមមានលើសពី៧% ថែមទាំងទទួលបាននូវការទទួលស្គាល់ និងប្រសិទ្ធនាមថាជាប្រទេសមានកំណើនដ៏រឹងមាំ បើទោះបីសេដ្ឋកិច្ចកម្ពុជាជួបប្រទះនូវបញ្ហាប្រឈមខាងក្នុង និងហានិភ័យខាងក្រៅជាច្រើនសម្រាប់ឆ្នាំខាងមុខ ដូចជាការកើនឡើងនៃប្រាក់ឈ្នួលអប្បបរមា បញ្ហាគ្រោះធម្មជាតិ ការធ្លាក់ចុះតម្លៃកសិផល ភាពមិនប្រាកដប្រជានៃស្ថានភាពសេដ្ឋកិច្ច ហិរញ្ញវត្ថុ និងភូមិសាស្ត្រនយោបាយរបស់ពិភពលោកនិងក្នុងតំបន់ ការឡើងថ្លៃប្រាក់ដុល្លារ ការថមថយកំណើនសេដ្ឋកិច្ចចិន និងកំណើនថមថយនៃសេដ្ឋកិច្ចអឺរ៉ុប។ ជាមួយគ្នានេះដែរ ការវិវត្តនៃសេដ្ឋកិច្ចកម្ពុជាមានភាពកាន់តែស្មុគស្មាញជាងមុន ដោយសារភាពបើកចំហនៃសេដ្ឋកិច្ច ហើយដែលបានធ្វើឱ្យកម្ពុជាងាយនឹងរងផលប៉ះពាល់ពីកត្តាខាងក្រៅ ស្របគ្នានឹងកាលានុវត្តភាពសម្រាប់ការអភិវឌ្ឍតាមរយៈពាណិជ្ជកម្ម វិនិយោគ ទេសចរណ៍ និងហិរញ្ញវត្ថុ។ លើសពីនេះ កំណើនយ៉ាងខ្ពស់ និងឆាប់រហ័សនៃឥណទានក៏ជាបញ្ហាគួរឱ្យព្រួយបារម្ភផងដែរសម្រាប់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងវិស័យហិរញ្ញវត្ថុ ដែលទាមទារឱ្យមានការយកចិត្តទុកដាក់ខ្ពស់។ ជាក់ស្តែងធនាគារពិភពលោកបានផ្តល់ចំណាត់ថ្នាក់កម្ពុជាជាប្រទេសមួយក្នុងចំណោមបណ្តាប្រទេសដែលមានកំណើនរឹងមាំ (Olympians of Growth) និងធនាគារអភិវឌ្ឍអាស៊ី បានចាត់ទុកប្រទេសកម្ពុជាជាខ្លាសេដ្ឋកិច្ចថ្មីនៅអាស៊ី (Asia's New Tiger Economy)។ កំណើនដ៏រឹងមាំនេះ បានបង្កើតបន្ថែមនូវការងារ និងបង្កើនចំណូលជូនដល់ប្រជាជនកម្ពុជាព្រមទាំងលើកកម្ពស់សមធម៌នៅក្នុងសង្គមជាតិ។ ជាក់ស្តែង ផសសសម្រាប់មនុស្សម្នាក់ៗកើនឡើងដល់**១ ២១៥** ដុល្លារអាមេរិកក្នុងឆ្នាំ២០១៥ ធៀបទៅនឹងឆ្នាំ២០១៤ ដែលមានត្រឹមតែ **១ ១៣៨** ដុល្លារអាមេរិក ដែលធ្វើឱ្យប្រទេសកម្ពុជាក្លាយជាប្រទេសចំណូលមធ្យមកម្រិតទាប។

ទន្ទឹមនេះ អតិផរណាជាមធ្យមប្រចាំឆ្នាំបានធ្លាក់ចុះមកនៅត្រឹម១,២% ដែលតាមការគ្រោងទុកគឺក្នុងរង្វង់៣,៥% និងអត្រាប្តូរប្រាក់ជាមធ្យមរក្សាបាន៤ ០៦២ រៀល ក្នុងមួយដុល្លារអាមេរិកនៅក្នុងឆ្នាំ២០១៥ ដែលតាមការគ្រោងទុកគឺក្នុងរង្វង់ ៤ ០៥០ រៀល។ កំណើនសេដ្ឋកិច្ចខ្ពស់នេះបានមកពីការរួមចំណែកពីវិស័យបីនៃសេដ្ឋកិច្ច គឺឧស្សាហកម្ម សេវាកម្ម និងកសិកម្ម។ រាជរដ្ឋាភិបាលកម្ពុជាបន្តអនុវត្តនូវកម្មវិធីនយោបាយរបស់ខ្លួនប្រកបដោយជោគជ័យ ដែលឆ្លុះបញ្ចាំងតាមរយៈការសម្រេចបាននូវគោលដៅធំៗ ក្នុងការបន្តលើកកម្ពស់កំណើន ការងារ សមធម៌ និងកាត់បន្ថយបានជាបន្តបន្ទាប់នូវភាពក្រីក្ររបស់ប្រជាជន បន្តពង្រឹងសន្តិភាព ស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ធានាបន្តសម្រេចឱ្យបាននូវកំណើនសេដ្ឋកិច្ចខ្ពស់ប្រកបដោយបរិយាប័ន្ន និងចីរភាព ព្រមទាំងធានាបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងបរិការណ៍នៃអត្រាអតិផរណាទាប និងអត្រាប្តូរប្រាក់មានស្ថិរភាព បន្តអនុវត្តកម្មវិធីកែទម្រង់ចាំបាច់នានារបស់រដ្ឋាភិបាលឱ្យមានលក្ខណៈស៊ីជម្រៅ និងទទួលបានលទ្ធ

ផលជាផ្លែផ្កាបណ្តើរៗ រួមមានការកែទម្រង់ប្រព័ន្ធសៀវត្ស ការកែទម្រង់រដ្ឋបាលសាធារណៈ ការកែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ការកែទម្រង់កងកម្លាំងប្រដាប់អាវុធ ការកែទម្រង់ហិរញ្ញវត្ថុសាធារណៈ ការកែទម្រង់ប្រព័ន្ធយុត្តិធម៌ និងតុលាការ ការកែទម្រង់ដីធ្លី និងការប្រយុទ្ធប្រឆាំងនឹងអំពើពុករលួយ ដើម្បីលើកកម្ពស់គុណភាព ពង្រីកការទទួលបាន បង្កើនភាពពេញចិត្ត និងកែលម្អប្រសិទ្ធភាពនៃសេវាសាធារណៈគ្រប់ប្រភេទ បន្តជំរុញការអភិវឌ្ឍធនធានមនុស្សតាមរយៈការលើកកម្ពស់គុណភាពវិស័យអប់រំ ការបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ព្រមទាំងការលើកកម្ពស់សេវាសុខាភិបាល បន្តជំរុញការវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន និងហេដ្ឋារចនាសម្ព័ន្ធចាំបាច់ដទៃផ្សេងទៀត ដើម្បីគាំទ្រដល់កំណើនសេដ្ឋកិច្ច និងការអភិវឌ្ឍ បន្តអនុវត្តគោលនយោបាយស្តីពីការជំរុញផលិតផលស្រូវ និងការនាំចេញអង្ករ និងចាប់ផ្តើមអនុវត្តគោលនយោបាយថ្មីៗរបស់រាជរដ្ឋាភិបាល ជាពិសេសគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្ម ពង្រឹងនិងពង្រីកលំហថវិកា ព្រមទាំងពង្រឹងយន្តការគ្រប់គ្រងវិបត្តិពិសេសតាមរយៈការបង្កើនប្រាក់បញ្ញើរាជរដ្ឋាភិបាល ដើម្បីត្រៀមទប់ទល់នឹងវិបត្តិ និងហានិភ័យផ្សេងៗដែលអាចកើតមានឡើងជាយថាហេតុ។ ដែលជាសក្តីភាពនាំមកនូវចំណូលចរន្តថវិកាថ្នាក់ជាតិឆ្នាំ ២០១៥ កើនឡើង **១៥,១%** បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៤ ចំណូលសារពើពន្ធកើនឡើង **១៦,១%** បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៤ ចំណូលថវិការបស់រាជធានី ខេត្តឆ្នាំ២០១៥ កើនឡើង **១០,៣៥ %** បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៤ និងចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក ឆ្នាំ ២០១៥ កើនឡើង **១៣,០៣ %** បើប្រៀបធៀបទៅនឹងការអនុវត្តឆ្នាំ២០១៤ សំដៅបន្តកាត់បន្ថយភាពក្រីក្ររបស់ប្រជាជនជាលំដាប់។ រីឯចំណាយថវិកាថ្នាក់ជាតិសរុបអនុវត្តបានកើនឡើង ៤,២% ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៤ ចំណាយថវិការាជធានី ខេត្ត អនុវត្តបានកើនឡើង ២៤,៩៣% ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៤ និងចំណាយថវិការដ្ឋបាលក្រុង ស្រុក អនុវត្តបានកើនឡើង ១៤,៧៥ % ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៤។ ការអនុវត្តចំណូល និងចំណាយនេះបានធ្វើឱ្យមានការសន្សំអតិរេកថវិកាថ្នាក់ជាតិចំនួន **១ ៥៦៩ ០៥៦,៧**លានរៀល។ ទាំងនេះបានមកដោយសារការដឹកនាំដ៏ត្រឹមត្រូវប្រកបដោយឆន្ទៈនយោបាយមោះមុត ឈ្លាសវៃ និងភ្លឺស្វាងរបស់រាជរដ្ឋាភិបាលកម្ពុជា និងដោយសារតែរាជរដ្ឋាភិបាលមានច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ព្រមទាំងអនុវត្តយ៉ាងខ្ជាប់ខ្ជួនតាមអាទិភាពគោលនយោបាយសំខាន់ៗ ។

ថវិកាឆ្នាំ២០១៥ បានបង្ហាញពីឆន្ទៈដ៏មុះមុតរបស់រាជរដ្ឋាភិបាលក្នុងការខិតខំបង្កើនប្រសិទ្ធភាព និងកម្រិតនៃការកៀរគរចំណូល តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់ ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ ជាពិសេសការលើកកម្ពស់វប្បធម៌បង់ពន្ធ ការបង្ក្រាបអំពើរត់ពន្ធ និងការគេចវេះពន្ធគ្រប់រូបភាពឱ្យដល់ឬសគល់ និងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ព្រមទាំងការខិតខំប្រកបដោយភាពម៉ឺងម៉ាត់ និងហ្មត់ចត់ ក្នុងការគ្រប់គ្រងចំណាយ ដែលបានជួយឱ្យរាជរដ្ឋាភិបាលអាចមានលទ្ធភាពឆ្លើយតបបានកាន់តែមានប្រសិទ្ធភាពទៅនឹងបណ្តាតម្រូវការជាអាទិភាពនានា ដែលបានកំណត់ក្នុងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ២០១៥។

លទ្ធផលនៃការអនុវត្តថវិកាឆ្នាំ២០១៥ បានបង្ហាញពីការប្តេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការឈានទៅសម្រេចឱ្យបាននូវគោលដៅ និងវិធានការនានា ជាពិសេសការបន្តការអនុវត្តឱ្យមានប្រសិទ្ធភាពនូវការកែទម្រង់ស៊ីជម្រៅលើគ្រប់វិស័យឱ្យកាន់តែមុតស្រួចជាងមុន និងផ្តល់លទ្ធផលជាក់ស្តែង ដោយប្រកាន់ខ្ជាប់នូវអភិក្រមការងារបួនយ៉ាងគឺ "**ឆ្លុះកញ្ចក់ ទួតទឹក ជុសភ្នែល និងព្យាបាល**"។ ចលនានៃការកែទម្រង់លើគ្រប់វិស័យ និងកាន់តែស៊ីជម្រៅនេះ បាននាំឱ្យកម្ពុជាសម្រេចបាននូវការផ្លាស់ប្តូរពីចំណាត់ថ្នាក់នៃប្រទេសមានចំណូលទាបក្លាយទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប។

ក្នុងបរិការណ៍នេះ គឺជាការត្រឹមត្រូវណាស់ដែលរាជរដ្ឋាភិបាលបានប្រសិទ្ធនាមថវិកាឆ្នាំ២០១៥ ថា "ជាថវិកានៃការបោះជំហានទៅមុខយ៉ាងស្វាហាប់ ក្នុងដំណើរការផ្លាស់ប្តូររបស់កម្ពុជា ឆ្ពោះទៅរកការអភិវឌ្ឍប្រកបដោយគុណភាព និងចីរភាព"។ ថវិកានេះបានគិតគូរអំពីតុល្យភាពនៃកំណើនសេដ្ឋកិច្ច និងការបែងចែកផលនៃកំណើនដោយផ្សារភ្ជាប់ទៅនឹងជីវភាពរស់នៅប្រចាំថ្ងៃ និងបំណងប្រាថ្នារបស់ប្រជាជន ព្រមទាំងគិតគូរដល់ការអភិវឌ្ឍរយៈពេលវែង ក្នុងបរិការណ៍សមាហរណកម្មស៊ីជម្រៅក្នុងតំបន់ និងការវិវឌ្ឍនៃសកលភាវូបនីយកម្ម ក៏ដូចជាការពង្រឹងសមត្ថភាពគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ចសង្គមឱ្យស្របទៅនឹងដំណាក់កាលថ្មីរបស់កម្ពុជា។

អាជ្ញាធរសវនកម្មជាតិ ជាស្ថាប័នសវនកម្មកំពូលមួយ ដែលត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជាក្នុងខែមីនា ឆ្នាំ២០០០ ក្រោមឆន្ទៈ និងការប្តេជ្ញាដ៏មោះមុតរបស់រាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ក្នុងគោលបំណងបំពេញមុខងារត្រួតពិនិត្យ វាយតម្លៃ និងផ្តល់អនុសាសន៍កែលម្អរាល់ចំណុចខ្វះខាតរបស់ក្រសួងស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន អង្គភាពពាក់ព័ន្ធនានា និងធ្វើរបាយការណ៍ស្តីពីលទ្ធផលសវនកម្មផ្ញើជូនរដ្ឋសភា ព្រឹទ្ធសភា និងរាជរដ្ឋាភិបាល សំដៅរួមចំណែកពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កិច្ចប្រតិបត្តិការការងារឱ្យកាន់តែល្អប្រសើរ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

អាជ្ញាធរសវនកម្មជាតិ ផ្សព្វផ្សាយរបាយការណ៍សវនកម្មនេះជាសាធារណៈដោយអនុលោមតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ របាយការណ៍នេះលើកឡើងនូវលទ្ធផលនៃការធ្វើសវនកម្មលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងារសម្រាប់ការិយបរិច្ឆេទ២០១៥ របស់ក្រសួងស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ និងអង្គភាពពាក់ព័ន្ធនានាមួយចំនួន។

ដោយការខិតខំប្រឹងប្រែង និងការទទួលខុសត្រូវខ្ពស់ ការតស៊ូ អត់ធ្មត់ ពុះពារឆ្លងកាត់ការលំបាករបស់ថ្នាក់ដឹកនាំ និងមន្ត្រីសវនកម្មនៃអាជ្ញាធរសវនកម្មជាតិ ព្រមទាំងមានការជួយឧបត្ថម្ភគាំទ្រពីគ្រប់មជ្ឈដ្ឋានទាំងផ្នែកស្មារតី និងសម្ភារ បាននាំឱ្យអាជ្ញាធរសវនកម្មជាតិមានសក្តានុពលក្នុងការអនុវត្តការងារ និងសម្រេចបានជាបន្តបន្ទាប់នូវផែនការយុទ្ធសាស្ត្រ២០១២-២០១៦របស់ខ្លួន។ ចំពោះមុខអាជ្ញាធរសវនកម្មជាតិនឹងបន្តខិតខំបន្ថែមទៀត ដោយធ្វើការពង្រីកវិសាលភាពសវនកម្ម ពង្រឹងសមត្ថភាពមន្ត្រី និងបង្កើនគុណភាពសវនកម្ម ដើម្បីឈានទៅសម្រេចភារកិច្ចតាមច្បាប់សវនកម្មនៃព្រះរាជាណាចក្រកម្ពុជា

និងស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងឆ្លើយតបទៅនឹងតម្រូវការស្ថានភាពសេដ្ឋកិច្ច និងគោលនយោបាយរបស់ប្រទេសជាតិផងដែរ។

ក្នុងនាមអាជ្ញាធរសវនកម្មជាតិ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅចំពោះរាជរដ្ឋាភិបាល រដ្ឋសភា ព្រឹទ្ធសភា ដែលជានិច្চកាលតែងតែគាំទ្រអាជ្ញាធរសវនកម្មជាតិ ទាំងស្មារតី និងសម្ភារ។ ម្យ៉ាងវិញទៀត ខ្ញុំក៏សូមអរគុណ និងកោតសរសើរចំពោះថ្នាក់ដឹកនាំ និងមន្ត្រីនៃអាជ្ញាធរសវនកម្មជាតិទាំងអស់ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្চប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ធ្វើឱ្យសម្រេចបាននូវជោគជ័យគួរឱ្យកត់សម្គាល់។ ឆ្លៀតក្នុងឱកាសនេះដែរ ខ្ញុំសូមថ្លែងអំណរគុណដល់អង្គភាពរងសវនកម្មនានា និងសាធារណជនទាំងឡាយដែលបានសហការ គាំទ្រ និងលើកទឹកចិត្តចំពោះរាល់ការងារបម្រើឱ្យវិស័យសវនកម្មសាធារណៈនាពេលកន្លងមក។ ជាមួយគ្នានេះដែរ ខ្ញុំសូមអរគុណផងដែរដល់អង្គការកិច្চសហប្រតិបត្តិការអន្តរជាតិរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់(GIZ) ស្ថាប័នសវនកម្មកំពូលប្រទេសស៊ុយអែត ព្រមទាំងដៃគូអភិវឌ្ឍន៍ និងស្ថាប័នសវនកម្មកំពូលនានាដែលបានផ្តល់ការគាំទ្រ និងឧបត្ថម្ភផ្សេងៗក្នុងកិច្চដំណើរការអភិវឌ្ឍស្ថាប័ន។

អាជ្ញាធរសវនកម្មជាតិមានសង្ឃឹមយ៉ាងមុតមាំថា អាជ្ញាធរសវនកម្មជាតិនឹងសម្រេចនូវលទ្ធផលថ្មីៗថែមទៀតដែលបង្ហាញពីការចូលរួមចំណែកក្នុងការលើកស្ទួយ និងការអភិវឌ្ឍប្រទេសជាតិជាទីគោរព និងស្រឡាញ់នៃយើងទាំងអស់គ្នា។

រាជធានីភ្នំពេញ, ថ្ងៃទី ២៧ ខែ មេសា ឆ្នាំ២០១៧

អគ្គសចិវករ

សោម គីមសួត

មាតិកា

សេចក្តីសង្ខេប ១

១. សេចក្តីផ្តើម ៤

១.១.លក្ខណៈទូទៅ ៤

១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម ៤

១.៣. គោលបំណងនៃការផ្សព្វផ្សាយ ៥

២. ការគ្រប់គ្រងថវិកា ៥

២.១.មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា ៥

២.២.កិច្ចប្រតិបត្តិការថវិកា ៦

៣. លទ្ធផលសវនកម្ម ៧

៣.១.ការគ្រប់គ្រងថវិកាថ្នាក់ជាតិ ៧

៣.១.១. ការលើកលែងប្រាក់ពិន័យដល់ក្រុមហ៊ុន សហគ្រាសយឺតយ៉ាវចុះបញ្ជីពន្ធ ៧

៣.១.២. ប្រាក់កក់នៅសល់រយៈពេលយូរពុំទាន់បានជម្រះបញ្ជី ៨

៣.១.៣. តម្លៃមូលដ្ឋានសម្រាប់បង់ពន្ធនាំចូលលើរថយន្តទំនើប ៩

៣.១.៤. ជើងសារគយហួសសុពលភាពយកមកបំពេញបែបបទគយ ៩

៣.១.៥. ភាពយឺតយ៉ាវក្នុងការបង់ចំណូលពីការជួលទីតាំង ១០

៣.១.៦. ការដកប្រាក់រង្វាន់២០%យកទៅចំណាយដើម្បីពង្រឹងយន្តការប្រមូលចំណូល.. ១០

៣.១.៧. ការប្រមូលមូលនិធិទាយជ្ជទានបរិស្ថានមិនអស់លទ្ធភាព ១២

៣.១.៨. ការប្រមូលចំណូលពីប្រាក់តម្កល់ធានាអប្បបរមាមិនបានពេញលេញ ១៣

៣.១.៩. ការកត់ត្រាចំណាយថវិកាខុសមាតិកាថវិកា ១៥

៣.១.១០.ការយកថវិកាឆ្នាំ២០១៥ទៅធ្វើការទូទាត់ចំណាយឆ្នាំ២០១៤ ..... ១៦

៣.១.១១.ការចំណាយថវិកាកម្មវិធីពុំស្របទៅនឹងកម្មវិធីសកម្មភាពប្រចាំឆ្នាំ ១៧

៣.១.១២.ការបំបែកប័ណ្ណចំណាយដើម្បីគេចវេសពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ១៨

៣.១.១៣.ការអនុវត្តចំណាយខុសទៅនឹងអនុកម្មវិធី និងចង្កោមសកម្មភាពប្រចាំឆ្នាំ ១៩

៣.១.១៤.ការអនុវត្តចំណាយមុនការសម្រេច និងឯកភាពពីប្រធានអង្គភាពថវិកា ២០

៣.១.១៥.ការយកចំណាយថវិកាបុរេប្រទានឆ្នាំ២០១៥ទៅធ្វើការ
ទូទាត់ក្នុងឆ្នាំ២០១៦ ..... ២១

៣.១.១៦.ការទូទាត់ចំណាយថវិកាកម្មវិធីពុំទាន់បានត្រឹមត្រូវ ២២

៣.១.១៧.ការចំណាយក្រោយកិច្ចប្រតិបត្តិការជាក់ស្តែង ២៣

៣.១.១៨.តម្លៃទំនិញក្នុងកិច្ចសន្យាមិនស្របតាមតម្លៃទីផ្សារ.....២៤
៣.១.១៩.ការបង្វែរពីវិធីសាស្ត្រដេញថ្លៃសាធារណៈមកអនុវត្តវិធីសាស្ត្រចរចាថ្លៃនិង
អង្គភាព ទទួលការពុំទាន់មានការវាយតម្លៃពីចំណាត់ថ្នាក់និងលក្ខណៈ
សម្បត្តិពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ២៥
៣.១.២០.ការបើកឯកសារដេញថ្លៃពុំទាន់បានត្រឹមត្រូវ ២៧
៣.១.២១.ការទូទាត់ចំណាយប្រាក់បំណាច់ម៉ោងបន្ថែមពុំទាន់បានត្រឹមត្រូវ ២៨
៣.១.២២.កង្វះខាតក្នុងការកំណត់ការរៀបចំរចនាសម្ព័ន្ធនិងតួនាទីភារកិច្ចរបស់
អង្គភាព ៣០
៣.១.២៣.ការពុំមានតារាងតម្លៃទិន្នន័យតម្លៃទីផ្សារសម្រាប់វាយតម្លៃជ្រើសរើស
អ្នកដេញថ្លៃ ៣០
៣.១.២៤.ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវា ដែលមាន
សកម្មភាព អាជីវកម្ម (ប៉ាតង់)មិនស្របតាមកម្មវត្ថុនៃកិច្ចសន្យា ៣០
៣.១.២៥.នាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុវត្តការងារមិនទាន់អស់លទ្ធភាព ៣០
៣.១.២៦.ការបំបែកគម្រោងលទ្ធកម្មសាធារណៈ: ៣១
៣.១.២៧.ការធ្វើសៀវភៅការងារ ៣២
៣.១.២៨.កង្វះខាតការត្រួតពិនិត្យចំណីអាហារ..... ៣៣
៣.១.២៩.ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ.....៣៣
៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ ៣៤
៣.២.១. ការប្រមូលពន្ធប្រថាប់ត្រា ៣៤
៣.២.២. ការបង្កើតបញ្ជីដីមិនបានប្រើប្រាស់ ៣៦
៣.២.៣. ការបង់ចំណូលឆ្លងឆ្នាំ ៣៦
៣.២.៤. ការចំណាយមិនសមស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ៣៧
៣.២.៥. ភាពយឺតយ៉ាវក្នុងការធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ ៣៨
៣.២.៦. កង្វះខាតក្នុងការរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះ ... ៣៨
៤. ការពិនិត្យទៅលើវឌ្ឍនភាពនៃការអនុវត្តន៍អនុសាសន៍សវនកម្ម.....៣៩
៤.១. ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធ ៣៩
៤.២. ការបំពេញកាតព្វកិច្ចសារពើពន្ធ.....៤០
៤.៣. របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ៤០
៤.៤. ការប្រើប្រាស់វិក្កយបត្រ ៤១
៤.៥. ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ ៤១

៤.៦. ការបំពេញកាតព្វកិច្ចចុះបញ្ជីសារពើពន្ធសហគ្រាស.....៤២
៤.៧. ការប្រមូលពន្ធអចលនទ្រព្យ.....៤២
៤.៨. ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ.....៤៣
៤.៩. ក្រុមហ៊ុនចូលរួមដេញថ្លៃសាងសង់ភ្ជាប់ប្រភេទវិញ្ញាបនបត្រចុះបញ្ជីសាងសង់
មិនសមស្រប.....៤៣
៤.១០.ការផ្ទេរបាយការណ៍លទ្ធកម្មមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ.....៤៣
៤.១១.ការកត់ត្រាចំណូលថវិការដ្ឋ.....៤៤
៤.១២.ការទូទាត់ និងការកត់ត្រាចំណាយ.....៤៤
៤.១៣.ការធ្វើបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ.....៤៤
៤.១៤.ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ.....៤៥
៥. សេចក្តីសន្និដ្ឋាន.....៤៥

របាយការណ៍សវនកម្ម
លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈសម្រាប់ការិយបរិច្ឆេទ២០១៥

សេចក្តីសង្ខេប

អាជ្ញាធរសវនកម្មជាតិជាស្ថាប័នសាធារណៈដែលឯករាជ្យអំពីកិច្ចប្រតិបត្តិការនៃការងារ និងមានភារកិច្ចចំពោះការអនុវត្តមុខងារសវនកម្មផ្នែកក្រៅរបស់រាជរដ្ឋាភិបាល។ ស្ថាប័ននេះត្រូវបានបង្កើតឡើងដោយច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០។ អនុលោមតាមមាត្រា២ មាត្រា៣ មាត្រា២៩ និងមាត្រា៣៧នៃច្បាប់នេះ អាជ្ញាធរសវនកម្មជាតិមានកាតព្វកិច្ចធ្វើសវនកម្ម និងផ្សព្វផ្សាយលទ្ធផលសវនកម្មដែលចាំបាច់។

សម្រាប់ការិយបរិច្ឆេទ២០១៥ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មលើបណ្តាក្រសួងស្ថាប័នរដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោងផ្សេងៗ និងសម្បទានវិនិយោគមួយចំនួនដែលមានលទ្ធផលសង្ខេបខាងក្រោម៖

ក. កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ចំណូលថវិកាថ្នាក់ជាតិអនុវត្តបានចំនួន **១៦ ២២៩ ២០៣,៨**លានរៀល ស្មើនឹង**២២,១០%** នៃ ផ.ស.ស គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុ **៧,២%** ហើយបានកើនឡើង **៦,៥%** ធៀបទៅនឹងការអនុវត្តឆ្នាំ ២០១៤។ ទាំងនេះឆ្លុះបញ្ចាំងអំពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការបន្តអនុវត្តគោលនយោបាយ និងច្បាប់ដែលមានស្រាប់ ជាពិសេសវិធានការដែលបានដាក់ចេញក្នុងយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ ក្នុងការពង្រឹងរដ្ឋបាលប្រមូលចំណូល និងគោលនយោបាយ។ ក្នុងនោះចំណូលគយ និងរដ្ឋាករសម្រេចបានលទ្ធផលល្អ តាមរយៈការបន្តពង្រឹងរដ្ឋបាល និងអភិបាលកិច្ចជាពិសេសការបន្តលើកកម្ពស់អនុលោមភាព និងបន្តបង្ក្រាបអំពើរត់ពន្ធ។ ជាមួយគ្នានេះ ចំណូលពន្ធដារក៏ទទួលបានលទ្ធផលល្អប្រសើរ តាមរយៈការបន្តពង្រឹងរដ្ឋបាលចំណូលពន្ធដារ, ការបន្តពង្រឹង និងកែលម្អស្ថាប័ន ក្នុងគោលបំណងបង្កើនចំណូលពន្ធតាមរយៈការលើកកម្ពស់វប្បធម៌បង់ពន្ធ និងធ្វើឱ្យមានភាពសាមញ្ញ និងមានសមធម៌។ រីឯចំណូលមិនមែនសារពើពន្ធក៏សម្រេចបានលទ្ធផលល្អប្រសើរផងដែរតាមរយៈការពង្រឹងរដ្ឋបាលប្រមូលចំណូលនៅតាមក្រសួង-ស្ថាប័នពាក់ព័ន្ធដែលប្រមូលចំណូលមិនមែនសារពើពន្ធ និងការធ្វើឱ្យប្រសើរឡើងនូវកិច្ចសហការរវាងស្ថាប័នទាំងនោះ ប៉ុន្តែនៅមានបញ្ហាប្រឈមមួយចំនួន ដោយសារការគ្រប់គ្រងចំណូលនេះពាក់ព័ន្ធនឹងសមត្ថកិច្ចខុសៗគ្នា និងវិស័យជាច្រើន។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មបានបង្ហាញឱ្យឃើញថា នៅមានការកត់សម្គាល់មួយចំនួនដែលចាំបាច់ត្រូវធ្វើឱ្យប្រសើរឡើងថែមទៀតមានជាអាទិ៍៖ ការលើកលែងប្រាក់ពិន័យដល់ក្រុមហ៊ុនសហគ្រាសយឺតយ៉ាវចុះបញ្ជីពន្ធ ប្រាក់កក់នៅសល់រយៈពេលយូរពុំទាន់បានជម្រះបញ្ជី តម្លៃមូលដ្ឋាន

សម្រាប់បង់ពន្ធនាំចូលលើរថយន្តទំនើប ជើងសារគយហួសសុពលភាពយកមកបំពេញបែបបទគយ ការដកប្រាក់រង្វាន់២០%យកទៅចំណាយដើម្បីពង្រឹងយន្តការប្រមូលចំណូល ការប្រមូលមូលនិធិទាយជួទានបរិស្ថានមិនអស់លទ្ធភាព ការប្រមូលចំណូលពីប្រាក់តម្កល់ធានាអប្បបរមាមិនបានពេញលេញ ការកាន់កាប់កិច្ចបញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធ ការបំពេញកាតព្វកិច្ចសារពើពន្ធ របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ការប្រើប្រាស់វិក្កយបត្រ ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ ការបំពេញកាតព្វកិច្ចចុះបញ្ជីសារពើពន្ធសហគ្រាស ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ និងការកត់ត្រាចំណូលថវិការដ្ឋ។ ចំណាយថវិកាថ្នាក់ជាតិអនុវត្តបានចំនួន**១៤ ៦៦០ ១៤៧,១**លានរៀល ស្មើនឹង **១៩,៩៧%** នៃផ.ស.ស គឺទាបជាងច្បាប់ហិរញ្ញវត្ថុ **២,៥%** ហើយបានកើនឡើង **៤,២%** ធៀបទៅនឹងការអនុវត្តឆ្នាំ២០១៤។

ការអនុវត្តគោលនយោបាយចំណាយថវិកាឆ្នាំ២០១៥ ទទួលបានលទ្ធផលល្អ ដោយបានបំពេញតួនាទីជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាព ដោយដោះស្រាយបាននូវអាទិភាពគោលនយោបាយរបស់រាជរដ្ឋាភិបាលតាមការគ្រោងទុក ឆ្លើយតបទៅនឹងសភាពការណ៍បន្ទាន់ចំពោះមុខ និងគាំទ្រដល់ការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាល ជាពិសេស៖

– ការត្រៀមលក្ខណៈរួចជាស្រេចក្នុងការអនុវត្តគោលនយោបាយបៀវត្សមន្ត្រីរាជការ សំដៅតម្លើងបៀវត្សមូលដ្ឋាន តម្លើងប្រាក់បំណាច់មុខងារ និងតម្លើងប្រាក់សោធននិវត្តន៍ជូននិវត្តជន ប្រាក់បំណាច់របស់មន្ត្រីជាប់កិច្ចសន្យា។ ទន្ទឹមនេះ ការបើកប្រាក់បៀវត្សត្រូវបានធ្វើឡើងនៅក្នុងសប្តាហ៍ទី៤ នៃខែនីមួយៗ និងធ្វើឡើងតាមប្រព័ន្ធធនាគារ។

– បង្កើននូវប្រសិទ្ធភាពចំណាយដោយធានាបាននូវចំណាយចំមុខសញ្ញា មានភាពចាំបាច់ ថ្លៃសមរម្យ បរិមាណត្រឹមត្រូវ គុណភាពសមរម្យ និងទាន់ពេលវេលា ពិសេសតាមរយៈវិធានការមុឹងម៉ាត់ពីដើមទី តាំងពីការវិភាជន៍ថវិកា និងការត្រួតពិនិត្យផ្តល់ការធានាចំណាយ។

– ក្នុងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈក្នុងឆ្នាំ២០១៥ រាជរដ្ឋាភិបាលសន្សំថវិកាបានចំនួន ៩៥ ៨៧១,៩លានរៀល ពីការលើកកម្ពស់ប្រសិទ្ធភាពចំណាយក្នុងគ្រប់ដំណាក់កាលនៃការអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈ ទាំងផ្នែកចំណាយចរន្ត ទាំងផ្នែកចំណាយវិនិយោគ។ វិធានការលើកកម្ពស់ប្រសិទ្ធភាពចំណាយមិនត្រឹមតែធ្វើឱ្យមានការសន្សំជាសាច់ប្រាក់ប៉ុណ្ណោះទេ ថែមទាំងបានធ្វើឱ្យក្រសួងស្ថាប័នមួយចំនួនកម្រិតការចាយក្នុងទំហំទឹកប្រាក់ដដែល តែទទួលបានទំនិញ សេវា និងសំណង់ក្នុងបរិមាណច្រើនជាងមុន និងមានគុណភាពល្អជាងមុន ព្រមទាំងកាន់តែចំទិសដៅដែលបានកំណត់ក្នុងអំឡុងពេលរៀបចំថវិកាទៀតផង។

– យន្តការផ្ទេរមុខងារ និងធនធានរបស់រដ្ឋបាលថ្នាក់ជាតិឱ្យរដ្ឋបាលថ្នាក់ក្រោមជាតិ តាមរយៈក្រសួងមួយចំនួន កំពុងដំណើរការអនុវត្ត។

– ឱនភាពទូទៅនៃថវិកា ត្រូវបានរក្សាកាត់បន្ថយឱ្យមកស្ថិតនៅក្នុងកម្រិតដែលអាចធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ក្នុងរយៈពេលមធ្យម និងរយៈពេលវែង ដែលឆ្លុះបញ្ចាំងពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ក្នុងការបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវការគ្រប់គ្រងបំណុលសាធារណៈក្រៅប្រទេសឆ្នាំ

២០១៥ តាមយុទ្ធសាស្ត្រស្តីពីការគ្រប់គ្រងបំណុលសាធារណៈរយៈពេលមធ្យមឆ្នាំ ២០១៥-២០១៨ របស់រាជរដ្ឋាភិបាល ជាពិសេសតាមគោលការណ៍គ្រឹះចំនួន០៤គឺ៖ (១) ត្រូវខ្ចីឥណទានក្នុងទំហំសមស្របដែលស្ថានភាពថវិកា និងសេដ្ឋកិច្ចអាចទ្រាំទ្របាន (២) ត្រូវខ្ចីតែឥណទានដែលមានកម្រិតសម្បទាន ឬលក្ខខណ្ឌអនុគ្រោះខ្ពស់ (៣) ត្រូវខ្ចីសម្រាប់តែវិស័យអាទិភាពទ្រទ្រង់ចីរភាពនៃកំណើន និងវិស័យបង្កើនផលិតភាពសេដ្ឋកិច្ច ឬផលិតភាពផលិតកម្ម និង (៤) ត្រូវប្រើប្រាស់ឥណទានទាំងនោះប្រកបដោយតម្លាភាព គណនេយ្យភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពខ្ពស់បំផុត។ ជាក់ស្តែង រាជរដ្ឋាភិបាលបានខ្ចីឥណទានសម្បទានពីដៃគូអភិវឌ្ឍន៍សរុបប្រមាណ៥៥៨ លានអេសដេអ៊ែរ ស្មើនឹង៩៣%នៃច្បាប់កំណត់។

ទោះបីជាការអនុវត្តចំណាយថវិកានេះបានល្អប្រសើរក៏ដោយ ក៏នៅមានចំណុចគួរឱ្យកត់សម្គាល់មួយចំនួន ដូចជា ការចំណាយថវិការដ្ឋទេយ្យបុរេប្រទានមិនស្របតាមនីតិវិធី ការយកថវិកាឆ្នាំ២០១៥ទៅធ្វើការទូទាត់ចំណាយឆ្នាំ២០១៤ ការចំណាយថវិកាកម្មវិធីពុំស្របទៅនឹងកម្មវិធីសកម្មភាពប្រចាំឆ្នាំ ការបំបែកប័ណ្ណចំណាយដើម្បីគេចវេសពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ការអនុវត្តចំណាយខុសទៅនឹងអនុកម្មវិធីនិងចង្កោមសកម្មភាពប្រចាំឆ្នាំ ការអនុវត្តចំណាយមុនការសម្រេច និងឯកភាពពីប្រធានអង្គភាពថវិកា ការយកចំណាយថវិកាបុរេប្រទានឆ្នាំ២០១៥ទៅធ្វើការទូទាត់ក្នុងឆ្នាំ ២០១៦ ការទូទាត់ចំណាយថវិកាកម្មវិធីពុំទាន់បានត្រឹមត្រូវ តម្លៃទំនិញក្នុងកិច្ចសន្យាមិនស្របតាមតម្លៃទីផ្សារ ការបង្វែរពីវិធីសាស្ត្រដេញថ្លៃសាធារណៈមកអនុវត្តវិធីសាស្ត្រចរចាថ្លៃ និងអង្គភាពទទួលការពុំទាន់មានការវាយតម្លៃពីចំណាត់ថ្នាក់ និងលក្ខណៈសម្បត្តិពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ការបើកឯកសារដេញថ្លៃពុំទាន់បានត្រឹមត្រូវ ការទូទាត់ចំណាយប្រាក់បំណាច់ម៉ោងបន្ថែមពុំទាន់បានត្រឹមត្រូវ កង្វះខាតក្នុងការកំណត់ការរៀបចំរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អង្គភាព ការពុំមានតារាងតម្លៃទិន្នន័យតម្លៃទីផ្សារសម្រាប់វាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ ការអនុវត្តកិច្ចលទ្ធកម្មលើសផែនការកំណត់ ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវាដែលមានសកម្មភាពអាជីវកម្ម (ប៉ាតង់) មិនស្របតាមកម្មវត្ថុនៃកិច្ចសន្យា ការទូទាត់និងការកត់ត្រាចំណាយ។

កិច្ចប្រតិបត្តិការថវិកាអនុវត្តក្រៅរតនាគារជាតិ ត្រូវបានគ្រោងទុកដោយមានតុល្យភាពចំណូលសរុប ស្មើនឹងចំណាយសរុប។ កិច្ចប្រតិបត្តិការនេះអនុវត្តបានចំនួន ៣ ៧២០ ៤០៥,៣ លានរៀល ស្មើនឹង**១០០,៩%** នៃច្បាប់ហិរញ្ញវត្ថុដែលមានចំនួន **៣ ៦៨៧ ០០០,០**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុចំនួន **៣៣ ៤០៥,៣** លានរៀល។

ខ. កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ចំណូលថវិការបស់រដ្ឋបាលរាជធានីខេត្តអនុវត្តបានចំនួន**៨៩៥ ៦៨០,១**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ ចំនួន**១៨,៨%** និងការអនុវត្តចំណាយថវិការបស់រដ្ឋបាលរាជធានីខេត្តអនុវត្តបាន**៨៩៥ ៦៧៥,៨**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ ចំនួន**១៨,៨%**។ ចំណូលថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបាន **១០១ ៣៩៩,៥**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ ចំនួន**២៤,៧%** និងចំណាយថវិការបស់រដ្ឋបាលក្រុង ស្រុក អនុវត្តបាន**៩៧ ៨៦៥,៨**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ ចំនួន**២០,៥%**។ រីងចំណូលថវិការបស់រដ្ឋបាលឃុំ សង្កាត់ អនុវត្ត

បាន **៣៧៥ ០៥៤,៦៣** លានរៀលគឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០១៥ ចំនួន**៣៧,៩%** និងចំណាយថវិការបស់រដ្ឋបាលឃុំ សង្កាត់អនុវត្តបាន**២៩៤ ៣០៦,៦៥**លានរៀល គឺខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៥ ចំនួន **៨,២%**។

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញមានបញ្ហាគួរឱ្យកត់សម្គាល់ ដូចជា ការប្រមូលពន្ធប្រថាប់ត្រា ការបង្កើតបញ្ជីដីមិនបានប្រើប្រាស់ ការប្រមូលពន្ធអចលនទ្រព្យ ការបង់ចំណូលឆ្លងឆ្នាំ ការចំណាយមិនសមស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា ភាពយឺតយ៉ាវក្នុងការធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ កង្វះខាតក្នុងការរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើង ថយចុះ។

ចំពោះការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ ក្រសួង ស្ថាប័ន និងសាលារាជធានីខេត្តធ្វើការផ្គូផ្គងតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើងថយចុះបានចំនួន១ ០៥៣ អង្គភាព ស្មើនឹង៨៧% នៅខ្វះ ១៥២ អង្គភាព ស្មើនឹង១៣%។

១. សេចក្តីផ្តើម

១.១. លក្ខណៈទូទៅ

ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា តម្រូវឱ្យអាជ្ញាធរសវនកម្មជាតិមានភារកិច្ចអនុវត្តមុខងារសវនកម្មផ្ទៃក្រៅរបស់រាជរដ្ឋាភិបាល ធ្វើសវនកម្មលើកិច្ចបញ្ជីកាគណនេយ្យ គណនីប្រព័ន្ធគ្រប់គ្រង ការត្រួតពិនិត្យកិច្ចប្រតិបត្តិការ និងកម្មវិធីរបស់បណ្តាក្រសួងស្ថាប័ន ភ្នាក់ងារ អាជ្ញាធរធនាគារជាតិ ស្ថាប័នហិរញ្ញវត្ថុរដ្ឋ និងស្ថាប័នហិរញ្ញវត្ថុចម្រុះឯកជន សហគ្រាសសាធារណៈ គ្រឹះស្ថានសាធារណៈ រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន អ្នកមៅការ អ្នកផ្គត់ផ្គង់ទំនិញ និងសេវាកម្មចំពោះរាជរដ្ឋាភិបាលតាមកិច្ចសន្យា និងបណ្តាអង្គការផ្សេងៗទៀតដែលរាជរដ្ឋាភិបាលបានផ្តល់ជំនួយហិរញ្ញវត្ថុបន្ថែមលើទុនផ្ទាល់ និងឥណទាន រួមមានទាំងការលើកលែងពន្ធអាករគ្រប់ប្រភេទ ព្រមទាំងសម្បទានផ្សេងៗទៀតទៅអង្គការដែលមិនរកប្រាក់ចំណេញ និងសហគ្រាសវិនិយោគឯកជន។

ក្រៅពីការងារខាងលើនេះ អាជ្ញាធរសវនកម្មជាតិមានភារកិច្ចធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំនីមួយៗ និងធ្វើរបាយការណ៍សវនកម្មជូនទៅរដ្ឋសភា ព្រឹទ្ធសភាដោយផ្ទាល់ និងផ្ញើជូនទៅរាជរដ្ឋាភិបាល ដើម្បីជ្រាបជាព័ត៌មាន ព្រមទាំងផ្សព្វផ្សាយនូវលទ្ធផលសវនកម្មដែលចាំបាច់។

១.២. ការអនុវត្ត និងដែនកំណត់សវនកម្ម

អាជ្ញាធរសវនកម្មជាតិបានអនុវត្តភារកិច្ចធ្វើសវនកម្មនៅតាមបណ្តាក្រសួងស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន សហគ្រាសសាធារណៈ គម្រោង និងសម្បទានវិនិយោគផ្សេងៗ ជាពិសេសគឺការធ្វើសវនកម្មបញ្ជាក់លើសេចក្តីព្រាងច្បាប់ស្តីពីការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំនីមួយៗស្របតាមច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា។ សម្រាប់ការិយបរិច្ឆេទ ២០១៥ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្ម និងរៀបចំរបាយការណ៍សរុបចំនួន៦២ ដែលខ្លឹមសារសំខាន់ៗមួយចំនួនក្នុងរបាយការណ៍ទាំងនោះត្រូវបានដកស្រង់មកបង្ហាញក្នុងចំណុចទី៣ នៃរបាយការណ៍សម្រាប់ផ្សព្វផ្សាយជាសាធារណៈនេះ។

អាជ្ញាធរសវនកម្មជាតិធ្វើសវនកម្មដោយអនុលោមតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ដែលតម្រូវឱ្យមានការរៀបចំផែនការ និងអនុវត្តការងារសវនកម្មដោយផ្អែកលើមូលដ្ឋាននៃការត្រួតពិនិត្យវាយតម្លៃលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអនុលោមតាមបទប្បញ្ញត្តិ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធនានា ព្រមទាំងការធ្វើតេស្តលើឯកសារផ្សេងៗ ដើម្បីទទួលបានភស្តុតាងសវនកម្មសមស្របសម្រាប់ធ្វើសេចក្តីសន្និដ្ឋាន និងផ្តល់អនុសាសន៍កែលម្អដល់អង្គភាពរងសវនកម្មទាំងនោះ។

១.៣. គោលបំណងនៃការផ្សព្វផ្សាយ

ការផ្សព្វផ្សាយរបាយការណ៍សវនកម្មជាសាធារណៈ មានគោលបំណងចូលរួមចំណែកជាមួយស្ថាប័ននីតិប្បញ្ញត្តិ និងនីតិប្រតិបត្តិ ដើម្បីពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រតិបត្តិការការងាររបស់ក្រសួងស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានា តាមរយៈការចង្អុលបង្ហាញនូវចំណុចខ្វះខាតក្នុងការអនុវត្តកន្លងមក និងផ្តល់អនុសាសន៍កែលម្អលើចំណុចខ្វះខាតទាំងនោះ សំដៅធ្វើឱ្យការគ្រប់គ្រងកាន់តែប្រសើរឡើង។

អាជ្ញាធរសវនកម្មជាតិមិនទទួលខុសត្រូវអំពីផលប៉ះពាល់ណាមួយចំពោះក្រសួងស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន ក្រុមហ៊ុន សហគ្រាស ឬបុគ្គលពាក់ព័ន្ធនានា ក្នុងករណីដែលមានតតីយជនទាំងឡាយណាយកខ្លឹមសារក្នុងរបាយការណ៍ផ្សព្វផ្សាយជាសាធារណៈនេះទៅធ្វើការបកស្រាយ ឬប្រើប្រាស់ខុសគោលដៅ។

២. ការគ្រប់គ្រងថវិកា

២.១. មូលដ្ឋានគតិយុត្តនៃការអនុវត្តថវិកា

កិច្ចដំណើរការនៃថវិកាឆ្នាំ២០១៥ ត្រូវបានប្រព្រឹត្តទៅដោយផ្អែកលើមូលដ្ឋានច្បាប់ និងលិខិតបទដ្ឋានគតិយុត្តមួយចំនួន ដែលមានជាអាទិ៍ ៖

- ច្បាប់ស្តីពីសវនកម្មនៃព្រះរាជាណាចក្រកម្ពុជា ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ជស/រកម/០៣០០/១០ ចុះថ្ងៃទី០៣ ខែមីនា ឆ្នាំ២០០០
- ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/ ០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខនស/រកម/ ១២១៤/០២៦ ចុះថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៤
- ច្បាប់ស្តីពីរបបហិរញ្ញវត្ថុ និងការគ្រប់គ្រងទ្រព្យសម្បត្តិរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៦១១/០១១ ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ ២០១១
- ច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំសង្កាត់ ប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខជស/ រកម/០៣០១/១៥ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១
- អនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៥ ស្តីពីបទបញ្ជាទូទៅនៃគណនេយ្យសាធារណៈ
- អនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

២.២. កិច្ចប្រតិបត្តិការថវិកា

កិច្ចប្រតិបត្តិការថវិកាឆ្នាំ២០១៥ ត្រូវបានរៀបចំឡើងដោយផ្អែកតាមលទ្ធផលនៃការអនុវត្តចំណូលចំណាយតាមរយៈរតនាគារជាតិ រតនាគាររាជធានីខេត្ត និងលទ្ធផលនៃការអនុវត្តគម្រោងវិនិយោគសាធារណៈដោយហិរញ្ញប្បទានក្រៅប្រទេសដែលអនុវត្តក្រៅរតនាគារជាតិ ដូចមានបង្ហាញក្នុងតារាងខាងក្រោម ៖

ក/ កិច្ចប្រតិបត្តិការថវិកាថ្នាក់ជាតិ

ឯកតា : លានរៀល

បរិយាយ	២០១៥		
	ច្បាប់ហិរញ្ញវត្ថុ	អនុវត្ត	ភាគរយ
	1	*2*	*3 = (2/1)*
I. សរុបចំណូល	**១៥ ១៣៥ ២៣០,០**	**១៦ ២២៩ ២០៣,៨**	**១០៧,២%**
-ចំណូលចរន្ត	១១ ០១៤ ៦៤៤,០	១២ ២៤៥ ៦៣៩,១	១១១.២%
-ចំណូលមូលធនក្នុងប្រទេស	១៣៣ ៥៨៦,០	១២១ ៣៨៣,១	៩០,៩%
-ចំណូលមូលនិធិទ្រទ្រង់ថវិកា	៣០០ ០០០,០	១៤១ ៧៧៦,៣	៤៧,៣%
-ចំណូលមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស	៣ ៦៨៧ ០០០,០	៣ ៧២០ ៤០៥,៣	១០០,៩%
II. សរុបចំណាយ	**១៥ ០៣៥ ២២៩,០**	**១៤ ៦៦០ ១៤៧,១**	**៩៧,៥%**
-ចំណាយចរន្ត	៩ ២៧៥ ១៦១,០	៩ ០៦៦ ៨០៤,៨	៩៧,៨%
-ចំណាយមូលធន	២ ០៧៣ ០៦៨,០	១ ៨៧២ ៩៣៧,០	៩០,៣%
-ចំណាយមូលធនដោយហិរញ្ញប្បទានក្រៅប្រទេស	៣ ៦៨៧ ០០០,០	៣ ៧២០ ៤០៥,៣	១០០,៩%

ខ-កិច្ចប្រតិបត្តិការថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

ខ១/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលរាជធានី ខេត្ត

ឯកតា : លានរៀល

បរិយាយ	២០១៥		
	ច្បាប់ហិរញ្ញវត្ថុ	អនុវត្ត	ភាគរយ
	1	*2*	*3 = (2/1)*
I. សរុបចំណូលថវិកា	**៧៥៣ ៩៤០,០**	**៨៩៥ ៦៨០,១**	**១១៨,៨%**
-ចំណូលចរន្ត	៦៦០ ៦៩៩,០	៨០២ ៥៣៩,១	១២១,៥%
•ចំណូលសារពើពន្ធ	៦៣២ ៣០០,០	៧៦១ ៣៧២,៣	១២០,៤%
•ចំណូលមិនមែនសារពើពន្ធ	២៨ ៣៩៩,០	៥១ ០៦៦,៨	១៤៤,៦%
-ឧបត្ថម្ភពីថវិកាថ្នាក់ជាតិ	៩៣ ២៤១,០	៩៣ ២៤១,០	១០០,០%
II. សរុបចំណាយថវិកា	**៧៥៣ ៩៤០,០**	**៨៩៥ ៦៧៥,៨**	**១១៨,៨%**
-ចំណាយចរន្ត	៦២១ ០៧៩,០	៧០៣ ៩៤០,៨	១១៣,៣%
-ចំណាយមូលធន	១៣២ ៨៦១,០	១៩១ ៧៣៥,០	១៤៤,៣%

ខ២/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលក្រុង ស្រុក

ឯកតា : លានរៀល

បរិយាយ	២០១៥		
	ច្បាប់ហិរញ្ញវត្ថុ	អនុវត្ត	ភាគរយ
	1	*2*	*3 = (2/1)*
I. សរុបចំណូលថវិកា	**៨១ ៣០២,០**	**១០១ ៣៩៩,៥**	**១២៤,៧%**
-ចំណូលចរន្ត (មិនមែនសារពើពន្ធ)	៣ ៦០១,០	២៥ ០៦១,៥	៦៦៨,២%
-ចំណូលឧបត្ថម្ភពីថវិកាថ្នាក់ជាតិ	៧៧ ៧០១,០	៧៧ ៣៣៨,០	៩៩,៥%
II. សរុបចំណាយថវិកា	**៨១ ៣០២,០**	**៩៧ ៨៦៥,៨**	**១២០,៤%**
-ចំណាយចរន្ត	៨១ ៣០២,០	៩៧ ៨៦៥,៨	១២០,៤%

ខ៣/កិច្ចប្រតិបត្តិការថវិការបស់រដ្ឋបាលឃុំ សង្កាត់

ឯកតា : លានរៀល

បរិយាយ	២០១៥		
	ច្បាប់ហិរញ្ញវត្ថុ	អនុវត្ត	ភាគរយ
	1	*2*	*3 = (2/1)*
I. សរុបចំណូលថវិកា	**២៧១ ៩៥៤,០០**	**៣៧៥ ០៥៤,៦៣**	**១៣៧,៩%**
-ចំណូលមិនមែនសារពើពន្ធ	០	១០ ៨៨០,៧៩	
-ចំណូលឧបត្ថម្ភពីថវិកាជាតិ	២៧១ ៩៥៤,០០	២៧១ ៩៥៤,០០	១០០,០%
-អតិរេកឆ្នាំ២០១៤	០	៩២ ២១៩,៨៤	
II. សរុបចំណាយថវិកា	**២៧១ ៩៥៤,០០**	**២៩៤ ៣០៦,៦៥**	**១០៨,២%**
-ចំណាយសង្កាត់ចំណុះរាជធានី	១៨ ០៧៧,៥៣	១៨ ៦៥៩,១៣	១០៣,២%
-ចំណាយសង្កាត់ចំណុះក្រុង	២១ ៣២១,៩៧	២៣ ៣៥៣,៥៥	១០៩,៥%
-ចំណាយឃុំ	២៣២ ៥៥៤,៥០	២៥២ ២៩៣,៩៧	១០៨,៥%

៣. លទ្ធផលសវនកម្ម

៣.១. ការគ្រប់គ្រងថវិកាថ្នាក់ជាតិ

៣.១.១. ការលើកលែងប្រាក់ពិន័យដល់ក្រុមហ៊ុនសហគ្រាសយឺតយ៉ាវចុះបញ្ជីពន្ធ

ដើម្បីគ្រប់គ្រងអ្នកជាប់ពន្ធ និងប្រមូលពន្ធពីការធ្វើអាជីវកម្មគ្រប់ប្រភេទសម្រាប់ទ្រទ្រង់ថវិកាជាតិ រដ្ឋសភាបានអនុម័តច្បាប់ស្តីពីសារពើពន្ធដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០២៩៧/០៣ ចុះថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ១៩៩៧។ ត្រង់មាត្រា១២៨នៃច្បាប់នេះបានចាត់ទុកការចាប់ផ្តើមអាជីវកម្មដោយមិនបានចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធថាជាអំពើរាំងស្ទះការអនុវត្តបទប្បញ្ញត្តិស្តីពីពន្ធដារ និងត្រង់មាត្រា១៣០នៃច្បាប់នេះ ពន្ធបន្ថែមត្រូវអនុវត្តចំពោះបទល្មើសបទប្បញ្ញត្តិស្តីពីពន្ធដារ។ តាមការពិនិត្យរបាយការណ៍របស់ក្រុមការងារចុះបញ្ជីឆ្នាំ២០១៥ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនបានមកចុះបញ្ជីមានចំនួន៤ ២២៧ ក្រុមហ៊ុន ហើយមានក្រុមហ៊ុនត្រូវរងនូវទោសទណ្ឌ (ពន្ធបន្ថែមការប្រាក់)។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានពន្ធដារមិនបានពិន័យក្រុមហ៊ុនមួយចំនួនដែលបានមកចុះបញ្ជីយឺតយ៉ាវមិនទាន់ពេលវេលាតាមច្បាប់កំណត់។

ការខកខានក្នុងការអនុវត្តការពិន័យអាចនាំឱ្យបាត់បង់ប្រាក់ពន្ធ ឬការអនុវត្តរបបនៃការបង់ពន្ធមិនមានតម្លាភាព។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអង្គភាពប្រតិបត្តិខាងលើអនុវត្តមុខងាររបស់ខ្លួនឱ្យបានសមស្របតាមលិខិតបទដ្ឋានខាងលើ។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងសូមបញ្ជាក់បន្ថែមថា បច្ចុប្បន្នមានយន្តការជំរុញអ្នកជាប់ពន្ធឱ្យមកចុះបញ្ជីពន្ធដារដោយស្ម័គ្រចិត្ត និងស្មោះត្រង់បានគ្រប់ៗគ្នា បានតម្រូវឱ្យមានការអនុគ្រោះនូវការជាកពិន័យមួយចំនួនតូចដែលជាឧបសគ្គដល់ការចុះបញ្ជីពន្ធដារ។ ថ្មីៗនេះ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងរៀបចំសេចក្តីព្រាងអនុក្រឹត្យ និងប្រកាសស្តីពីការលើកទឹកចិត្តពន្ធដារចំពោះការចុះបញ្ជីដោយស្ម័គ្រចិត្តរបស់អ្នកជាប់ពន្ធបន្ថែមទៀត ដើម្បីចលនាឱ្យអ្នកជាប់ពន្ធមកចុះបញ្ជីបង់ពន្ធដោយស្ម័គ្រចិត្តឱ្យបានច្រើន និងគ្រប់សហគ្រាសក្នុងគោលបំណងប្រមូលប្រាក់ពន្ធឱ្យបានជាអតិបរមា។ បន្ថែមពីនេះទៀត នៅក្នុងឆ្នាំ២០១៤-២០១៥ អគ្គនាយកដ្ឋានពន្ធដារបានបង្កើតប្រព័ន្ធចុះបញ្ជីតាម Online និងដោយប្រើប្រាស់កុំព្យូទ័រ ហើយបានជំរុញលើកទឹកចិត្តអ្នកជាប់ពន្ធឱ្យមកចុះបញ្ជី គឺពុំបានដាក់ទោស ឬពិន័យអ្វីទេ។

៣.១.២. ប្រាក់កក់នៅសល់រយៈពេលយូរពុំទាន់បានជម្រះបញ្ជី

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីនិមុត្តិធានាដោយបញ្ជាក់ថា រដ្ឋបាលគយអាចតម្រូវឱ្យតម្កល់នូវនិមុត្តិធានា ដើម្បីធានានូវការបង់ពន្ធ និងអាករ ដើម្បីធានាថាប្រតិវេទន៍ករ និងភាគីទទួលខុសត្រូវផ្សេងៗទៀតបំពេញនូវកាតព្វកិច្ចតាមនីតិវិធីគយ ឬការអនុវត្តច្បាប់ផ្សេងៗទៀត និងរដ្ឋបាលគយត្រូវដោះបន្ទុកនិមុត្តិធានាឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន ក្រោយពេលដែលមន្ត្រីគយមានសមត្ថកិច្ចពិនិត្យឃើញថា កាតព្វកិច្ចនានានៃនិមុត្តិធានាត្រូវបានបំពេញរួចរាល់ រាប់បញ្ចូលទាំងការបង់ពន្ធ និងអាករ។

តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជាមាននៅសល់ប្រាក់កក់នៅក្នុងគណនីប្រាក់រៀល និងគណនីប្រាក់ដុល្លារដែលមានរយៈពេលយូរពុំទាន់បានជម្រះបញ្ជីនៅឡើយគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបញ្ជាក់ថា ការតម្កល់និមុត្តិធានាត្រូវបានកើតឡើងជាប្រចាំ ហើយការដោះបន្ទុកក៏ត្រូវបានធ្វើជាប្រចាំតាមប្រកាសស្តីពីនិមុត្តិធានា ចំពោះករណីខ្លះ និមុត្តិធានាត្រូវបានរក្សាទុកយូរទៅតាមលក្ខខណ្ឌនៃនិមុត្តិធានាដែលមិនតម្រូវឱ្យដកវិញក្នុងរយៈពេលខ្លីទេ ដូចជា ការតម្កល់ដើម្បីប្រកបធុរកិច្ចជើងសារគយប្រតិបត្តិការភណ្ឌាគារគយមានដែនកំណត់រាប់បញ្ចូលទាំងអគារលក់ទំនិញរួចពន្ធ និងជាប្រតិបត្តិករផែស្ងួតជាដើម និងករណីខ្លះទៀត និមុត្តិធានាត្រូវបានរក្សាទុកយូរដោយសារ

ម្ចាស់មិនចូលខ្លួនមកដោះបន្ទុក។ ករណីដូចនេះក៏មិនអាចដោះស្រាយរយៈពេលខ្លីបានដែរ គឺត្រូវការពេលវេលាដើម្បីស្រាវជ្រាវរកម្ចាស់មកដោះបន្ទុក ហើយករណីខ្លះត្រូវមានដីកាសម្រេចពីតុលាការទៀតផង។

៣.១.៣. តម្លៃមូលដ្ឋានសម្រាប់បង់ពន្ធនាំចូលលើរថយន្តទំនើប

រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យស្តីពីការតម្លើងទីចាត់ការគយ និងរដ្ឋាករ...ឲ្យទៅជាអគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ក្នុងនោះមានតួនាទី និងភារកិច្ចក្នុងការស្រាវជ្រាវ និងកែសម្រួលជាប្រចាំនូវបញ្ជីតម្លៃគិតពន្ធអាករគយសម្រាប់ពិចារណាលើទំនិញនាំចេញ នាំចូល តម្លៃរូបិយប័ណ្ណ អត្រាប្តូរប្រាក់ឱ្យបានសមស្របតាមភាពជាក់ស្តែងសម្រាប់ជាមូលដ្ឋានពិចារណា និងសម្រេចចិត្តក្នុងការអនុវត្តការងាររបស់អង្គភាពគយ និងរដ្ឋាករមូលដ្ឋាន។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការបង្កើត និងកិច្ចដំណើរការអង្គភាពគ្រប់គ្រងតម្លៃចម្លងការនៃទំនិញនាំចូល និងលិខិតស្តីពីការកែសម្រួលជាបណ្តោះអាសន្ននូវតារាងតម្លៃចម្លងការសម្រាប់ជាមូលដ្ឋានពិចារណាលើរថយន្តនាំចូលប្រភេទប្រើរួចដោយត្រូវដាក់ឱ្យអនុវត្តចំពោះទំនិញដែលផ្ទុកចូលមធ្យោបាយដឹកជញ្ជូននៅឯបរទេស ដើម្បីនាំចូលមកព្រះរាជាណាចក្រកម្ពុជាចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥។

តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការប្រកាសតម្លៃមូលដ្ឋានគិតពន្ធលើការនាំចូលរថយន្តស៊េរីទំនើបមួយចំនួនមានដូចជា LAMBORGHINI HURACAN MCLAREN P1, ROLLS ROYCE នៅមានលក្ខណៈមិនទាន់បានសមស្របនៅឡើយ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានបំភ្លឺថា អាចមានករណីមួយចំនួនតូចដូចនេះមែនដោយហេតុថា ទំនិញប្រភេទនេះ ជារួមក្នុងដំណាក់កាលនេះមានបរិមាណតិចតួច ហើយនាំចូលសម្រាប់បម្រើឱ្យការតាំងពិព័ណ៌ ការបើកបង្ហាញសាកល្បងប៉ុណ្ណោះ មានន័យថាកំពុងស្វែងរកទីផ្សារ និងពុំទាន់មានលក្ខណៈពាណិជ្ជកម្មមួយពេញលេញនៅឡើយ។

៣.១.៤. ជើងសារគយហួសសុពលភាពយកមកបំពេញបែបបទគយ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការបង្កើត និងកិច្ចដំណើរការជើងសារគយ ដោយបានបញ្ជាក់ថា បុគ្គលដែលមានសិទ្ធិសម្បទា ដើម្បីបំពេញបែបបទគយបាន មានដូចជា អ្នកនាំចូល អ្នកនាំចេញ ម្ចាស់ទំនិញ ឬតំណាងមានការអនុញ្ញាតអាចធ្វើការបំពេញបែបបទគយតែលើទំនិញសម្រាប់អាជីវកម្មរបស់ខ្លួនផ្ទាល់ និងជាបុគ្គលទាំងឡាយណាដែលទទួលបានការអនុញ្ញាតជាជើងសារគយមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ អាជ្ញាប័ណ្ណជើងសារគយត្រូវកំណត់នៅការិយាល័យគយដែលជើងសារនោះត្រូវបានអនុញ្ញាតឱ្យធ្វើប្រតិបត្តិការ និងលក្ខខណ្ឌចាំបាច់ជាកាតព្វកិច្ចនានារបស់ជើងសារគយ អាជ្ញាប័ណ្ណនេះត្រូវផ្តល់ជូនសម្រាប់រយៈពេលពីរ(២)ឆ្នាំ។

តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនជើងសារចំនួន០៤ ហួសសុពលភាពកំណត់ ប៉ុន្តែបានអនុញ្ញាតឱ្យមកស្នើសុំបំពេញបែបបទនាំទំនិញចូលក្នុងព្រះរាជាណាចក្រកម្ពុជា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាពថា អាចមានករណីមួយចំនួនតូចដូចនេះមែនដោយហេតុថា នេះជាការអនុគ្រោះរយៈពេលខ្លីប៉ុណ្ណោះដើម្បីទុកឱកាសឱ្យជើងសារគយខ្លះដែលបានតម្កល់និមុត្តិធានាអាជីវកម្ម និងមានអត្តសញ្ញាណច្បាស់លាស់អាចបន្តការងាររបស់ខ្លួន ជៀសវាងការរាំងស្ទះដល់លំហូរទំនិញរបស់វិនិយោគិន អាជីវករត្រឹមត្រូវដែលជាអតិថិជនរបស់ជើងសារទាំងនោះ។

៣.១.៥. ភាពយឺតយ៉ាវក្នុងការបង់ចំណូលពីការជួលទីតាំង

ដើម្បីជំរុញដល់ក្រសួងស្ថាប័នឱ្យធ្វើការបង់ចូលចំណូលដែលប្រមូលបានបង់ចូលថវិការដ្ឋឱ្យបានទាន់ពេលវេលា និងត្រឹមត្រូវទៅតាមការិយបរិច្ឆេទនៃឆ្នាំថវិកា រាជរដ្ឋាភិបាលបានចេញនូវអនុក្រឹត្យលេខ៨២ អនក្រ.បក ចុះថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ១៩៩៦ ត្រង់មាត្រា១០៦ បានចែងថា ចំណូលត្រូវបានគិតចូលក្នុងថវិកានៃឆ្នាំ ដែលក្នុងអំឡុងនោះចំណូលទាំងនេះត្រូវបានប្រមូលដោយគណនេយ្យករសាធារណៈ និងប្រកាសណែនាំលេខ០១៤ សហវ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការបិទបញ្ជីចំណូលចំណាយ និងធ្វើរបាយការណ៍ហូរសរុបអនុវត្តចំណូលចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៥ ត្រង់ចំណុចទី I.ក បានចែងថា "ចំណូលថវិកាទាំងអស់ ទោះស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬមួយពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ..."។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈនៅមានភាពយឺតយ៉ាវក្នុងការបង់ចំណូលពីថ្លៃឈ្នួលជួលទីតាំងក្នុងឆ្នាំ២០១៤ មួយចំនួនចូលថវិការដ្ឋ។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួរធ្វើការបង់ចំណូលពីការជួលទីតាំងចូលថវិការដ្ឋឱ្យបានទាន់ពេលវេលា។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសូមធ្វើការបញ្ជាក់ថា ចំពោះរោងមហោស្រពខេត្តកំពង់ចាម បន្ទាប់មកបានទូទាត់រួចប័ណ្ណបង់ប្រាក់លេខ/RefNO FJB1501300000103 កាលបរិច្ឆេទថ្ងៃទី១៣-០១-២០១៥ (បង់ឆ្នាំ២០១៥)។

៣.១.៦. ការដកប្រាក់រង្វាន់២០%យកទៅចំណាយដើម្បីពង្រឹងយន្តការប្រមូលចំណូល

ក្នុងយន្តការពង្រឹងការបែងចែកប្រាក់រង្វាន់លើកទឹកចិត្តជូនដល់មន្ត្រីពីការប្រមូលចំណូលឱ្យកាន់តែមានប្រសិទ្ធភាព និងតម្លាភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសរួមលេខ៩៨៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២ ត្រង់ប្រការ៦ ចំណុច**ក** បានចែងថា ការបើកផ្តល់ប្រាក់រង្វាន់ជូនមន្ត្រីរាជការនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ត្រូវអនុលោមតាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ដោយឈរលើគោលការណ៍សមធម៌ និងផ្អែកតាមគុណសម្បត្តិការងារ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានសារមន្ទីរបានដកប្រាក់រង្វាន់លើកទឹកចិត្ត២០% យកទៅចំណាយលើដំណើរការរដ្ឋបាល ពង្រឹងយន្តការប្រមូលចំណូល និងដោះស្រាយការងារសង្គមពុំទាន់បានស្របតាមគោលការណ៍ចំណាយសម្រាប់ប្រាក់រង្វាន់លើកទឹកចិត្តនៅឡើយ។

អាស្រ័យហេតុនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួរធ្វើការណែនាំដល់នាយកដ្ឋានសារមន្ទីរជាតិត្រូវធ្វើការចំណាយប្រាក់រង្វាន់លើកទឹកចិត្តឱ្យបានត្រឹមត្រូវ និងស្របទៅតាមប្រកាសរួមខាងលើ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសូមបញ្ជាក់ថា:

១. ប្រាក់រង្វាន់ចំនួន២៩%នៃចំណូលសរុបនៅសារមន្ទីរជាតិ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានធ្វើការបែងចែកចំនួន៧០%ជូនមកនាយកដ្ឋានសារមន្ទីរ ដើម្បីបើកជាប្រាក់រង្វាន់ដល់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់នៅសារមន្ទីរជាតិ។ ចំណែកប្រាក់រង្វាន់៧០% ដែលសារមន្ទីរជាតិកម្ពុជាទទួលបាននេះ នាយកដ្ឋានសារមន្ទីរបានធ្វើការបែងចែកជាពីរបន្តទៀត គឺ៨០%សម្រាប់បើកជាប្រាក់រង្វាន់ជូនមន្ត្រីរាជការ មន្ត្រីកិច្ចសន្យា និងពលកររសេរីប្រចាំសារមន្ទីរជាតិ និង២០%សម្រាប់ពង្រឹងយន្តការប្រមូលចំណូល។ ដូច្នេះ ការលម្អៀងសាច់ប្រាក់ក្រៅបញ្ជីថវិការដ្ឋប្រាក់រង្វាន់មួយចំនួននេះ គឺជាថវិកាដែលនាយកដ្ឋានបានបែងចែកចំនួន២០% ពីចំណែករបស់ខ្លួនសម្រាប់ពង្រឹងយន្តការប្រមូលចំណូល។ ថវិកា២០%នេះសារមន្ទីរជាតិប្រើប្រាស់ក្នុងទិសដៅពង្រឹងយន្តការប្រមូលចំណូល ដូចតទៅ៖

- រៀបចំសណ្តាប់ធ្នាប់ទូទៅក្នុងបរិវេណ និងជុំវិញសារមន្ទីរជាតិ
- កែលម្អស្លាកសញ្ញាផ្សេងៗក្នុងថែរពិព័រណ៌
- ថែទាំអគារខ្នាតតូច
- ជួសជុលទឹក ភ្លើង និងផ្លាស់ប្តូរអំពូល និងបរិក្ខារអគ្គីសនី ដែលតែងខូចជាប្រចាំ
- ថែទាំសួន និងការផ្គត់ផ្គង់សម្ភារសម្រាប់កាត់ស្មៅ កាត់របង និងមែកឈើ
- ឧបត្ថម្ភដល់មន្ត្រីយាមប្រចាំការពេលថ្ងៃត្រង់ពីម៉ោង១១ និង៣០នាទី ដល់ម៉ោង១៣ និង៣០នាទី
- ឧបត្ថម្ភដល់កម្លាំងនគរបាលមូលដ្ឋាន និងនគរបាលទេសចរណ៍ឈរជើងប្រចាំការ ដើម្បីរក្សាសុវត្ថិភាពជូនភ្ញៀវទេសចរណ៍ និងរៀបចំសណ្តាប់ធ្នាប់រថយន្តទេសចរណ៍
- ឧបត្ថម្ភប្រាក់លើកទឹកចិត្តមន្ត្រីក្នុងឱកាសបុណ្យសិទ្ធិនារីថ្ងៃទី០៨ ខែមីនា
- និងឧបត្ថម្ភការថែទាំសុខភាពមន្ត្រី និងសង្គមកិច្ច ដូចជាចូលបុណ្យសពគ្រួសារមន្ត្រីជាដើម។

២. ករណីសារមន្ទីរជាតិរក្សាសាច់ប្រាក់លើសចំនួនកំណត់: នាយកដ្ឋានសារមន្ទីរតែងតែបង្វិលសាច់ប្រាក់ចូលធនាគារជាតិ បែងចែកជូនក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ រៀងរាល់ពីរសប្តាហ៍ម្តង។ អាស្រ័យហេតុនេះ ក្នុងរដូវទេសចរណ៍ខ្ពស់ ចំណូលប្រចាំថ្ងៃតែងមានចំនួនច្រើន ដែលការរង់ចាំដល់ថ្ងៃកំណត់អាចនាំឱ្យសាច់ប្រាក់កើនលើសចំនួនគោលការណ៍កំណត់។ ក្នុងករណីនេះ ពេលខ្លះចំណូលតែមួយថ្ងៃក៏អាចលើសកំណត់នៃសាច់ប្រាក់ដែលស្ថាប័នអាចរក្សាទុកបានតាមច្បាប់កំណត់។ អាស្រ័យហេតុនេះ សារមន្ទីរជាតិពុំអាចមានលទ្ធភាពបង់រាល់ថ្ងៃបានដោយសារមន្ត្រីនៃការិយាល័យរដ្ឋបាល និងគណនេយ្យនៃនាយកដ្ឋានសារមន្ទីរមានចំនួនមិនគ្រប់គ្រាន់។ ទន្ទឹមនឹងនេះ រដ្ឋទេយ្យកររងចំណូលនៃនាយកដ្ឋានមានវ័យចំណាស់ និងសុខភាពមិនសូវមាំមួនដែលមិនអាចធ្វើការឱ្យរហ័សរហួនបាន។ នាយកដ្ឋាននឹងពិនិត្យលទ្ធភាពបន្ថែមមន្ត្រីវ័យក្មេងជាជំនួយការ ដើម្បីធ្វើយ៉ាងណាអាចជួយរៀបចំឯកសារបង់ចំណូលឱ្យបានមួយសប្តាហ៍ម្តង។

៣.១.៧. ការប្រមូលមូលនិធិទាយជ្ជទានបរិស្ថានមិនអស់លទ្ធភាព

ច្បាប់កិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិត្រូវបានអនុម័ត ដើម្បីជាប្រយោជន៍សម្រាប់អនុវត្តការងារជាប្រចាំទៅលើបរិស្ថាន ដោយតម្រូវឱ្យមានការប្រមូលមូនិធិទាយជ្ជទានបរិស្ថានសម្រាប់ការស្តារឡើងវិញទៅលើផ្នែកនេះ។

តាមការពិនិត្យលើការប្រមូលមូលនិធិទាយជ្ជទានបរិស្ថានសម្រាប់ការិយបរិច្ឆេទឆ្នាំ២០១៥ ឃើញថា ម្ចាស់គម្រោងមួយចំនួនបានបង់មូលនិធិទាយជ្ជទាននេះបានត្រឹមត្រូវនៅក្រសួងបរិស្ថាន ប៉ុន្តែម្ចាស់គម្រោងមួយចំនួនទៀតពុំបានបង់មូលនិធិទាយជ្ជទាននេះទេ ដែលធ្វើឱ្យការប្រមូលចំណូលពីមូលនិធិទាយជ្ជទាននេះពុំទាន់អស់លទ្ធភាព។

ការខកខានរបស់ម្ចាស់គម្រោងមួយចំនួននេះ នាំឱ្យប្រមូលប្រាក់មូលនិធិទាយជ្ជទានបរិស្ថានមិនទាន់ពេលវេលា និងអាចមានការបាត់បង់ជាយថាហេតុ។

ក្រសួងបរិស្ថានបានបំភ្លឺថា ថវិកាបំណុលដែលសវនករបានរកឃើញនោះ ក្រសួងសូមបញ្ជាក់ថា ក្រុមហ៊ុនមួយចំនួនមានភាពយឺតយ៉ាវក្នុងការបង់មូលនិធិទាយជ្ជទានបរិស្ថានដោយសារក្រុមហ៊ុនមួយចំនួនបិទអាជីវកម្ម ឬប្តូរទីតាំង និងមានចេតនាពុំបង់មូលនិធិនេះ។ ទន្ទឹមនឹងនេះ ក្រសួងបាននិងឯកំពុងជំរុញឱ្យក្រុមហ៊ុនដែលមានបំណុលធ្វើការបង់ថវិកាមូលនិធិទាយជ្ជទានបរិស្ថានឱ្យអស់លទ្ធភាព ក្រសួងក៏មានវិធានការចំពោះក្រុមហ៊ុនដែលមិនបានបង់មូលនិធិទាយជ្ជទាន ដូចតទៅ ចាត់វិធានការរដ្ឋបាលដោយចេញលិខិតព្រមានទៅក្រុមហ៊ុនដែលខកខាន ឬមិនបានបង់មូលនិធិទាយជ្ជទានបរិស្ថាន ផ្សព្វផ្សាយដល់ក្រុមហ៊ុនជំពាក់បំណុលមូលនិធិទាយជ្ជទានបរិស្ថានជាសាធារណៈ សហការជាមួយក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ដើម្បីផ្អាកការនាំចេញរបស់ក្រុមហ៊ុន និងធ្វើបច្ចុប្បន្នភាពចំពោះក្រុមហ៊ុនដែលបានបិទអាជីវកម្ម និងប្តូរទីតាំងដោយសហការជាមួយក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣.១.៨.ការប្រមូលចំណូលពីប្រាក់តម្កល់ធានាអប្បបរមាមិនបានពេញលេញ

ដើម្បីគ្រប់គ្រងលើការប្រមូលចំណូលពីប្រាក់តម្កល់របស់គ្រឹះស្ថានសិក្សាឯកជនក្នុងការស្នើសុំអាជ្ញាប័ណ្ណបើកគ្រឹះស្ថានបង្រៀន និងរៀន ក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញលិខិតលេខ២៩៥ អយក.ហវ ចុះថ្ងៃទី២៧ ខែមករា ឆ្នាំ២០១៤ របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីសំណើសុំអនុញ្ញាតគោលការណ៍តម្កល់ប្រាក់កក់អប្បបរមានៅរតនាគារជាតិក្នុងពេលអនុវត្តកិច្ចសន្យាសម្រាប់ការផ្តល់អាជ្ញាប័ណ្ណបើកគ្រឹះស្ថានសិក្សាឯកជននៅក្រសួងអប់រំ យុវជន និងកីឡាតម្រូវឱ្យអតិថិជនរួបរួនបុគ្គលឬនីតិបុគ្គលចាំបាច់ត្រូវតម្កល់ប្រាក់កក់អប្បបរមានៅរតនាគារជាតិក្នុងពេលអនុវត្តកិច្ចសន្យាសម្រាប់ផ្តល់អាជ្ញាប័ណ្ណបើកគ្រឹះស្ថានសិក្សាឯកជន បញ្ជាក់ថា "គ្រឹះស្ថានបឋមសិក្សាឯកជន (កម្មវិធីសិក្សាជាតិ) នៅរាជធានីចំនួន២៤ ០០០ ០០០រៀល គ្រឹះស្ថានបឋមសិក្សាឯកជន (កម្មវិធីអន្តរជាតិ) នៅរាជធានីចំនួន៤០ ០០០ ០០០រៀល គ្រឹះស្ថានមធ្យមសិក្សាទុតិយភូមិឯកជន(កម្មវិធីសិក្សាជាតិ) នៅរាជធានីចំនួន៥៦ ០០០ ០០០រៀល គ្រឹះស្ថានមធ្យមសិក្សាទុតិយភូមិឯកជន (កម្មវិធីសិក្សាអន្តរជាតិ) នៅរាជធានីចំនួន៨០ ០០០ ០០០រៀល គ្រឹះស្ថានមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិ (កម្មវិធីសិក្សាជាតិ)នៅរាជធានី ចំនួន ១០០ ០០០ ០០០រៀល គ្រឹះស្ថានមត្តេយ្យសិក្សាដល់មធ្យមសិក្សាទុតិយភូមិ (កម្មវិធីសិក្សាអន្តរជាតិ) នៅរាជធានីចំនួន១២០ ០០០ ០០០រៀល គ្រឹះស្ថានឧត្តមសិក្សាឯកជន(កម្មវិធីសិក្សាជាតិ) ចំនួន១៦០ ០០០ ០០០រៀល និងគ្រឹះស្ថានឧត្តមសិក្សាឯកជន(កម្មវិធីអន្តរជាតិ) ចំនួន២៤០ ០០០ ០០០រៀល..." និងលិខិតលេខ១៣៨៨ សហវ.អ ទច ចុះថ្ងៃទី១៤ ខែមីនា ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើករណីឯកភាពជាគោលការណ៍លើការតម្រូវឱ្យម្ចាស់គ្រឹះស្ថានសិក្សាឯកជននីមួយៗត្រូវដាក់ប្រាក់តម្កល់ធានាអប្បបរមានៅអគ្គនាយកដ្ឋានរតនាគារជាតិសម្រាប់ការផ្តល់អាជ្ញាប័ណ្ណបើកគ្រឹះស្ថានសិក្សានានា នៅក្នុងព្រះរាជាណាចក្រកម្ពុជា។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងអប់រំ យុវជន និងកីឡា មិនទាន់បានប្រមូលចំណូលពីការបង់ប្រាក់តម្កល់ធានាអប្បបរមា សម្រាប់ផ្តល់អាជ្ញាប័ណ្ណបើកគ្រឹះស្ថានសិក្សាឯកជនចំនួន១០៤ (គ្រឹះស្ថានសិក្សាចំណេះដឹងទូទៅឯកជន និងគ្រឹះស្ថាន ឧត្តមសិក្សា) នៅឡើយ។

ក្រសួងអប់រំ យុវជន និងកីឡាគួរចាត់វិធានការឱ្យបានម៉ឺងម៉ាត់ចំពោះគ្រឹះស្ថានសិក្សាឯកជនដែលមិនបានបង់ប្រាក់តម្កល់ធានាអប្បបរមាសម្រាប់ផ្តល់អាជ្ញាបណ្ណបើកបង្រៀន និងរៀន។

ឆ្លើយតបនឹងករណីនេះ ក្រសួងអប់រំ យុវជន និងកីឡាមិនបានព្រងើយកន្តើយដោយបានរៀបចំពិភាក្សាជាច្រើនលើកច្រើនសារ ដើម្បីចូលរួមពង្រឹងការគ្រប់គ្រង និងការប្រមូលចំណូលពីការបង់ប្រាក់តម្កល់ធានាអប្បបរមាក្នុងការអនុញ្ញាតផ្តល់អាជ្ញាប័ណ្ណបើកគ្រឹះស្ថានសិក្សាឯកជនមានដូចខាងក្រោម៖

១-យោងកិច្ចប្រជុំពីថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៤ ដែលតម្រូវឱ្យគ្រឹះស្ថានសិក្សាដែលធ្វើសកម្មភាពបណ្តុះបណ្តាលអប់រំទូទាំងប្រទេស ត្រូវមានអាជ្ញាប័ណ្ណ អង្គប្រជុំបានឯកភាពលើគោលការណ៍ដូចខាងក្រោម៖

– គ្រឹះស្ថានសិក្សាដែលបើកដំណើរការបណ្តុះបណ្តាលមុនឆ្នាំ២០១៤ តម្រូវឱ្យសុំអាជ្ញាប័ណ្ណបើកបន្តសុពលភាពនៃការបណ្តុះបណ្តាលអប់រំឡើងវិញ ដោយបង់តែថ្លៃសេវារដ្ឋបាល តែចាំបាច់ដាក់ប្រាក់តម្កល់អប្បបរមានៅរតនាគារជាតិ។

– គ្រឹះស្ថានសិក្សាដែលបើកបណ្តុះបណ្តាលក្រោយឆ្នាំ២០១៤ តម្រូវឱ្យសុំអាជ្ញាប័ណ្ណថ្មីជាការបណ្តុះបណ្តាលអប់រំ ដោយតម្រូវឲ្យបង់ថ្លៃសេវារដ្ឋបាល និងដាក់ប្រាក់តម្កល់អប្បបរមានៅរតនាគារជាតិផង។

– ចំពោះគ្រឹះស្ថានសិក្សាចំនួន១០៤ ជាគ្រឹះស្ថានសិក្សាដែលមានអាជ្ញាប័ណ្ណចាស់មុនឆ្នាំ២០១៤ មុនមានកិច្ចដំណើរច្រកចេញចូលតែមួយដែលគ្រឹះស្ថានសិក្សាទាំងនោះនឹងត្រូវសុំបន្តសុពលភាពជាថ្មីឡើងវិញតាមសេចក្តីសម្រេច និងសេចក្តីណែនាំរបស់ក្រសួង បើមិនដូចនេះទេ គ្រឹះស្ថានទាំងនេះនឹងប្រឈមការបញ្ឈប់ដំណើរការ។ ជាមួយគ្នានោះ មានគ្រឹះស្ថានសិក្សាមួយចំនួនបានដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណបន្តសុពលភាពជាបន្តបន្ទាប់តាមការណែនាំរបស់ក្រសួង។

២-ចាប់តាំងពីឆ្នាំ២០១៤រហូតដល់ឆ្នាំ២០១៦ ច្រកចេញចូលតែមួយបានរៀបចំកែលម្អលិខិតបទដ្ឋាន និងបទប្បញ្ញត្តិមួយចំនួនដូចជា៖

– កែសម្រួលឧបសម្ព័ន្ធនៃប្រកាសរួមលេខ១០១១ សហវ.ប្រក ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០១២

– សេចក្តីណែនាំលេខ២៨ អយក.សណន ស្តីពីការស្នើសុំអាជ្ញាប័ណ្ណអប់រំ បើកគ្រឹះស្ថានសិក្សាចំណេះដឹងទូទៅចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការធ្វើសុពលភាពឡើងវិញក្នុងការស្នើសុំអាជ្ញាប័ណ្ណអប់រំ បើកគ្រឹះស្ថានសិក្សាឯកជន។

– លិខិតជូនដំណឹងលេខ៣៣២០ អយក.នក ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦ ស្តីពីការជូនដំណឹងទៅម្ចាស់គ្រឹះស្ថានសិក្សាចំណេះដឹងទូទៅឯកជនទាំងនោះ ដោយកំណត់ឲ្យអថិតជនយកប្រាក់ទៅដាក់តម្កល់ធានាអប្បបរមានៅធនាគារជាតិ និងការមកទទួលយកអាជ្ញាប័ណ្ណ ដោយមិនអនុញ្ញាតឱ្យហួសពីខែកក្កដា ឆ្នាំ២០១៦ បើពុំអនុវត្តតាមសេចក្តីជូនដំណឹង ក្រសួងនឹងចាត់វិធានការតាមផ្លូវច្បាប់ជាបន្តបន្ទាប់ចំពោះគ្រឹះស្ថានសិក្សាដែលមិនមានអាជ្ញាប័ណ្ណ។

– ក្រសួងបានចេញលិខិតលេខ៣៤៦៧ អយក.នក ចុះថ្ងៃទី០៧ ខែកក្កដា ឆ្នាំ២០១៦ ជូនទៅរតនាគារជាតិស្តីពីការកំណត់នីតិវិធីលើកិច្ចប្រតិបត្តិការសម្រាប់ការដកប្រាក់តម្កល់ធានាអប្បរមារបស់ម្ចាស់គ្រឹះស្ថានសិក្សាឯកជន ដើម្បីយកមកប្រើប្រាស់វិញ។

– ក្រសួងកំពុងរៀបចំវិធានការថ្មីបន្ថែមទៀតរបស់ច្រកចេញចូលតែមួយ ក៏ដូចជាថ្នាក់ដឹកនាំក្រសួងនឹងដាក់ឲ្យអនុវត្តឆាប់ៗ គឺការជូនដំណឹងទៅម្ចាស់គ្រឹះស្ថានប្រមាណជាង១០០គ្រឹះស្ថានសិក្សា ដែលក្រសួងបានចេញប្រកាសរួចហើយ មិនបានដាក់ប្រាក់តម្កល់ និងមិនយកអាជ្ញាប័ណ្ណគឺតម្រូវឱ្យអចិតិជនមកដកយកសំណុំឯកសារស្នើសុំអាជ្ញាប័ណ្ណត្រឡប់ទៅវិញ និងនិរាករណ៍ប្រកាសទាំងនោះចោល និងតម្រូវឲ្យអចិតិជនដាក់ពាក្យជាថ្មីឡើងវិញ តាមសេចក្តីណែនាំលេខ២៨ អយក.សណនចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៦។

៣.១.៩. ការកត់ត្រាចំណាយថវិកាខុសមាតិកាថវិកា

ដើម្បីផ្តល់ព័ត៌មានត្រឹមត្រូវដល់អ្នកប្រើប្រាស់របាយការណ៍ស្តីពីការចំណាយថវិការដ្ឋ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ១៨៩ សហវ.ប្រក ចុះថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិ បានណែនាំអំពីការកត់ត្រាមាតិកាចំណាយថវិកាក្នុងជំពូក៦១ (អនុគណនី៦១០៥២) បានបញ្ជាក់អំពីការកត់ត្រារាល់ការចំណាយលើការថែទាំ និងជួសជុលអគារ ដូចជាលើការងារលាបថ្នាំ ការរៀបចំបណ្តាញឡើងវិញដែលបណ្តាលមកពីការជួសជុលអគារ និងការជួសជុលរបងអគារ។ រីឯជំពូក២១ (អនុគណនី២១០៣១ និង ២១០៣២) បានបញ្ជាក់អំពីការកត់ត្រារាល់ការចំណាយលើការសាងសង់អគាររដ្ឋបាលសម្រាប់បម្រើការងាររដ្ឋាភិបាល និងការចំណាយលើការរៀបចំកែលម្អអគារក្នុងទ្រុងទ្រាយធំ។ តាមការធ្វើសវនកម្មលើរបាយការណ៍សម្រេចទូទាត់ថវិកាទូទៅរបស់ក្រសួងមួយសម្រាប់ឆ្នាំ ២០១៥ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់ធានាចំណាយ ព្រមទាំងទូទាត់ឱ្យក្រសួងនោះនូវការសាងសង់អគារដោយប្រើប្រាស់ថវិកាជំពូក៦១ ជំនួសឱ្យថវិកាជំពូក២១ ដែលមានទឹកប្រាក់សរុបចំនួន ២៥ ០០៨ ៨១១ ១០០រៀល។

ដោយសារក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់ធានាចំណាយ និងយល់ព្រមទូទាត់ឱ្យក្រសួងសាមីធ្វើឱ្យការកត់ត្រាតួលេខចំណាយមិនត្រឹមត្រូវតាមមាតិកាចំណាយថវិកា និងផ្តល់ព័ត៌មានមិនត្រឹមត្រូវដល់អ្នកប្រើប្រាស់របាយការណ៍។ ជាងនេះទៀត វានាំឱ្យការអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិមិនបានគ្រប់ជ្រុងជ្រោយ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងសាមីគួររៀបចំផែនការថវិកាឱ្យបានត្រឹមត្រូវតាមមាតិកាថវិកា។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងបានបំភ្លឺថា ឥណទានថវិកាប្រចាំឆ្នាំ ២០១៥ ជាពិសេសចំណាយមិនមែនបន្ទុកបុគ្គលិកត្រូវបានគ្រោង និងអនុម័តដោយឈរលើមូលដ្ឋានពិដានកញ្ចប់ថវិកាចំណាយមិនមែនបន្ទុកបុគ្គលិកឆ្នាំ២០១៤ ដើម្បីធានាកុំឱ្យគម្រោងថវិកាវិស័យអាទិភាពធ្លាក់ចុះ។ ហេតុនេះហើយ ទំហំថវិកាដែលបានសន្សំពីការបង្កើនប្រសិទ្ធភាពចំណាយក្នុងឆ្នាំ២០១៤ ត្រូវបានវិភាជន៍ផ្តល់ជូនក្រសួងនោះវិញជាការលើកទឹកចិត្ត ដើម្បីបន្តពង្រឹងការបង្កើនប្រសិទ្ធភាពចំណាយថែមទៀតផង និងដើម្បីឆ្លើយតបទៅនឹងតម្រូវការ

ចាំបាច់ និងបន្ទាន់របស់ក្រសួងសាមីក្នុងឆ្នាំ២០១៥ផង ដែលរួមមានតម្រូវការសាងសង់អគារ ជាបន្ទាន់សម្រាប់បម្រើសេវាសាធារណៈ។ សមិទ្ធផលទាំងនេះគឺពិតជាបានឆ្លើយតបពិត ប្រាកដទៅនឹងតម្រូវការរបស់ប្រជាជន ដែលមកទទួលយកសេវាសាធារណៈនៅតំបន់ទាំង នោះបានល្អប្រសើរប្រកបដោយប្រសិទ្ធភាព។ លើសពីនេះ ក្នុងក្របខណ្ឌនៃការដាក់អនុវត្ត ថវិកាកម្មវិធីពេញលេញជាលើកទី១ នៅឆ្នាំ២០១៥ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនាម រាជរដ្ឋាភិបាលត្រូវផ្តល់ថវិកាក្នុងកម្រិតមួយធានាមិនឱ្យកញ្ចប់ចំណាយវិស័យអាទិភាពមាន ការធ្លាក់ចុះនោះទេ។

ការប្រើប្រាស់ថវិកា និងការកត់ត្រាការអនុវត្តថវិកាគួរមានការទទួលខុសត្រូវ និង មានតម្លាភាព អាជ្ញាធរសវនកម្មជាតិសូមលើកទឹកចិត្តឱ្យមានការគ្រោងផែនការថវិកាឱ្យបាន ច្បាស់លាស់ និងកត់ត្រាការអនុវត្តថវិកាឱ្យបានត្រឹមត្រូវតាមមាតិកាថវិកា។

៣.១.១០. ការយកថវិកាឆ្នាំ២០១៥ទៅធ្វើការទូទាត់ចំណាយឆ្នាំ២០១៤

ដើម្បីពង្រឹងយន្តការចំណាយ និងទូទាត់ចំណាយឱ្យស្របតាមឆ្នាំនៃថវិកា រាជរដ្ឋាភិបាលបានណែនាំដល់គ្រប់ក្រសួងស្ថាប័នឱ្យអនុវត្តការចំណាយស្របទៅតាមច្បាប់ និងសារាចរណែនាំផ្សេងៗ ដូចជា ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨ ត្រង់មាត្រា១ បានចែងថា "ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ និងសារាចរណែនាំលេខ០១៤ សហវ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការបិទបញ្ជីចំណូលចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៥ ត្រង់ចំណុចI.គ ត្រេ ទី១ បានចែងថា "ក្នុងរយៈពេលពីថ្ងៃទី១១ ដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ រដ្ឋទេយ្យករបុរេ ប្រទានត្រូវរួតរះប្រមូលសក្តីប័ត្រ និងលិខិតយុត្តិការចំណាយ ដើម្បីបោះផ្សាយអាណត្តិនិយ័ត កម្មឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រួចបញ្ជូនទៅរតនាគារថ្នាក់កណ្តាលយ៉ាងយូរ បំផុតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៦ ឬរតនាគារថ្នាក់មូលដ្ឋានយ៉ាងយូរបំផុតត្រឹម ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ជាកំហិត... និងចំណុចត្រេទី៣ ការទូទាត់ថ្លៃសេវាប្រើប្រាស់រថយន្តប្រណិត ជូនក្រុមហ៊ុន Royal Cambodia Limousine Service Co,Ltd ក្រសួងស្ថាប័ន និងអង្គភាពរដ្ឋបាល ថ្នាក់កណ្តាលត្រូវរួតរះបោះផ្សាយអាណត្តិនិយ័តកម្មឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានគណនេយ្យ និងហិរញ្ញវត្ថុរបស់ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានយកថវិកាឆ្នាំ២០១៥ មួយចំនួនតូចទៅធ្វើការទូទាត់ ចំណាយលើថ្លៃជួលរថយន្ត និងថវិកាមួយចំនួនតូចផ្សេងទៀត ទៅធ្វើការទូទាត់ចំណាយ ប្រាក់បៃសកកម្មឆ្នាំ២០១៤។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួរធ្វើការចំណាយថវិកាឆ្លុះបញ្ចាំងក្នុងឆ្នាំថវិកា។

ឆ្លើយតបនឹងករណីនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈសូមធ្វើការបញ្ជាក់ថា ដោយថវិកាបៃសកកម្មក្នុងប្រទេស និងក្រៅប្រទេសឆ្នាំ២០១៤ ពុំអាចធានាចំណាយបាន សម្រាប់ការងារបៃសកកម្មក្នុង និងក្រៅប្រទេស ម្យ៉ាងដោយយោងលើអនុក្រឹត្យលេខ២១៦

អនក្រ.បក ចុះថ្ងៃទី២២ ខែកក្កដា ឆ្នាំ២០១៤ និងប្រកាសលេខ១៥៨៩ សហវ.ហក ចុះថ្ងៃទី ០៩ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុអនុញ្ញាតឱ្យគ្រប់ក្រសួង ស្ថាប័ន ប្រមូលឯកសារដែលនៅសេសសល់ឆ្នាំចាស់មកធ្វើការទូទាត់ឱ្យបានយូរបំផុតត្រឹមត្រីមាស ទី១ នៃឆ្នាំបន្ទាប់។

៣.១.១១. ការចំណាយថវិកាកម្មវិធីពុំស្របទៅនឹងកម្មវិធីសកម្មភាពប្រចាំឆ្នាំ

ក្នុងការពង្រឹងការអនុវត្តនីតិវិធីចំណាយថវិកាតាមកម្មវិធីឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ១៩១១ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ ស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ត្រង់ចំណុច៤ ចំណុចគ ត្រែទី២ បានកំណត់ពី "ការរៀបចំ របាយការណ៍ស្តីពីការអនុវត្តថវិកា និងលទ្ធផលសកម្មភាពការងាររបស់ខ្លួនស្របតាមការ ណែនាំរបស់អង្គភាពទទួលបន្ទុកហិរញ្ញវត្ថុ ក្រុមការងារថវិកា ក្នុងក្របខ័ណ្ឌនៃបទប្បញ្ញត្តិ និង នីតិវិធីហិរញ្ញវត្ថុជាធរមាន" និងគម្រោងផែនការថវិកាកម្មវិធីឆ្នាំ២០១៥ តាមកម្មវិធី អនុកម្ម វិធី និងសកម្មភាពសម្រាប់ថ្នាក់រដ្ឋបាលកណ្តាលនៃក្រសួងអប់រំ យុវជន និងកីឡា រួមមានការ អភិវឌ្ឍន៍ការអប់រំក្រៅប្រព័ន្ធ និងមិនផ្លូវការ ការអភិវឌ្ឍន៍ឧត្តមសិក្សា និងការស្រាវជ្រាវការ អភិវឌ្ឍន៍វិស័យអប់រំកាយ និងកីឡា ការអភិវឌ្ឍន៍ជំនាញបច្ចេកទេស និងជំនាញទន់សម្រាប់ យុវជន និងការគាំទ្រសេវាអប់រំ និងអភិបាលកិច្ចល្អ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៥ នាយកដ្ឋានហិរញ្ញវត្ថុបាន អនុវត្តចំណាយសរុបចំនួន៩ ៥៥៨ ២១៩ ៣៧០រៀល ដែលត្រូវអនុវត្តចំនួន០៥ចង្កោម សកម្មភាព រួមមាន កិច្ចដំណើរការអង្គភាព ការពង្រឹងសមត្ថភាព និងកិច្ចប្រជុំ ទឹ្រព្យសម្ភារ សម្ភារបរិក្ខារ និងការបោះពុម្ព ការងារសង្គមកិច្ច និងការចំណាយឥតគ្រោងទុក និងការពិនិត្យ តាមដាន។ ប៉ុន្តែជាក់ស្តែងនាយដ្ឋានហិរញ្ញវត្ថុមិនបានធ្វើការកត់ត្រា និងបូកសរុបរបាយការណ៍ ចំណាយទាំងនោះទៅតាមកម្មវិធី អនុកម្មវិធី និងសកម្មភាពសម្រាប់ថ្នាក់រដ្ឋបាលកណ្តាល នោះទេ។ ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការអនុវត្តចំណាយថវិកាកម្មវិធីឱ្យស្របទៅតាម កម្មវិធី និងឆ្លើយតបទៅនឹងសូចនាករនៃការអនុវត្តថវិកាកម្មវិធីប្រចាំឆ្នាំ។

ឆ្លើយតបទៅនឹងករណីនេះ ក្រសួងបានធ្វើការបំភ្លឺថា ជាការពិត នាយកដ្ឋាន ហិរញ្ញវត្ថុដែលជាសេនាធិការឲ្យក្រសួងអប់រំ យុវជន និងកីឡា ហើយការកត់ត្រា និងបូក សរុបរបាយការណ៍ចំណាយទាំងនោះទៅតាមកម្មវិធី អនុកម្មវិធី និងសកម្មភាពសម្រាប់ថ្នាក់ រដ្ឋបាលកណ្តាលមិនបានឆ្លើយតប ដោយហេតុថា៖

១. ក្រសួងអប់រំ យុវជន និងកីឡាអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញក្នុងឆ្នាំ ២០១៥ ដែលជាឆ្នាំដំបូង ហើយការអនុវត្តជួបប្រទះនូវបញ្ហាប្រឈមជាច្រើន ដោយ ក្រសួងអប់រំ យុវជន និងកីឡាពុំទាន់មានគោលការណ៍អនុវត្តថ្មី។

២. តាមសារាចរណែនាំលេខ០១៤ សហវ ចុះថ្ងៃទី ១៣ ខែ វិច្ឆិកា ឆ្នាំ២០១៥ ស្តីពី ការបិទបញ្ជីចំណូលចំណាយថវិកា និងការធ្វើរបាយការណ៍ហូកសរុបការអនុវត្តចំណូល ចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៥ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពុំបានណែនាំឱ្យទៅ តាមកម្មវិធី អនុកម្មវិធី និងសកម្មភាព។ ដូចនេះ ក្រសួងអប់រំ យុវជន និងកីឡាបានអនុវត្ត តាមស្មារតីនៃសារាចរណែនាំខាងលើ។

៣.១.១២. ការបំបែកប័ណ្ណចំណាយដើម្បីគេចវេសពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ

ដើម្បីពង្រឹងការអនុវត្តចំណាយឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុបានចេញប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ របស់ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋ បាលថ្នាក់ជាតិ ត្រង់ប្រការ១៧ វាក្យខណ្ឌ៣ បានចែងថា "រដ្ឋទេយ្យបុរេប្រទានត្រូវជៀសវាង ដាច់ខាតនូវការបំបែកប័ណ្ណចំណាយទៅតាមទឹកន្លែង ឬគោលដៅចំណាយ ពេលវេលា ទឹក ប្រាក់ចំណាយ និងសមាសធាតុនៃមុខសញ្ញាចំណាយ ក្នុងគោលដៅគេចវេសការអនុវត្តនីតិ វិធីលទ្ធកម្មសាធារណៈ" និងប្រកាសអន្តរក្រសួងលេខ៥០៨សហវ.ប្រក ចុះថ្ងៃទី២០ ខែឧសភា ឆ្នាំ២០១៣ ស្តីពីគោលការណ៍ចំណាយសម្រាប់អនុវត្តថវិកាកម្មវិធីនៅក្រសួងអប់រំ យុវជន និងកីឡា ត្រង់ប្រការ៣ ចំណុចត្រែទី២ បានចែងថា "រាល់ការចំណាយថវិកាដែលពាក់ព័ន្ធ ទៅនឹងការទិញ ការជួសជុល ឬសេវាផ្សេងៗ ដែលមានទឹកប្រាក់ក្រោម២០លានរៀលត្រូវ អនុវត្តតាមលំនាំនីតិវិធីសាស្ត្រលទ្ធកម្មស្នង់តម្លៃ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិការបស់នាយកដ្ឋានហិរញ្ញវត្ថុ និងអង្គភាពថវិការបស់មជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា និងមន្ទីរអប់រំ យុវជន និងកីឡាខេត្ត សៀមរាប បានធ្វើការបំបែកប័ណ្ណចំណាយថវិការដ្ឋទេយ្យបុរេប្រទាន ដើម្បីគេចវេសពីការអនុ វត្តនីតិវិធីលទ្ធកម្មសាធារណៈ ទៅលើការជួសជុលរថយន្ត អគារសាលារៀននៅរដ្ឋបាល កណ្តាល និងតាមបណ្តាខេត្ត ទិញសម្ភារការិយាល័យ និងសម្ភារកីឡា មានដូចខាងក្រោម៖

នាយកដ្ឋានហិរញ្ញវត្ថុមានទឹកប្រាក់ចំនួន៥២៨ ៦៧៦ ៥០០រៀល ក្នុងនោះជួស ជុលរថយន្តចំនួន៩ ៦០០ ០០០រៀល ជួសជុលអគារសាលារៀនតាមបណ្តាខេត្តចំនួន ២៦៨ ៩១២ ៥០០រៀល និងទិញសម្ភារការិយាល័យចំនួន២៥១ ១៦៤ ០០០រៀល មជ្ឈមណ្ឌល ជាតិហ្វឹកហ្វឺនកីឡាមានទឹកប្រាក់ចំនួន៦២ ៩៩៩ ៨០០រៀល មន្ទីរអប់រំ យុវជន និងកីឡាខេត្ត សៀមរាបមានទឹកប្រាក់ចំនួន៣២ ៤៦៤ ៩០០រៀល។

ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការអនុវត្តចំណាយថវិការដ្ឋទេយ្យបុរេប្រទាន កម្មវិធីឱ្យបានត្រឹមត្រូវទៅតាមខ្លឹមសារនៃប្រកាសខាងលើ។

ឆ្លើយតបទៅនឹងករណីនេះ ក្រសួងអប់រំ យុវជន និងកីឡាបានធ្វើការបំភ្លឺ និង ទទួលស្គាល់ថា ដោយសារមានតម្រូវការចាំបាច់ និងបន្ទាន់ដើម្បីចូលរួមដោះស្រាយជូន ថ្នាក់ដឹកនាំក្រសួង ក្នុងការងារប្រចាំថ្ងៃ និងការកែទម្រង់វិស័យអប់រំ ក្នុងន័យនេះនាយកដ្ឋាន

ហិរញ្ញវត្ថុបានចូលរួមសម្របសម្រួលការងារចាំបាច់ខាងលើ រីឯការជួសជុលអគារសាលារៀនតាមបណ្តាខេត្តដោយមានតម្រូវការក្នុងការរៀបចំទទួលព្រះរាជដំណើរទស្សនកិច្ចរបស់ព្រះអង្គម្ចាស់ក្សត្រិយមហាចក្រីសិរិនថន នៅសាលាគោលដៅទាំងបួន (វិទ្យាស្ថានបច្ចេកវិទ្យាស្រុកថ្ពងខេត្តកំពង់ស្ពឺ វិទ្យាស្ថានបច្ចេកវិទ្យាកំពង់ឈើទាលស្រុកប្រាសាទសម្បូរណ៍ ខេត្តកំពង់ធំ សាលាបឋមសិក្សាហ៊ុនសែនតំបែរខេត្តត្បូងឃ្មុំ និងសាលាបឋមសិក្សាពន្លៃ ខេត្តព្រៃវែង) ហើយនាយកដ្ឋានសំណង់ និងមន្ទីរអប់រំ យុវជន និងកីឡាមិនមានឥណទាន ដូចនេះ នាយកដ្ឋានហិរញ្ញវត្ថុ ចាំបាច់ត្រូវដោះស្រាយបញ្ហានេះជាបន្ទាន់ក្នុងការកែលម្អបរិស្ថានឱ្យបានសមស្រប និងមានសោភ័ណភាព។ ម្យ៉ាងទៀត ដោយមានអង្គភាពចំនួន០៥ ក្រោមការគ្រប់គ្រងរបស់អង្គភាពថវិកាហិរញ្ញវត្ថុ តម្រូវឱ្យមានការទិញសម្ភារការិយាល័យសម្រាប់ប្រើប្រាស់ក្នុងកិច្ចដំណើរការរបស់អង្គភាពជាបន្តបន្ទាប់ដែលជាហេតុធ្វើឱ្យអង្គភាពថវិកាហិរញ្ញវត្ថុមិនអាចប្រមូលផ្តុំធ្វើកិច្ចលទ្ធកម្មបាន។

ដោយមានតម្រូវការចាំបាច់ និងបន្ទាន់ ដើម្បីការចូលរួមចំណែកកែទម្រង់វិស័យកីឡាទាមទារឲ្យអង្គភាពថវិកាមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា បានអនុវត្តការចំណាយផ្អែកលើពីរចំណុច៖

១. ការអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញក្នុងឆ្នាំ២០១៥ គឺជាឆ្នាំដំបូង ហើយការអនុវត្តជួបប្រទះនូវបញ្ហាប្រឈមជាច្រើនដែលពាក់ព័ន្ធនឹងការអនុវត្តថវិកា។

២. តម្រូវឲ្យមានការទិញសម្ភារកីឡាសម្រាប់ប្រើប្រាស់ក្នុងការប្រមូលផ្តុំការហ្វឹកហាត់ និងការប្រកួតរបស់ក្រុមជម្រើសជាតិដែលត្រូវប្រើប្រាស់នៅដើមឆ្នាំ ហើយជាការងារចាំបាច់ និងបន្ទាន់សម្រាប់ការប្រមូលផ្តុំកីឡាករ កីឡាការិនី គ្រូបង្វឹក និងអនុរក្សជាប្រចាំជាហេតុធ្វើឱ្យអង្គភាពមជ្ឈមណ្ឌលជាតិហ្វឹកហ្វឺនកីឡា មិនអាចរង់ចាំប្រមូលផ្តុំធ្វើកិច្ចលទ្ធកម្មសាធារណៈបាន។

– ជាក់ស្តែង មន្ទីរអប់រំ យុវជន និងកីឡាខេត្តសៀមរាបមិនបានបំបែកសក្តីប័ត្រចំណាយក្នុងការទិញសម្ភារការិយាល័យនោះទេ ដោយអង្គភាពថវិកាមានតែមួយ ហើយអង្គភាពក្រោមឱវាទមានចំនួនច្រើន ដូចជាការិយាល័យអប់រំក្រុង ស្រុកចំនួន១២ ការិយាល័យក្រោមចំណុះមន្ទីរមានចំនួន១១ សាលាគរុកោសល្យ និងវិក្រឹត្យការចំនួន០១ អគារធនធានវិទ្យាល័យក្រឡាញ់ និងវិទ្យាល័យអង្គរដោយអនុវត្តតាមនីតិវិធីរដ្ឋទេយ្យបុរេប្រទាន។ ទន្ទឹមនឹងនេះ ចាប់ពីឆ្នាំ២០១៧តទៅ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតម្រូវឱ្យក្រសួងអប់រំ យុវជន និងកីឡា រៀបចំប្រកាសអន្តរក្រសួងដោយឡែកពាក់ព័ន្ធនឹងនីតិវិធីអនុវត្តថវិកានៅតាមការិយាល័យអប់រំក្រុង ស្រុក ខណ្ឌ និងសាលាគរុកោសល្យ និងវិក្រឹត្យការតាមលិខិតលេខ ៧៧៧៨ សហវ.អថ ចុះថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ជាហេតុធ្វើឱ្យអង្គភាពក្រោមចំណុះនៅសល់មានចំនួនតិច។

៣.១.១៣. ការអនុវត្តចំណាយខុសទៅនឹងអនុកម្មវិធី និងចង្កោមសកម្មភាពប្រចាំឆ្នាំ

ដើម្បីពង្រឹងយន្តការលើការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងការអនុវត្តចំណាយថវិកាឱ្យឆ្លើយតបទៅនឹងបរិបថការងារ រាជរដ្ឋាភិបាលបានចេញនូវអនុក្រឹត្យលេខ

៤២៦ អនក្រ.បក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងដាក់ឱ្យអនុវត្តអង្គភាពថវិកា ត្រង់មាត្រា១ បានចែងថា "អង្គភាពថវិកាគឺជាអង្គភាពដែលត្រូវបានទទួលអាណត្តិកិច្ចច្បាស់លាស់ក្នុងការអនុវត្តសកម្មភាពការងារ ដើម្បីបង្កើតបានលទ្ធផលជាក់លាក់ និងអាចវាស់វែងបាន និងរួមចំណែកក្នុងការសម្រេចគោលបំណង គោលនយោបាយអាទិភាពរបស់ក្រសួងស្ថាប័ន" និងគម្រោងចំណាយថវិកាកម្មវិធីឆ្នាំ២០១៥ទៅតាមកម្មវិធី អនុកម្មវិធី និងសកម្មភាពសម្រាប់រដ្ឋបាលកណ្តាលនៃអង្គភាពថវិកា នាយកដ្ឋានហិរញ្ញវត្ថុត្រូវអនុវត្តកម្មវិធីទី៥ អនុកម្មវិធី៥.៣ ការអភិវឌ្ឍន៍សមត្ថភាព ផែនការហិរញ្ញវត្ថុ និងមូលដ្ឋានសម្ភារ និងមាន០៥ចង្កោមសកម្មភាព រួមមានកិច្ចដំណើរការអង្គភាព ការពង្រឹងសមត្ថភាព និងកិច្ចប្រជុំ ទព្វសម្ភារ សម្ភារបរិក្ខារ និងការបោះពុម្ព ការងារសង្គមកិច្ច និងការចំណាយឥតគ្រោងទុក និងការពិនិត្យតាមដាន។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានហិរញ្ញវត្ថុបានយកថវិកាចំណាយកម្មវិធីឆ្នាំ២០១៥មួយចំនួន ទៅធ្វើការចំណាយផ្ទុយទៅនឹងកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពប្រចាំឆ្នាំ ដោយនាយដ្ឋានហិរញ្ញវត្ថុបានយកថវិកាចំណាយខាងលើទៅធ្វើការចំណាយជួសឱ្យកម្មវិធី អនុកម្មវិធី និងចង្កោមសកម្មភាពរបស់អង្គភាពថវិកានាយកដ្ឋានសំណង់ នាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ាន។

ក្រសួងអប់រំ យុវជន និងកីឡា គួរធ្វើការអនុវត្តថវិកាកម្មវិធីឱ្យស្របតាមកម្មវិធីសកម្មភាពប្រចាំឆ្នាំ។

ឆ្លើយតបនឹងករណីនេះ ក្រសួងបានធ្វើការបញ្ជាក់ថា ជាការពិត ដោយអង្គភាពថវិកានាយកដ្ឋានសំណង់ នាយកដ្ឋានរដ្ឋបាល និងនាយកដ្ឋានព័ត៌មាន និងកិច្ចការអាស៊ានបានអនុវត្តថវិកាកម្មវិធីសាកល្បងពេញលេញក្នុងឆ្នាំ២០១៥ ដូចនេះការគ្រោងថវិកាប្រចាំឆ្នាំរបស់អង្គភាពមួយចំនួននៅជួបបញ្ហាប្រឈម រីឯអង្គភាពថវិកានាយកដ្ឋានហិរញ្ញវត្ថុមានតួនាទីជាអ្នកគាំទ្រ និងសម្របសម្រួលជាមួយអង្គភាពថវិកាក្រោមឱវាទក្រសួង ហេតុនេះទើបនាយកដ្ឋានហិរញ្ញវត្ថុជាអ្នកទទួលបន្ទុកលើការអនុវត្តថវិកាជំនួសអង្គភាពខាងលើ ។

៣.១.១៤. ការអនុវត្តចំណាយមុនការសម្រេច និងឯកភាពពីប្រធានអង្គភាពថវិកា

ក្នុងការពង្រឹងយន្តការចំណាយថវិការដ្ឋទេយ្យបុរេប្រទានឱ្យមានភាពត្រឹមត្រូវ និងស្របតាមនីតិវិធីចំណាយរដ្ឋទេយ្យបុរេប្រទាន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញនូវប្រកាសលេខ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់ផ្នែកទី២ ប្រការ១៥ បានចែងថា "ជាគោលការណ៍ រដ្ឋទេយ្យបុរេប្រទានត្រូវចំណាយជាសាច់ប្រាក់ ដោយមានសក្តីប័ត្របញ្ជាក់ត្រឹមត្រូវ។ មុននឹងធ្វើការចំណាយជាសាច់ប្រាក់ រដ្ឋទេយ្យករបុរេប្រទានត្រូវស្នើសុំគោលការណ៍ចំណាយទៅអាណាប័ក ឬអ្នកដែលទទួលបានការផ្ទេរសិទ្ធិពីអាណាប័ក។ ក្រោយពីទទួលបានគោលការណ៍ចំណាយ រដ្ឋទេយ្យករបុរេប្រទានត្រូវអនុវត្តការទូទាត់ចំណាយ ដោយតម្រូវឱ្យអ្នកទទួលប្រាក់ចុះហត្ថលេខាបញ្ជាក់អំពីការបានទទួលប្រាក់គ្រប់ចំនួនលើសក្តីប័ត្រ"។ អាជ្ញាធរ

សវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែង បានយកថវិកាចំណាយមួយចំនួនទៅធ្វើការចំណាយមុនធ្វើការស្នើសុំការឯកភាព និងសម្រេចពីប្រធានអង្គភាពថវិកា។

ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការចំណាយឱ្យបានត្រឹមត្រូវ និងមានតម្លាភាព។

ផ្អែកលើករណីនេះ ក្រសួងបានធ្វើការបញ្ជាក់ថា ដោយសារការអនុវត្តនីតិវិធីហិរញ្ញវត្ថុ២០១៥ថ្មី ព្រមទាំងការយល់ដឹងរបស់រដ្ឋទេយ្យករបុរេប្រទាននៅមានកម្រិត ហេតុដូចនេះទើបអង្គភាពថវិកានាយកដ្ឋានអប់រំកាយ និងកីឡាសិស្ស និស្សិត និងមន្ទីរអប់រំ យុវជន និងកីឡាខេត្តព្រៃវែងបានចំណាយសាច់ប្រាក់មុនធ្វើការស្នើសុំការឯកភាព និងសម្រេចពីប្រធានអង្គភាពថវិកា ដើម្បីអនុវត្តសកម្មភាពឲ្យទាន់ពេលវេលា និងស្របជាមួយសូចនាករដែលបានកំណត់។ ក្រសួងអប់រំ យុវជន និងកីឡា នឹងពង្រឹងការអនុវត្តថវិកាឲ្យបានត្រឹមត្រូវ និងតម្លាភាពឲ្យស្របនឹងស្មារតីនៃប្រកាសលេខ៨២៩ សហវ.ប្រក ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ២០១៥ ស្តីពីការកែសម្រួលប្រការ៤ ប្រការ៥ ប្រការ១៤ ប្រការ១៦ និងប្រការ១៧ នៃប្រកាសលេខ១៩៣៧ សហវ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយរដ្ឋទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

៣.១.១៥. ការយកចំណាយថវិកាបុរេប្រទានឆ្នាំ២០១៥ទៅធ្វើការទូទាត់ក្នុងឆ្នាំ២០១៦

ដើម្បីពង្រឹងការចំណាយថវិការដ្ឋឱ្យស្របនិងត្រឹមត្រូវ និងស្របតាមគោលការណ៍ហិរញ្ញវត្ថុ និងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលបានណែនាំការអនុវត្តដល់គ្រប់ក្រសួងស្ថាប័នទាំងអស់ឱ្យអនុវត្តការចំណាយស្របតាមច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រង់មាត្រា១១ បានចែងថា "ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ" និងសារាចរណែនាំលេខ០១៤ សហវ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ស្តីពីការបិទបញ្ជីចំណូលចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៥ ត្រង់ចំណុច I.គ ត្រែទីពីរ បានចែងថា "ការផ្តល់ថវិកាបុរេប្រទានត្រូវបញ្ឈប់នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ ២០១៥ ហើយការទូទាត់ប្រាក់បុរេប្រទាននេះក៏ត្រូវរួតរះប្រមូលឯកសារសុំទូទាត់ឱ្យបានមុនថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ដោយឡែកចំពោះថវិកាកម្មវិធីត្រូវរួតរះប្រមូលឯកសារទូទាត់ឱ្យបានមុនថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៦ជាកំហិត និងចំណុចទី៥ បានកំណត់ថា ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០១៦តទៅ រាល់កិច្ចប្រតិបត្តិការចំណូលចំណាយថវិកាថ្នាក់ជាតិឆ្នាំថ្មីត្រូវកត់ត្រាចូលក្នុងគណនីថ្នាក់ជាតិឆ្នាំ២០១៦" និងរបាយការណ៍កិច្ចប្រជុំស្តីពីសំណើសុំពន្យារពេលការបិទបញ្ជីចំណូលចំណាយថវិកាឆ្នាំ២០១៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ត្រង់ចំណុចគ បានចែងថា "មិនគួរអនុញ្ញាតឱ្យទូទាត់ចំណាយដែលអនុវត្តសកម្មភាពទាំងឡាយណាដែលអនុវត្តក្នុងឆ្នាំ២០១៦ទេ ពោលគឺគួរអនុញ្ញាតឱ្យរៀបចំឯកសារគតិយុត្តសម្រាប់ទូទាត់តែសកម្មភាពដែលបានអនុវត្តក្នុងឆ្នាំ២០១៥ ព្រោះយោងច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រង់មាត្រា១១ ចែងថា ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា

ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ។ ដូច្នេះ ក្រសួងអប់រំ យុវជន និងកីឡាមិនអាចប្រើប្រាស់ឥណទានថវិកាឆ្នាំ២០១៥ មកអនុវត្តសកម្មភាពក្នុងឆ្នាំ២០១៦បានទេ។ អាស្រ័យហេតុនេះ រាល់សក្ខីប័ត្រចំណាយទាំងអស់សម្រាប់យកមកទូទាត់បុរេប្រទានត្រូវមានកាលបរិច្ឆេទយ៉ាងយូរត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ទោះបីជាមានសកម្មភាពជាក់ស្តែងខ្លះត្រូវអនុវត្តបន្តរហូតដល់ខែមករា ឆ្នាំ២០១៦ក៏ដោយ។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពថវិកាមួយចំនួនរបស់ក្រសួងអប់រំ យុវជន និងកីឡា បានយកចំណាយថវិកាបុរេប្រទានក្នុងឆ្នាំ២០១៥មួយចំនួន ទៅធ្វើការទូទាត់ចំណាយសកម្មភាពមួយចំនួនក្នុងឆ្នាំ២០១៦។

ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការចំណាយថវិកាឱ្យ ស្របតាមឆ្នាំថវិកា និងឆ្លុះបញ្ចាំងក្នុងឆ្នាំថវិកា។

ឆ្លើយតបនឹងករណីនេះ ក្រសួងបានឯកភាពចំពោះការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ តែបានលើកឡើងថា ដោយការអនុវត្តថវិកាកម្មវិធីពេញលេញក្នុងឆ្នាំ២០១៥ របស់ក្រសួងអប់រំ យុវជន និងកីឡា ជួបនូវបញ្ហាប្រឈមជាច្រើន ធ្វើឱ្យការបោះផ្សាយអាណត្តិទូទាត់មានកម្រិតទាប មិនឆ្លើយតបនឹងចំណុចដៅជាក់ស្តែងគិតត្រឹមថ្ងៃទី០១ ខែធ្នូ ឆ្នាំ២០១៥ (រដ្ឋទេយ្យបុរេប្រទានចំនួន២៧.៦៦% បុរេប្រទានចំនួន២៩.០៥% និងទូទាត់ត្រង់ចំនួន ៣៩.៧៣%) ដូចនេះក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏បានអនុញ្ញាតជាគោលការណ៍ផ្តល់ថវិកាបុរេប្រទានចំនួន១៩ ០៨៥ ៩៧៦ ៣២៥រៀល តាមលិខិតលេខ១០០៦០សហវ.ហក ចុះថ្ងៃទី១៥ ខែធ្នូ ឆ្នាំ២០១៥ សម្រាប់អនុវត្តសកម្មភាពដែលនៅសេសសល់ត្រូវបញ្ចប់ក្នុងឆ្នាំ ២០១៥ ហើយបន្តចំណាយរហូតដល់បំណាច់ខែមករា ឆ្នាំ២០១៦ ក្នុងគោលដៅជួយជំរុញការទូទាត់ថវិកាឲ្យតាមសូចនាករដែលបានគ្រោងទុក។

៣.១.១៦. ការទូទាត់ចំណាយថវិកាកម្មវិធីពុំទាន់បានត្រឹមត្រូវ

ដើម្បីពង្រឹងការទូទាត់ចំណាយថវិកាកម្មវិធីឱ្យបានត្រឹមត្រូវ និងស្របតាមគោលការណ៍ហិរញ្ញវត្ថុ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០០៨ ត្រង់មាត្រា១១ បានចែងថា "ការិយបរិច្ឆេទនៃឆ្នាំថវិកាចាប់ផ្តើមនៅថ្ងៃទី០១ ខែមករា ហើយបញ្ចប់នៅថ្ងៃទី៣១ ខែធ្នូ" និងសារាចរណែនាំលេខ០១៤ សហវ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ ២០១៥ ស្តីពីការបិទបញ្ជីចំណូលចំណាយថវិកាថ្នាក់ជាតិឆ្នាំ២០១៥ ត្រង់ចំណុច៤.គ បានចែងថា "អំពីចំណាយរដ្ឋទេយ្យបុរេប្រទាន និងថវិកាបុរេប្រទានក្នុងរយៈពេលពីថ្ងៃទី១១ ដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០១៥ រដ្ឋទេយ្យករបុរេប្រទានត្រូវរួតរះប្រមូលសក្ខីប័ត្រ និងលិខិតយុត្តិការចំណាយដើម្បីបោះផ្សាយអាណត្តិនិយ័តកម្ម ឆ្លងទិដ្ឋាការពីមន្ត្រីត្រួតពិនិត្យហិរញ្ញវត្ថុ រួចបញ្ជូនមករតនាគារថ្នាក់កណ្តាលយ៉ាងយូរបំផុតត្រឹមថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៦..."។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានហិរញ្ញវត្ថុបានយកថវិកាចំណាយកម្មវិធីក្នុងឆ្នាំ ២០១៥មួយចំនួន ទៅធ្វើការទូទាត់ចំណាយឧបត្ថម្ភប្រាក់អាហារូបករណ៍ជូនសិស្ស និស្សិតទៅសិក្សាស្រាវជ្រាវនៅក្រៅប្រទេសក្នុងឆ្នាំ២០១៤ និងវិទ្យាស្ថានជាតិអប់រំបានយកថវិកាចំណាយ

កម្មវិធីក្នុងឆ្នាំ២០១៥មួយចំនួន ទៅធ្វើការទូទាត់ថ្លៃឧបត្ថម្ភអាហារូបករណ៍របស់គរុនិស្សិតក្នុងឆ្នាំសិក្សា២០១៣ និងឆ្នាំសិក្សា២០១៤។

ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការចំណាយឱ្យបានត្រឹមត្រូវទៅតាមឆ្នាំថវិកា ដើម្បីកុំឱ្យប៉ះពាល់ដល់ការរៀបចំសេចក្តីព្រាងច្បាប់ទូទាត់ថវិកាប្រចាំឆ្នាំ។

ឆ្លើយតបនឹងករណីនេះ ក្រសួងអប់រំ យុវជន និងកីឡាសូមឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ប៉ុន្តែបន្ទាប់ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានអនុញ្ញាតជាគោលការណ៍តាមលិខិតលេខ២៨៧ សហវ.ហក ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៥ ស្តីពីការបន្ថែមវិសាលភាពមួយចំនួន ដើម្បីអនុវត្តការចំណាយប្រាក់បេសកកម្មក្នុង និងក្រៅប្រទេសនៅក្រសួងអប់រំ យុវជន និងកីឡា ទើបនាយកដ្ឋានហិរញ្ញវត្ថុបានរៀបចំបោះផ្សាយអាណត្តិទូទាត់ប្រាក់បេសកកម្មក្រៅប្រទេសជូនដល់សិស្សនិស្សិតដែលបានបំពេញបេសកកម្មកាលពីឆ្នាំ២០១៤កន្លងមក ក្នុងគោលបំណងបញ្ចៀសវិវាទរវាងសិស្សនិស្សិតជាមួយក្រសួងអប់រំ យុវជន និងកីឡា។ តាមស្មារតីនៃអនុក្រឹត្យលេខ១៧៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៤ ស្តីពីអាហារូបករណ៍ឧបត្ថម្ភជីវភាពអន្តេវាសិកសម្រាប់សិស្សនិស្សិតសិក្សាតាមគ្រឹះស្ថានសាធារណៈ ត្រង់មាត្រា១១ បានចែងថា ចំពោះមន្ត្រីរាជការត្រូវបណ្តុះបណ្តាលចាប់ពី១២ខែឡើងទៅ មិនផ្តល់ប្រាក់ឧបត្ថម្ភជូនទេ ជាហេតុធ្វើឲ្យមន្ត្រីរាជការដែលកំពុងបណ្តុះបណ្តាលមានរយៈពេល១ឆ្នាំ គឺគ្រូកម្រិតឧត្តម (បរិញ្ញា+១) នៅវិទ្យាស្ថានជាតិអប់រំ មានប្រតិឃាតយ៉ាងខ្លាំងជាមួយក្រសួង ពីព្រោះធ្លាប់ទទួលបានប្រាក់ឧបត្ថម្ភ ហេតុនេះហើយទើបក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានជួយដោះស្រាយបញ្ហាប្រឈមតាមលិខិតលេខ ២៩៩០ សហវ.ហក ចុះថ្ងៃទី០៤ ខែឧសភា ឆ្នាំ២០១៥ ជូនដល់គ្រូឧត្តម (បរិញ្ញា+១)។

៣.១.១៧.ការចំណាយក្រោយកិច្ចប្រតិបត្តិការជាក់ស្តែង

ដើម្បីពង្រឹងយន្តការក្នុងការអនុវត្តចំណាយ ក៏ដូចជាថវិការជួទេយ្យបុរេប្រទានកម្មវិធីឱ្យកាន់តែមានប្រសិទ្ធភាព ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញនូវប្រកាសលេខ ១៩៣៧ សហវ.ប្រក ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៤ ស្តីពីនីតិវិធីចំណាយតាមរជ្ជទេយ្យបុរេប្រទានសម្រាប់រដ្ឋបាលថ្នាក់ជាតិ ត្រង់ប្រការ១១ ចែងថា "ក្នុងករណីដែលអាណាប័កពិនិត្យឃើញថា លិខិតយុត្តិការចំណាយមួយចំនួនពុំមានលក្ខណៈត្រឹមត្រូវទេ អាណាប័កត្រូវបញ្ជូនលិខិតយុត្តិការចំណាយនោះទៅរជ្ជទេយ្យករបុរេប្រទានវិញ ដើម្បីកែតម្រូវ"។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការិយាល័យរដ្ឋបាល បុគ្គលិក និងបណ្តុះបណ្តាលវិជ្ជាជីវៈនៃមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនៈគីរី បានយកថវិកាចំណាយរជ្ជទេយ្យបុរេប្រទានមួយចំនួនទៅធ្វើការចំណាយសម្រាប់ទិញសម្ភារ និងអាហារសម្រន់សម្រាប់ដំណើរការសន្និបាតក្រោយកិច្ចប្រតិបត្តិការជាក់ស្តែង(ក្រោយថ្ងៃសន្និបាត)។

ក្រសួងអប់រំ យុវជន និងកីឡាគួរធ្វើការចំណាយថវិកាឱ្យបានត្រឹមត្រូវ និងស្របទៅនឹងកម្មវិធីជាក់ស្តែង។

ផ្អែកលើករណីនេះ ក្រសួងអប់រំ យុវជន និងកីឡាបានឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ តែមន្ទីរអប់រំ យុវជន និងកីឡាខេត្តរតនៈគីរីបានចំណាយសម្រាប់ការទិញសម្ភារ និងអាហារសម្រន់ក្នុងកិច្ចដំណើរការរៀបចំសន្និបាតក្រោយកិច្ចប្រតិបត្តិការជាក់ស្តែង (ក្រោយថ្ងៃសន្និបាត)។ ដូចនេះ ក្រសួងនឹងពង្រឹងការអនុវត្តថវិកាឱ្យបានត្រឹមត្រូវជាក់លាក់ ព្រមទាំងស្របជាមួយកម្មវិធីសកម្មភាពជាក់ស្តែង និងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

៣.១.១៨.តម្លៃទំនិញក្នុងកិច្ចសន្យាមិនស្របតាមតម្លៃទីផ្សារ

ដើម្បីពង្រឹងលើតម្លៃសម្ភារបរិក្ខារដែលអនុវត្តទៅតាមនីតិវិធីលទ្ធកម្ម ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរធ្វើការចេញនូវតារាងតម្លៃឱ្យមានលក្ខណៈស្តង់ដារមួយសម្រាប់ដាក់ឱ្យក្រសួងស្ថាប័នយកទៅអនុវត្តលើតម្លៃសម្ភារបរិក្ខារដែលត្រូវអនុវត្តសម្រាប់កិច្ចលទ្ធកម្ម និងដើម្បីជៀសវាងតម្លៃក្នុងកិច្ចសន្យាលទ្ធកម្មមានតម្លៃខ្ពស់ជាងទីផ្សារ។ ជាក់ស្តែង អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពលទ្ធកម្មរបស់ក្រសួងអប់រំ យុវជន និងកីឡា បានអនុវត្តកិច្ចសន្យាផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសគ្រប់ប្រភេទទៅដល់អង្គភាពថវិកាមួយចំនួន។ ប៉ុន្តែតម្លៃទំនិញមួយចំនួននៅក្នុងកិច្ចសន្យាលើការផ្គត់ផ្គង់សម្ភារបរិក្ខារបច្ចេកទេសគ្រប់ប្រភេទ ដែលអង្គភាពលទ្ធកម្មរបស់ក្រសួង អប់រំ យុវជន និងកីឡាបានអនុវត្តនោះមានតម្លៃខ្ពស់ជាងតម្លៃទីផ្សារ។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរធ្វើការចេញនូវតារាងតម្លៃទំនិញសម្ភារបរិក្ខារសម្រាប់ដាក់ឱ្យក្រសួងស្ថាប័នអនុវត្ត ដើម្បីជៀសវាងតម្លៃទំនិញដែលមានក្នុងកិច្ចសន្យានៅតែខ្ពស់ជាងតម្លៃទីផ្សារ។ ទន្ទឹមគ្នានេះដែរ ក្រសួងអប់រំ យុវជន និងកីឡាគួរអនុវត្តតម្លៃទំនិញក្នុងកិច្ចសន្យាលទ្ធកម្មឱ្យស្របតាមតម្លៃទីផ្សារ។

ផ្អែកលើករណីនេះ ក្រសួងបានឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ប៉ុន្តែក្រសួងបានបញ្ជាក់ថា ករណីទំនិញចំនួន០៧មុខក្នុងចំណោម១៣៩មុខ ដែលបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុន ភី ស៊ី អេស ស៊ី ខនស្ត្រាក់សិន ហើយមានតម្លៃមិនសមស្របធៀបនឹងតម្លៃទីផ្សារ អង្គភាពលទ្ធកម្មសូមបញ្ជាក់ដូចខាងក្រោម ៖

១-ដើម្បីអាចឱ្យតម្លៃមានលក្ខណៈសមស្របតាមតម្លៃលក់ជាក់ស្តែងតាមទីផ្សារ លុះត្រាតែអង្គភាពថវិកានីមួយៗប្រើប្រាស់នីតិវិធីហិរញ្ញវត្ថុតាមរយៈបុរេប្រទាន ដើម្បីយកសាច់ប្រាក់កាន់ទៅទិញ និងទូទាត់ផ្ទាល់នៅលើទីផ្សារត្រង់តែម្តង ដោយពុំមានកិច្ចសន្យា និងមិនបាច់អនុវត្តនីតិវិធីលទ្ធកម្មឡើយ។ បើអនុវត្តតាមករណីនេះគឺមិនសមស្របតាមនីតិវិធីហិរញ្ញវត្ថុ។

២-ការអនុវត្តនីតិវិធីកិច្ចលទ្ធកម្ម ក្រុមហ៊ុនដែលទទួលបានកិច្ចសន្យាមានកាតព្វកិច្ចខុសពីក្រុមហ៊ុនដែលលក់ជាក់ស្តែងនៅលើទីផ្សារដូចខាងក្រោមៈ

– ក្រុមហ៊ុនដែលទទួលបានកិច្ចសន្យាលទ្ធកម្ម គឺត្រូវមានកាតព្វកិច្ចដូចជា ទី១.បង់ពន្ធអាករលើតម្លៃបន្ថែមចំនួន១០% នៃតម្លៃកិច្ចសន្យាសរុប ទី២.បង់ពន្ធអាករលើប្រាក់

ចំណេញចំនួន១%នៃតម្លៃកិច្ចសន្យាសរុប ទី៣.បង់ពន្ធអាករប្រថាប់ត្រា០.១% នៃកិច្ចសន្យាសរុប និងទី៤.បង់ប្រាក់កក់ធានាការអនុវត្តកិច្ចសន្យាចំនួន១០%នៅរតនាគារជាតិ

– ក្រុមហ៊ុនមានការចំណាយលើអត្រាការប្រាក់ក្នុងការទូទាត់កិច្ចសន្យាយូរ និងយឺតយ៉ាវ

– ក្រុមហ៊ុនត្រូវធ្វើការបូកបន្ថែមថ្លៃដឹកជញ្ជូនតាមលក្ខខណ្ឌនៃកិច្ចសន្យាលទ្ធកម្មនីមួយៗ

– ក្រុមហ៊ុនត្រូវទទួលខុសត្រូវក្រោយប្រគល់ទទួល ក្នុងការចំណាយលើការជួសជុល និងថែទាំរហូតផុតសុពលភាពនៃកិច្ចសន្យា។

៣.១.១៩. ការបង្វែរពីវិធីសាស្ត្រដេញថ្លៃសាធារណៈមកអនុវត្តវិធីសាស្ត្រចរចាថ្លៃ និងអង្គភាពទទួលការពុំទាន់មានការវាយតម្លៃពីចំណាត់ថ្នាក់ និងលក្ខណៈសម្បត្តិពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

ដើម្បីពង្រឹងការអនុវត្តកិច្ចលទ្ធកម្មឱ្យកាន់តែមានប្រសិទ្ធភាព និងមានតម្លាភាព ច្បាប់ស្តីពីលទ្ធកម្មសាធារណៈដែលប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខនស/រកម/០១១២/០០៤ ចុះថ្ងៃទី១៤ ខែមករា ឆ្នាំ២០១២ ត្រង់មាត្រា២៧ បានចែងថា អ្នកដេញថ្លៃត្រូវចុះបញ្ជីចំណាត់ថ្នាក់ប្រភេទ និងចំណាត់ថ្នាក់អ្នកដេញថ្លៃនៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីមានសិទ្ធិចូលរួមក្នុងកិច្ចលទ្ធកម្មសាធារណៈ។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុត្រូវធ្វើប្រភេទ និងចំណាត់ថ្នាក់អ្នកដេញថ្លៃតាមសមត្ថភាពរបស់អ្នកដេញថ្លៃ ដើម្បីធានាការអនុវត្តកិច្ចសន្យា និងប្រកាសលេខ៣៨១ សហវ.ប្រក ចុះថ្ងៃទី១៥ ខែមិថុនា ឆ្នាំ២០១០ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការដាក់ឱ្យប្រើសៀវភៅលទ្ធកម្ម ការអនុវត្តវិធាន និងបទប្បញ្ញត្តិលទ្ធកម្មសាធារណៈ ត្រង់ជំពូក៣.៤.១ បានចែងថា ការចុះកិច្ចសន្យាផ្ទាល់ត្រូវបានប្រើប្រាស់ក្នុងករណីពិសេសដូចខាងក្រោម:

– ឧបករណ៍ និងលក្ខខណ្ឌបច្ចេកទេសដែលត្រូវប្រើមានប្រភពតែមួយគត់

– ករណីចាំបាច់សម្រាប់ឆ្លើយតបនៅពេលមានគ្រោះមហន្តរាយធម្មជាតិកើតឡើង និងតម្រូវការចាំបាច់បន្ទាន់រយៈពេលខ្លីមិនអាចរងចាំឱ្យប្រើវិធីសាស្ត្រផ្សេងទៀតបាន

– សម្រាប់គោលបំណងសិក្សាស្រាវជ្រាវដកពិសោធន៍អភិវឌ្ឍន៍មកពីខ្វះអ្នកចូលរួមដេញថ្លៃ ឬពុំមានការឆ្លើយតបក្នុងការដេញថ្លៃ"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានសម្ភារ និងបរិក្ខារនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានអនុវត្តលទ្ធកម្មសំណង់មានចំនួន០៩គម្រោងមានទឹកប្រាក់ចំនួន ២ ៩៧៨ ៨១៩ ៥០០រៀល ដែលត្រូវអនុវត្តវិធីសាស្ត្រដេញថ្លៃជាសាធារណៈមានចំនួន០៧គម្រោង និងពិគ្រោះថ្លៃមានចំនួន០២គម្រោង។ ប៉ុន្តែជាក់ស្តែង នាយកដ្ឋានសម្ភារ និងបរិក្ខារបស់ក្រសួងបានអនុវត្តវិធីសាស្ត្រលទ្ធកម្មដេញថ្លៃជាសាធារណៈមកធ្វើការអនុវត្តវិធីសាស្ត្រចរចាថ្លៃផ្ទាល់ជាមួយនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណដែលជាអង្គភាពមួយស្ថិត

ក្រោមការគ្រប់គ្រងរបស់ក្រសួង។ ទន្ទឹមនឹងនោះ ក្រសួងក៏ពុំទាន់មានការកំណត់ចំណាត់ថ្នាក់ និងវាយតម្លៃពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពីលក្ខណៈសម្បត្តិ និងតួនាទីភារកិច្ចរបស់នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណក្នុងការទទួលបានកិច្ចសន្យាលើការជួសជុលរាល់សំណង់សិល្បៈបុរាណ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួរអនុវត្តកិច្ចលទ្ធកម្មឱ្យស្របតាមវិធីសាស្ត្រលទ្ធកម្មសាធារណៈ និងស្នើសុំគោលការណ៍ទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីកំណត់ពីលក្ខណៈសម្បត្តិ ចំណាត់ថ្នាក់ និងតួនាទីភារកិច្ចរបស់នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណលើការជួសជុល និងថែទាំរាល់សំណង់បុរាណទាំងអស់ឱ្យបានច្បាស់ និងត្រឹមត្រូវតាមនីតិវិធីលទ្ធកម្មសាធារណៈ។

ឆ្លើយតបនឹងការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានធ្វើការបញ្ជាក់ថា:

ក.លទ្ធកម្មសំណង់គឺ សំដៅទៅលើប្រាសាទ ស្ពានបុរាណ និងវត្ថុបុរាណជាដើម។ ដូច្នេះហើយពុំមានក្រុមហ៊ុន ឬបុគ្គលណាមួយហ៊ានចូលដេញថ្លៃ និងមកពិគ្រោះថ្លៃដែរ ទើបនាយកដ្ឋានសម្ភារ និងបរិក្ខារនៃក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ បានអនុវត្តវិធីសាស្ត្រចរចាថ្លៃផ្ទាល់ជាមួយនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណរហូតដល់បច្ចុប្បន្ន។ មូលហេតុដូចខាងក្រោម៖

– ការអភិរក្ស ឬជួសជុលប្រាសាទត្រូវមានជំនាញ ដូចជាស្ថាបត្យករ វិស្វករបុរាណវិទ្យ និងសូនរូបជាដើម ហើយជាអ្នកដែលមានពិសោធន៍ធ្វើការជាមួយនឹងការងារនេះជាយូរឆ្នាំ ពីព្រោះដើម្បីជួសជុលប្រាសាទបានត្រូវតែមានអ្នកជំនាញស្គាល់ថ្មប្រាសាទមួយដុំៗ ចេះរកផ្គុំថ្ម និងចេះរៀបថ្មចាស់របស់ប្រាសាទឱ្យមានរូបរាងដូចដើម។ ជាពិសេសទៀត អ្នកបច្ចេកទេសទាំងនោះត្រូវចេះច្បាប់ជួសជុលបេតិកភណ្ឌអន្តរជាតិមួយចំនួន ដូចជា Chart pour Angkor, Nara on authenticity និងយល់ដឹងខ្លះពី Chart d′athen, Chart de Venise ជាដើម។

– ជាមួយគ្នានោះ អ្នកជួសជុលត្រូវចេះសិក្សា និងយល់ច្បាស់ពីប្រវត្តិសាស្ត្ររបស់សំណង់នៅពេលប្រទះឃើញថ្ម ឬសម្ភារប្រាសាទ ដឹងពីកាលបរិច្ឆេទ និងអាចដឹងថាតើផ្នែកណានៃសំណង់សាងសង់មុន ឬសាងសង់ក្រោយ មិនត្រឹមតែប៉ុណ្ណោះអ្នកជួសជុលត្រូវចេះមើលវិភាគពីស្រទាប់ដីរបស់គ្រឹះ និងចេះដឹង និងស្គាល់ពីវត្ថុសិល្បៈដែលរកឃើញនៅក្នុងពេលអនុវត្តការងារទៀតផង។ អ្វីដែលសំខាន់នៅក្នុងការជួសជុលសំណង់បេតិកភណ្ឌគឺការសិក្សាស្រាវជ្រាវពីប្រវត្តិសាស្ត្រ លក្ខណៈបច្ចេកទេស លំនាំដើមនៃសំណង់ព្រោះការជួសជុលគឺជាការបំផ្លាញប្រវត្តិសាស្ត្រនៃសំណង់ ដូច្នេះទើបទាមទារឱ្យមានការសិក្សាស្រាវជ្រាវ ដើម្បីកត់ត្រាទុកជាឯកសារសម្រាប់មនុស្សជំនាន់ក្រោយ។

– យោងតាមអនុក្រឹត្យលេខ៨៩ អន.បក ស្តីពីការអនុវត្តកិច្ចការពារបេតិកភណ្ឌវប្បធម៌ ចុះថ្ងៃទី១៧ ខែកញ្ញា ឆ្នាំ២០០២ ជំពូក៤ ពីមាត្រា២៥ និយាយពីការធ្វើកំណាយ

បុរាណវិទ្យា ការពង្រឹងគ្រឹះ ការវិភាគបែបវិទ្យាសាស្ត្រ គឺត្រូវធ្វើដោយមន្ត្រីជំនាញដែលមានបទពិសោធន៍ និងមានការឯកភាពពីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។ ក្នុងករណីនេះ នាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណមានធនធានមនុស្សគ្រប់គ្រាន់សម្រាប់បំពេញការងារនេះ(បុរាណវិទ្យាចំនួន១០រូប ស្ថាបត្យករចំនួន១០រូប និងវិស្វករចំនួន១០រូប)។

ខ.លក្ខណៈសម្បត្តិនៃនាយកដ្ឋានគាំពារ និងអភិរក្សសំណង់បុរាណ៖ បុគ្គលិកភាគច្រើនជាអតីតមន្ត្រីនាយកដ្ឋានបេតិកភណ្ឌ ដែលមានស្នាក់ការធំនៅអភិរក្សដ្ឋានអង្គរ ខេត្តសៀមរាប។ មន្ត្រីទាំងនោះមានភារៈកិច្ចគ្រប់គ្រងប្រាសាទ និងវត្ថុបុរាណទូទាំងប្រទេស រួមទាំងប្រាសាទក្នុងតំបន់អង្គរ។ នៅពេលអង្គការផ្សេងៗមកជួសជុល និងអភិរក្សនៅក្នុងតំបន់អង្គរចាប់តាំងពីឆ្នាំ១៩៨០ ដល់ឆ្នាំ១៩៩៦ ហើយអង្គការមួយចំនួនបានបន្តធ្វើការរហូតមកដល់សព្វថ្ងៃនេះ។ ដំបូងអង្គការទាំងនោះបានសហការជាមួយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជាពិសេសនាយកដ្ឋានបេតិកភណ្ឌ (អភិរក្សអង្គរ) តែម្តង។ នៅពេលនោះហើយក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានបញ្ជូនមន្ត្រីអតីតនិស្សិតបុរាណវិទ្យា ស្ថាបត្យកម្ម ឱ្យទៅចូលរួមធ្វើការជាមួយបណ្តាអង្គការទាំងអស់នោះដូចមានរៀបរាប់ខាងក្រោម:

– ចាប់ពីឆ្នាំ១៩៩២ មន្ត្រីនាយកដ្ឋានចំនួន០២នាក់ បានចូលរួមធ្វើការជាមួយអង្គការមូលនិធិបេតិកភណ្ឌពិភពលោក(WMF) ប្រទេសអាមេរិកក្នុងការជួសជុលប្រាសាទព្រះខ័ន

– ចាប់ពីឆ្នាំ១៩៩២ នាយកដ្ឋានបានបញ្ជូនមន្ត្រីចំនួន០១នាក់ទៅចូលរួមធ្វើការជាមួយអង្គការសូហ្វីយ៉ា(SOPHIA) ប្រទេសជប៉ុនក្នុងការជួសជុលប្រាសាទបន្ទាយក្តី

– ចាប់ពីឆ្នាំ១៩៩៤ មន្ត្រីនាយកដ្ឋានចំនួន០៥នាក់បានចូលរួមធ្វើការជាមួយអង្គការ JSA នៃប្រទេសជប៉ុនក្នុងការជួសជុលប្រាសាទសូរព្រ៉ែត្រ បណ្ណាល័យខាងជើងប្រាសាទអង្គរវត្ត និងជួសជុលប្រាសាទបាយ័ន

– ចាប់ពីឆ្នាំ១៩៩៥ មន្ត្រីនាយកដ្ឋានចំនួន០១នាក់បានចូលរួមធ្វើការជាមួយអាល្លឺម៉ង់ ជួសជុលអប្សរអង្គរវត្ត(GACP)ប្រទេសអាល្លឺម៉ង់

– ចាប់ពីឆ្នាំ១៩៩៥ មន្ត្រីនាយកដ្ឋានចំនួន០៣នាក់បានចូលរួមធ្វើការជាមួយអង្គការ(I.Ge.S) ប្រទេសអ៊ីតាលី ក្នុងការជួសជុលកសិន្នុអង្គរវត្ត និងប្រាសាទប្រែរូប

– ចាប់ពីឆ្នាំ១៩៩៥ មន្ត្រីនាយកដ្ឋានចំនួន០៣នាក់បានចូលរួមធ្វើការជាមួយសាលាបារាំងចុងបូព៌ា(EFEO) ប្រទេសបារាំង ក្នុងការជួសជុលទីលានស្តេចគម្លង់

– ចាប់ពីឆ្នាំ២០០០ មន្ត្រីនាយកដ្ឋានចំនួន០១នាក់បានចូលរួមធ្វើការជាមួយអង្គការ CSI នៃប្រទេសចិន ក្នុងការជួសជុលប្រាសាទចៅសាយទេវតា។ សរុបមន្ត្រីនាយកដ្ឋានទាំងអស់ដែលបានចូលរួមធ្វើការជាមួយអង្គការអន្តរជាតិមានចំនួន២០នាក់។

៣.១.២០. ការបើកឯកសារដេញថ្លៃពុំទាន់បានត្រឹមត្រូវ

ក្នុងគោលបំណងអនុវត្តនីតិវិធីលទ្ធកម្មសាធារណៈឱ្យស្របទៅគោលការណ៍ និងនីតិវិធីលទ្ធកម្មសាធារណៈ រាជរដ្ឋាភិបាលបានចេញនូវអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ ត្រង់មាត្រា៣៤ បានចែងថា "គ្រប់

សំណើដេញថ្លៃ និងសំណើជ្រើសរើសទីប្រឹក្សាទាំងអស់ (ទាំងបច្ចេកទេស និងហិរញ្ញវត្ថុ) ត្រូវតែរៀបចំបើកជាសាធារណៈ ហើយកំណត់ហេតុត្រូវផ្តល់ឲ្យក្រុមហ៊ុន និងបុគ្គលដែលបានចូលរួមទាំងអស់។ កំណត់ហេតុត្រូវបិទប្រកាសលើបញ្ជរព័ត៌មាននៅស្ថាប័នអនុវត្តលទ្ធកម្ម ដែលសាធារណៈជនទូទៅអាចមើលឃើញ...។ កំណត់ហេតុថតចម្លងក៏អាចផ្តល់ឲ្យសាធារណៈជនណាដែលបានដាក់ពាក្យស្នើសុំ ″ ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងចំណោមកិច្ចសន្យាលទ្ធកម្ម២៥គម្រោង ដែលមានទឹកប្រាក់សរុប ៦ ៦៥២ ៥០០ ០០០រៀល មានកិច្ចសន្យាចំនួន០៤ គឺកិច្ចសន្យាជួសជុលកែលម្អអគារសារមន្ទីរខេត្តពោធិ៍សាត់ ជួសជុលកែលម្អអគារទីស្តីក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ ជួសជុលម៉ាស៊ីនត្រជាក់ និងតបណ្តាញផ្សេងៗ ទូទាត់ថ្លៃសង្ហារឹមប្រើប្រាស់ឆ្នាំ ២០១៥ និងទូទាត់ថ្លៃជួតផ្តង់សម្ភារឧបករណ៍បុរាណ ដែលមានទឹកប្រាក់សរុបចំនួន ១ ៥៩២ ៣៥២ ៥០០រៀល ដោយបានធ្វើការរៀបចំបើកឯកសារដេញថ្លៃគម្រោងលទ្ធកម្មទាំងបួនខាងលើចំពេលវេលា(ម៉ោង និងថ្ងៃ ខែ ឆ្នាំ) តែមួយ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួរធ្វើការបើកឯកសារដេញថ្លៃនូវរាល់គម្រោងលទ្ធកម្មឱ្យបានត្រឹមត្រូវ តម្លាភាព និងស្របតាមគោលការណ៍លទ្ធកម្ម សាធារណៈ។

ឆ្លើយតបនឹងករណីនេះ ក្រសួងបានធ្វើការបញ្ជាក់ថា ចំពោះគម្រោងចំនួន០៤ មានដូចជាការជួសជុលម៉ាស៊ីនត្រជាក់ និងតបណ្តាញផ្សេងៗ សង្ហារឹមប្រើប្រាស់ឆ្នាំ២០១៥ និងជួតផ្តង់សម្ភារឧបករណ៍បុរាណ ដែលគម្រោងទាំងបួននេះបើកឯកសារចំពេលវេលា (ម៉ោង ថ្ងៃ ខែ ឆ្នាំ) តែមួយនោះ គឺមូលហេតុដោយសារកំហុសបច្ចេកទេសនៃអ្នកធ្វើកំណត់ហេតុដែលធ្វើការចម្លង(Copy) គម្រោងនីមួយៗនៅលើម៉ាស៊ីនកុំព្យូទ័រ ដោយពុំបានធ្វើការកែពេលវេលានៃការបើកគម្រោងនីមួយៗ ដើម្បីដាក់ជូនតំណាងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ គណៈកម្មការលទ្ធកម្ម (PC) និងតំណាងក្រុមហ៊ុនដែលចូលរួមដេញថ្លៃចុះហត្ថលេខាភ្លាមៗនៅពេលដែលបើកឯកសាររួច។ សូមបញ្ជាក់ជូនបន្ថែមទៀតថា ការបើកឯកសារគម្រោងទាំងបួននៃថ្ងៃ ខែឆ្នាំតែមួយនោះគឺអង្គភាពខ្ញុំបានធ្វើការកំណត់ម៉ោងដែលត្រូវបើកឯកសារ ដូចខាងក្រោម:

- ជួតផ្តង់សង្ហារឹមប្រើប្រាស់ឆ្នាំ២០១៥ (វេលាម៉ោង៩.០០នាទី)
- ជួសជុលម៉ាស៊ីនត្រជាក់ និងតបណ្តាញផ្សេងៗ (វេលាម៉ោង៩.៣០នាទី)
- ជួសជុលកែលម្អអគារទីស្តីការក្រសួង (វេលាម៉ោង១០.០០នាទី)
- ជួសជុលកែលម្អអគារសារមន្ទីរខេត្តពោធិ៍សាត់ (វេលាម៉ោង១០.៣០នាទី)

៣.១.២១. ការទូទាត់ចំណាយប្រាក់បំណាច់ម៉ោងបន្ថែមពុំទាន់បានត្រឹមត្រូវ

ដើម្បីពង្រឹងយន្តការលើការទូទាត់ចំណាយលើប្រាក់ម៉ោងបន្ថែមជូនសាស្ត្រាចារ្យតាមបណ្តាគ្រឹះស្ថានសាធារណៈរបស់រដ្ឋ រាជរដ្ឋាភិបាលបានចេញនូវអនុក្រឹត្យលេខ៣៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ១៩៩៦ ស្តីពីកម្រិតរបបម៉ោងកំណត់ម៉ោងបន្ថែម និងប្រាក់ម៉ោងបន្ថែមសម្រាប់ការបង្រៀនក្នុងគ្រឹះស្ថានសិក្សាសាធារណៈ ត្រង់មាត្រា៤ ចំណុចខ

ត្រទី១ បានចែងថា "ចំពោះមន្ត្រីរាជការដែលបានចាត់តាំងជាផ្លូវការឱ្យទៅបង្រៀនជាគ្រូ នៅសាលាមធ្យមសិក្សាឯកទេស សាលាបណ្តុះបណ្តាលវិជ្ជាជីវៈ គ្រឹះស្ថានឧត្តមសិក្សា និង គ្រឹះស្ថានសិក្សាផ្សេងៗរបស់រដ្ឋត្រូវអនុវត្តរបបម៉ោងបន្ថែមដោយគិតជាទឹកប្រាក់ម៉ោងបន្ថែម ទៅតាមសញ្ញាបត្រ ឬក្របខណ្ឌរបស់សាមីជន" និងប្រកាសលេខ១៨៩ សហវ.ប្រក ចុះថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០១៣ ស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិការបស់រដ្ឋ សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិនៃឧបសម្ព័ន្ធទី២នៃគណនី និងអនុ គណនីចំណាយ៦៤០២៣ បានចែងពីការចំណាយ និងកត់ត្រាចំណាយលើប្រាក់ម៉ោងបន្ថែម ជូនមន្ត្រីក្របខណ្ឌអចិន្ត្រៃយ៍ ដែលបានធ្វើការងារលើសម៉ោង និងចំណាយជាប្រាក់ឧបត្ថម្ភ ជូនមន្ត្រីដែលជាគ្រូបង្គោល"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈបាន យកថវិការដ្ឋចំនួន១១៥ ៦៥៩ ០០០ រៀល ទៅធ្វើការទូទាត់ចំណាយលើប្រាក់ឧបត្ថម្ភម៉ោង បន្ថែមជូនសាស្ត្រាចារ្យដែលមិនមានក្របខណ្ឌរបស់សាកលវិទ្យាល័យ និងក្របខណ្ឌរដ្ឋ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួរធ្វើការណែនាំដល់សាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈឱ្យធ្វើការចំណាយថវិការដ្ឋលើការឧបត្ថម្ភប្រាក់ម៉ោងបន្ថែមជូនសាស្ត្រាចារ្យឱ្យ បានត្រឹមត្រូវស្របទៅតាមអនុក្រឹត្យ និងប្រកាសខាងលើ។

ឆ្លើយតបនឹងករណីនេះ ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈបានឯកភាពតាមការ លើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ។

៣.១.២២. កង្វះខាតក្នុងការកំណត់ការរៀបចំរចនាសម្ព័ន្ធ និងតួនាទីភារកិច្ចរបស់អង្គភាព

អនុក្រឹត្យលេខ៥២ អនក្រ.បក ចុះថ្ងៃទី២៣ ខែមិថុនា ឆ្នាំ២០០៣ ស្តីពីការបង្កើត សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈ ជាគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រង់មាត្រា៨ បាន ចែងថា "ក្រុមប្រឹក្សាភិបាលមានបេសកកម្មដឹកនាំ តម្រង់ទិស និងធ្វើការត្រួតពិនិត្យលើ ដំណើរការរបស់សាកលវិទ្យាល័យ។ ក្នុងក្របខណ្ឌនៃបេសកកម្មនេះ ក្រុមប្រឹក្សាភិបាលត្រូវ កំណត់ការរៀបចំរចនាសម្ព័ន្ធ ព្រមទាំងការបែងចែកភារកិច្ចជាទូទៅដល់អង្គភាពក្រោមឱវាទ និងធ្វើការអភិវឌ្ឍន៍តាមការចាំបាច់"។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាកលវិទ្យាល័យភូមិន្ទវិចិត្រសិល្បៈពុំ ទាន់មានការកំណត់ពីការរៀបចំរចនាសម្ព័ន្ធ តួនាទីភារកិច្ច ព្រមទាំងការបែងចែកភារកិច្ចជា ទូទៅដល់អង្គភាពក្រោមឱវាទឱ្យបានច្បាស់លាស់ និងត្រឹមត្រូវនៅឡើយ។

ក្រសួងវប្បធម៌ និងវិចិត្រសិល្បៈគួរធ្វើការណែនាំដល់សាកលវិទ្យាល័យភូមិន្ទ វិចិត្រសិល្បៈ ធ្វើការរៀបចំកំណត់ពីរចនាសម្ព័ន្ធ និងតួនាទីភារកិច្ច និងការបែងចែកភារកិច្ច ទទួលខុសត្រូវរបស់អង្គភាពក្រោមឱវាទឱ្យច្បាស់លាស់ ដើម្បីជួយជំរុញដល់ការគ្រប់គ្រងការ ងាររបស់សាកលវិទ្យាល័យឱ្យកាន់តែមានប្រសិទ្ធភាពខ្ពស់។

៣.១.២៣. ការពុំមានតារាងតម្លៃទិន្នន័យតម្លៃទីផ្សារសម្រាប់វាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ

ស្ថាប័នអនុវត្តកិច្ចលទ្ធកម្មតែងតែរៀបចំតារាងទិន្នន័យតម្លៃទីផ្សារនៃសមាសធាតុលទ្ធកម្មសម្រាប់ទុកជាព័ត៌មានបន្ថែមក្នុងការវាយតម្លៃជ្រើសរើសអ្នកដេញថ្លៃ និងប្រគល់កិច្ចសន្យា។

ការធ្វើសវនកម្មបានរកឃើញថា ក្រសួងបរិស្ថាន (អង្គភាពលទ្ធកម្ម) មិនបានរៀបចំតារាងទិន្នន័យតម្លៃទីផ្សារចំពោះទំនិញដែលត្រូវទិញនោះទេ។

ក្រសួងបរិស្ថានបានធ្វើការបញ្ជាក់ថា ករណីនេះ តម្លៃសម្ភារដែលមាននៅក្នុងកិច្ចសន្យាទាំង១១គម្រោង អង្គភាពលទ្ធកម្មនៃក្រសួងបរិស្ថានមិនបានរៀបចំតម្លៃប្រៀបធៀបឡើយ មូលហេតុបណ្តាលមកពីការចុះរកតម្លៃទំនិញនៅតាមទីផ្សារខ្លះមានតម្លៃថោក និងខ្លះទៀតមានតម្លៃថ្លៃ ដោយឡែកការស្វែងរកតម្លៃទំនិញនៅតាមទីផ្សារពិបាករកតម្លៃពិតប្រាកដ។ ករណីនេះបង្ករឱ្យមានការប្រៀបធៀបតម្លៃទីផ្សារពុំមានមូលដ្ឋានគិតច្បាស់លាស់។

៣.១.២៤. ការចុះកិច្ចសន្យាជាមួយក្រុមហ៊ុនធ្វើការផ្គត់ផ្គង់ទំនិញ ឬសេវា ដែលមានសកម្មភាពអាជីវកម្ម (ប៉ាតង់)មិនស្របតាមកម្មវត្ថុនៃកិច្ចសន្យា

លិខិតជូនដំណឹងលេខ៦១៣៥ សហវ ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើសេចក្តីណែនាំចំពោះអ្នកដេញថ្លៃត្រូវមានមុខរបរឱ្យស្របគ្នានឹងមុខរបរ (ប័ណ្ណប៉ាតង់) ចូលរួមដេញថ្លៃផ្គត់ផ្គង់ទំនិញ ឬសេវា។

ប៉ុន្តែតាមការពិនិត្យឯកសារដែលក្រុមហ៊ុនដាក់ពាក្យចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ និងស្នង់តម្លៃនៅក្នុងកិច្ចលទ្ធកម្មប្រចាំឆ្នាំ២០១៥ របស់ក្រសួងបរិស្ថាន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងបានចុះកិច្ចសន្យាជាមួយក្រុមហ៊ុនធ្វើការផ្គត់ផ្គង់ទំនិញ និងសេវា ហើយក្រុមហ៊ុនដែលបានចុះកិច្ចសន្យាផ្គត់ផ្គង់ទាំងនោះភាគច្រើនមានសកម្មភាពអាជីវកម្មមិនស្របទៅនឹងកម្មវត្ថុនៃកិច្ចសន្យានោះឡើយ។ ដោយសារការខកខានមិនអនុវត្តតាមសេចក្តីជូនដំណឹងខាងលើ នាំឱ្យការអនុវត្តកិច្ចលទ្ធកម្មមិនស្របទៅនឹងសកម្មភាពអាជីវកម្ម។

ក្រសួងបរិស្ថានធ្វើការបញ្ជាក់ថា ក្នុងឆ្នាំ២០១៥ អគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើបច្ចុប្បន្នភាពក្រុមហ៊ុនធ្វើអាជីវកម្មទាំងអស់ក្នុងព្រះរាជាណាចក្រកម្ពុជា ជាហេតុធ្វើឱ្យការចេញប័ណ្ណប៉ាតង់ឆ្នាំ២០១៥ មានការយឺតយ៉ាវ។ ដូចនេះ ក្រុមហ៊ុនដែលបានចូលរួមដេញថ្លៃ ពិគ្រោះថ្លៃ និងស្នង់តម្លៃនៅក្នុងកិច្ចលទ្ធកម្មប្រចាំឆ្នាំ២០១៥ របស់ក្រសួងបរិស្ថានបានយកប័ណ្ណប៉ាតង់ឆ្នាំ ២០១៤ មកចូលរួម ។

៣.១.២៥. នាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុវត្តការងារមិនទាន់អស់លទ្ធភាព

អនុក្រឹត្យលេខ៥០ អនក្រ.បក ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៥ របស់រាជរដ្ឋាភិបាលស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃសវនកម្មផ្ទៃក្នុងនៅតាមបណ្តាស្ថាប័នក្រសួង និងសហគ្រាសសាធារណៈ។

សារាចរណែនាំលេខ១២ សរណន ចុះថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០១១ របស់រាជរដ្ឋាភិបាលស្តីពីការបន្តពង្រឹងមុខងារសវនកម្មផ្ទៃក្នុងតាមបណ្តាក្រសួងស្ថាប័ន និងសហគ្រាសសាធារណៈ។

តាមការពិនិត្យរបាយការណ៍ឫកសរុបប្រចាំឆ្នាំ២០១៥ របស់នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងបរិស្ថាន អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នាយកដ្ឋានសវនកម្មផ្ទៃក្នុង បានអនុវត្តការងារសវនកម្មបានចំនួនតិចតួចបំផុតទៅលើការងារជំនាញរបស់ខ្លួន។

ក្រសួងបរិស្ថានបានបំភ្លឺថា កត្តាដែលនាំឱ្យការអនុវត្តកិច្ចការមិនបានពេញលេញនូវតួនាទី និងភារកិច្ចសម្រាប់ការិយបរិច្ឆេទ២០១៥ នាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងបរិស្ថានជួបប្រទះនូវបញ្ហាប្រឈមមួយចំនួន ដូចជា កង្វះខាតមន្ត្រី សមត្ថភាពមន្ត្រីនៅមានកម្រិត ហើយមន្ត្រីមួយចំនួនបានផ្លាស់ពីអង្គភាពផ្សេងៗចូលមក។ ដោយហេតុថា ក្នុងឆ្នាំ២០១៥ ក្រសួងបរិស្ថានអនុវត្តថវិកាមិនមែនកម្មវិធីនៅឡើយ ហើយកញ្ចប់រដ្ឋទេយ្យបុរេប្រទានគឺមានកម្រិតជាអតិបរមាត្រឹម៣០%នៃឥណទានជ្រើសរើសតាមជំពូក ហើយសល់ពីនេះគឺអនុវត្តតាមនីតិវិធីធម្មតា។ សម្រាប់ឆ្នាំ២០១៦ នាយកដ្ឋានសវនកម្មផ្ទៃក្នុងទើបបញ្ចប់វគ្គបណ្តុះបណ្តាលជំនាញសវនកម្មដល់មន្ត្រីជំនាញ មន្ត្រីពាក់ព័ន្ធ ព្រមទាំងបានរៀបចំផែនការយុទ្ធសាស្ត្រសវនកម្មរយៈពេលបីឆ្នាំ(ឆ្នាំ២០១៧-២០១៩)។ នាយកដ្ឋានសវនកម្មផ្ទៃក្នុងអនុវត្តតាមអនុសាសន៍របស់អាជ្ញាធរសវនកម្មជាតិសម្រាប់ឆ្នាំ២០១៧ ដោយធ្វើសវនកម្មទាំងថ្នាក់កណ្តាល។

៣.១.២៦. ការបំបែកគម្រោងលទ្ធកម្មសាធារណៈ

សារាចរណែនាំលេខ០០៧ សហវ.សរណន ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៣ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ត្រង់ចំណុចទី៣ ចែងថា "មិនអនុញ្ញាតឱ្យមានការសម្របសម្រួលណាមួយដើម្បីបំបែក ឬអង្កន់គម្រោងធានាចំណាយឱ្យទៅជាគម្រោងតូចៗតម្រូវតាមកម្រិតទឹកប្រាក់ដែលបានប្រគល់ សម្រេចក្នុងការអនុវត្តកិច្ចលទ្ធកម្មឡើយ។ ករណីមានការបំបែក ឬអង្កន់ធានាចំណាយលើមុខសញ្ញាតែមួយនោះ បុគ្គល ឬ ស្ថាប័នសមត្ថកិច្ចត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាន"។

តាមការពិនិត្យលើរបាយការណ៍អនុវត្តកិច្ចលទ្ធកម្មសាធារណៈប្រចាំឆ្នាំ២០១៥ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានអនុវត្តគម្រោងលទ្ធកម្មចំនួន២៦ មានទឹកប្រាក់សរុប ៨ ៧៦៩ ២៣០ ០០០រៀល ក្នុងនោះក្រសួងបានទិញសម្ភារឧបភោគបរិភោគចំនួន០២គម្រោង មានទឹកប្រាក់ចំនួន៩៨៧ ០៦០ ០០០ រៀលសម្រាប់ឆមាសទី១ និងទិញសម្ភារឧបភោគបរិភោគចំនួន០៣គម្រោងទៀត ដែលមានទឹកប្រាក់ចំនួន១ ៥៣៩ ៩១៧ ០០០រៀលសម្រាប់ឆមាសទី២។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា នៅក្នុងឆ្នាំ២០១៥ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានបំបែកគម្រោងលទ្ធកម្មដែលមានយថាប្រភេទដូចគ្នាឱ្យទៅ

ជាគម្រោងតូចៗ ដើម្បីតម្រូវតាមកម្រិតទឹកប្រាក់ដែលបានប្រគល់សម្រេចក្នុងការអនុវត្តកិច្ចលទ្ធកម្មរបស់ខ្លួន។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាគួរធ្វើការណែនាំអង្គភាពស្ថិតក្រោមឱវាទ ឱ្យអនុវត្តកិច្ចលទ្ធកម្មសាធារណៈស្របតាមសារាចរណែនាំរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុខាងលើ។

ឆ្លើយតបចំពោះការលើកឡើងខាងលើ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាបានបញ្ជាក់ថា តាមសារាចរណែនាំលេខ០០៧ សហវ.សរណន ចុះថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០០៣របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងយោងរបាយការណ៍សវនកម្មរបស់អាជ្ញាធរសវនកម្មជាតិក្នុងការិយបរិច្ឆេទ២០១៥ ក្រសួងសូមឯកភាពលើនីតិវិធីលទ្ធកម្ម គឺមិនអាចបំបែកគម្រោងបានទេ ប៉ុន្តែការអនុវត្តជាក់ស្តែង គ្រឿងឧបភោគបរិភោគមិនអាចធ្វើការដេញថ្លៃមួយឆ្នាំតែម្តងបានទេ ដោយសាររបស់ទាំងអស់នោះមានកំណត់កាលបរិច្ឆេទ (ទុកបានរយៈពេលខ្លី)។ ម្យ៉ាងវិញទៀត ក្រសួងទិញទៅតាមតម្រូវការជាក់ស្តែងដែលមជ្ឈមណ្ឌលនីមួយៗត្រូវការ ហើយការអនុវត្តកិច្ចលទ្ធកម្មនេះទៀតសោធសុទ្ធតែមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ទោះបីជាយ៉ាងណាក្រសួងសូមឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ ហើយក្រសួងនឹងយកចំណុចនេះទៅពិភាក្សាជាមួយថ្នាក់ដឹកនាំក្រសួងនិងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដើម្បីកុំឱ្យមានបញ្ហានេះកើតមានឡើងនៅឆ្នាំក្រោយបន្ទាប់ទៀត។

៣.១.២៧.ការធ្វើសៀវភៅការងារ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានកំណត់ក្នុងលិខិតលេខ១៩៧ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ និងលិខិតលេខ១៩៥ ក.ប/ប្រ.ក ចុះថ្ងៃទី២០ ខែសីហា ឆ្នាំ២០១៤ ថា ម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយដូចមានចែងក្នុងមាត្រា១នៃច្បាប់ស្តីពីការងារ មិនអាចប្រើកម្មករនិយោជិតខ្មែរដោយគ្មានសៀវភៅការងារឡើយ ហើយត្រូវបង្កលក្ខណៈងាយស្រួលឲ្យពួកគេមានលទ្ធភាពគ្រប់គ្រាន់ ដើម្បីទៅធ្វើសៀវភៅការងារនៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្មនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចំពោះអ្នកនៅរាជធានីភ្នំពេញ និងនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានីខេត្ត និងម្ចាស់ ឬនាយកសហគ្រាស គ្រឹះស្ថានទាំងឡាយដូចមានចែងក្នុងមាត្រា១ នៃច្បាប់ស្តីពីការងារ ដែលត្រូវការប្រើប្រាស់ហត្ថពលកម្មបរទេស ឬជនបរទេសដែលចូលមកប្រកបមុខរបរណាមួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវបំពេញបែបបទស្នើសុំប័ណ្ណការងារ និងសៀវភៅការងារឲ្យបានត្រឹមត្រូវ។ សម្រាប់ការិយបរិច្ឆេទ២០១៥ អាជ្ញាធរសវនកម្មជាតិបានធ្វើសវនកម្មនៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈឃើញថា ទូទាំងខេត្តតាកែវមានក្រុមហ៊ុនកាត់ដេរ ក្រុមហ៊ុនដេរស្បែកជើង ក្រុមហ៊ុនក្រៅពីកាត់ដេរ កាស៊ីណូ សិប្បកម្ម ធនាគារ និងមីក្រូហិរញ្ញវត្ថុ សរុបចំនួន៦៥ ក្នុងនោះមាននិយោជិតខ្មែរសរុបចំនួន២៧ ៨៧៩ នាក់ (មានសៀវភៅការងារចំនួន១៣ ២២១ នាក់ និងពុំមានសៀវភៅការងារចំនួន១៤ ៦៥៨ នាក់)

និងនិយោជិតបរទេសសរុបចំនួន៤៣៨នាក់ (មានសៀវភៅការងារចំនួន៣៥៥ នាក់ និងពុំមានសៀវភៅការងារចំនួន៨៣ នាក់)។

ដើម្បីគ្រប់គ្រងចំណុលនេះឲ្យមានប្រសិទ្ធភាព ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈគួរណែនាំមន្ទីរគួរធ្វើសៀវភៅការងារជូនកម្មករនិយោជិតខ្មែរ និងបរទេសឲ្យស្របតាមគោលការណ៍កំណត់។

ឆ្លើយតបនឹងការលើកឡើងនេះ មន្ទីរបានបញ្ជាក់ថា ស្ថិតិកម្មករ និយោជិតខ្មែរសរុបចំនួន២៧ ៨៧៩ នាក់នេះ គឺស្ថិតចាប់តាំងពីឆ្នាំ២០១១ រហូតដល់ឆ្នាំ២០១៥នេះ ការពិតជាក់ស្តែងកម្មករចំនួន២៧ ៥៩៦ នាក់ បានធ្វើសៀវភៅការងាររួចហើយ នៅសល់តែចំនួន ២៨៣ នាក់ប៉ុណ្ណោះ ហើយមន្ទីរកំពុងជំរុញបន្តទៀត។ ចំនួននិយោជិតបរទេសចំនួន៤៣៨នាក់ គឺមានសៀវភៅការងារទាំងអស់ ឯចំនួន៣៥៥នាក់ បានស្នើសុំកូតាប្រើប្រាស់ជនបរទេសតាមរយៈមន្ទីរ ហើយចំនួន៨៣នាក់ទៀត ធ្វើនៅនាយកដ្ឋានមុខរបរ និងហត្ថពលកម្មនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈផ្ទាល់តែម្តង។

៣.១.២៨.កង្វះខាតការត្រួតពិនិត្យចំណីអាហារ

ដើម្បីគ្រប់គ្រងការត្រួតពិនិត្យតាមដានសុវត្ថិភាពចំណីអាហារឲ្យមានប្រសិទ្ធភាព ក្រសួងសុខាភិបាលបានចេញប្រកាសលេខ ៣០៨ អ.ប.ស/ផ.ព.ស ចុះថ្ងៃទី២៦ ខែសីហា ឆ្នាំ១៩៩៨ ស្តីពីការរៀបចំ និការប្រព្រឹត្តទៅរបស់មន្ទីរសុខាភិបាលខេត្ត ក្រុង ត្រង់ប្រការ៣ បានបញ្ជាក់ថា មន្ទីរសុខាភិបាលខេត្ត ក្រុង មានមុខងារ និងភារកិច្ចពិនិត្យតាមដានសុវត្ថិភាពចំណីអាហារ។ តាមការធ្វើសវនកម្មរបស់អាជ្ញាធរសវនកម្មជាតិនៅមន្ទីរសុខាភិបាលខេត្តព្រះវិហារសម្រាប់ការិយបរិច្ឆេទ២០១៥ សង្កេតឃើញថា ភោជនីយដ្ឋាន អាហារដ្ឋាន និងកន្លែងលក់ចំណីអាហារមានចំនួនសរុប៦១ទីតាំង មន្ទីរសុខាភិបាលបានត្រួតពិនិត្យតែ៣១ទីតាំងប៉ុណ្ណោះ។

ដើម្បីធានានូវសុវត្ថិភាពចំណីអាហារ មន្ទីរសុខាភិបាលគួរត្រួតពិនិត្យឲ្យបានគ្រប់ភោជនីយដ្ឋាន អាហារដ្ឋាន និងកន្លែងលក់ចំណីអាហារ។

ឆ្លើយតបនឹងការលើកឡើងខាងលើ មន្ទីរបានឯកភាព និងជំរុញការអនុវត្តការងារនេះឲ្យបានល្អប្រសើរ។

៣.១.២៩. ការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋ

ដើម្បីគ្រប់គ្រងដីធ្លីឲ្យបានល្អប្រសើរ រាល់អចលនទ្រព្យជាដីធ្លីដែលជាកម្មសិទ្ធិឯកជន ឬជាកម្មសិទ្ធិរបស់រដ្ឋតម្រូវឲ្យមានវិញ្ញាបនបត្រសម្គាល់អចលនទ្រព្យ (ប្លង់កម្មសិទ្ធិ)។ តាមចំណុច១៤.១ មាត្រា១៤ នៃអនុក្រឹត្យលេខ១១៥ អនក្រ.បក ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ១៩៩៩ ស្តីពីការបង្កើតសាកលវិទ្យាល័យភូមិន្ទកសិកម្មជាគ្រឹះស្ថានសាធារណៈរដ្ឋបាល បានកំណត់ដីទីតាំងនៃសាកលវិទ្យាល័យភូមិន្ទកសិកម្មមានចំនួនផ្ទៃដី៣៨០ហិចតា ស្ថិតនៅសង្កាត់ដង្កោ ខណ្ឌដង្កោ រាជធានីភ្នំពេញ។

អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា សាកលវិទ្យាល័យភូមិន្ទកសិកម្មបានធ្វើប្លង់កម្មសិទ្ធិដីបានចំនួនតែ០៣ប្លង់ សរុបស្មើនឹង ២៤៧ ៩៧៤ ម៉ែត្រការ៉េ រីឯផ្ទៃដីដែលនៅសល់ចំនួន៣ ៥៥២ ០២៦ ម៉ែត្រការ៉េ ត្រូវបានប្រជាជនចូលកាន់កាប់។

សាកលវិទ្យាល័យភូមិន្ទកសិកម្មគួរសហការជាមួយក្រសួងស្ថាប័ន និងអាជ្ញាធរដែនដីពាក់ព័ន្ធ ដើម្បីរកដំណោះស្រាយជាបន្ទាន់ចំពោះផ្ទៃដីពុំទាន់មាន ប័ណ្ណកម្មសិទ្ធិដែលប្រជាជនបានចូលកាន់កាប់។

ចំពោះករណីនេះ សាកលវិទ្យាល័យភូមិន្ទកសិកម្មបានឆ្លើយបំភ្លឺថា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានបង្កើតក្រុមការងារវាស់វែងដីធ្លីសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងបានសហការជាមួយក្រុមវាស់វែងដីធ្លីរបស់សាលារាជធានីភ្នំពេញ បានចុះវាស់វែងដីដែលសាកលវិទ្យាល័យបាននិងកំពុងកាន់កាប់ចំនួន៣កន្លែង ដែលមានទំហំសរុប ២៤៧ ៩៧៤ ម៉ែត្រការ៉េ (២៤ហិកតា និង៧ ៩៧៤ ម៉ែត្រការ៉េ) និងបានធ្វើប័ណ្ណកម្មសិទ្ធិក្បាលដីទាំង៣នេះរួចហើយ គឺក្បាលដីលេខ៣៥៦ ទំហំ ៥ ៤៧៣ ម៉ែត្រការ៉េ ក្បាលដីលេខ១១៨៥ ទំហំ ២៧ ១៣៤ ម៉ែត្រការ៉េ និងក្បាលដីលេខ១១៨៦ ទំហំ ២១៥ ៣៦៧ ម៉ែត្រការ៉េ។ ដោយឡែកទំហំដីក្រៅពីនេះ ត្រូវបានប្រជាជនចូលកាន់កាប់ ហើយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទបានធ្វើលិខិតស្នើសុំឯកឧត្តមអភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញស្នើសុំជម្រះចេញពីបញ្ជីសារពើភណ្ឌរបស់សាកលវិទ្យាល័យភូមិន្ទកសិកម្មតាមរយៈលិខិតលេខ៤៣០៨ កសក ចុះថ្ងៃទី០៨ ខែមិថុនា ឆ្នាំ២០១៦ កន្លងមករួចហើយ។

៣.២.ការគ្រប់គ្រងថវិការដ្ឋបាលថ្នាក់ក្រោមជាតិ

៣.២.១.ការប្រមូលពន្ធប្រថាប់ត្រា

រាជរដ្ឋាភិបាលកម្ពុជាបានចេញអនុក្រឹត្យលេខ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងអង្គភាពក្រោមឱវាទ ត្រង់មាត្រា៣៦ តម្រូវឱ្យអគ្គនាយកដ្ឋានពន្ធដាររៀបចំលិខិតបទដ្ឋាននានាកំណត់បញ្ជីឯកសារចាំបាច់នានា និងលិខិតយុត្តិការដែលអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវកាន់កាប់ រក្សាទុក និងផ្តល់ជូនរដ្ឋបាលសារពើពន្ធ....។ ជាងនេះទៀត ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសលេខ១១៧០ សហវ.ប្រក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៤ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃនាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ នៃអគ្គនាយកដ្ឋានពន្ធដារត្រង់ប្រការ១៣ បានចែងថា ការិយាល័យអចលនទ្រព្យ និងប្រថាប់ត្រាមានភារកិច្ចរៀបចំមូលដ្ឋានគិតពន្ធប្រថាប់ត្រា និងប្រមូលពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកម្មសិទ្ធិ និងសិទ្ធិកាន់កាប់អចលនទ្រព្យ និងប្រកាសលេខ៩៦២ សហវ.ប្រក ចុះថ្ងៃទី២៨ ខែសីហា ឆ្នាំ២០១៤ ស្តីពីការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រា ចំពោះការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ ត្រង់ឧបសម្ព័ន្ធទី១ ស្តីពីការបែងចែកភូមិសាស្ត្រ និងតម្លៃអចលនទ្រព្យសម្រាប់មូលដ្ឋានគិតពន្ធប្រថាប់ត្រានៅរាជធានីភ្នំពេញ។ តាមការពិនិត្យសំណុំឯកសារប្រថាប់ត្រាលើ

អចលនទ្រព្យខែមករា ខែមិថុនា និងខែធ្នូ សម្រាប់ការិយបរិច្ឆេទ២០១៥ របស់នាយកដ្ឋានច្បាប់ វិវាទ និងស្ថិតិ អាជ្ញាធរសវនកម្មជាតិបានសង្កេតឃើញថា នាយកដ្ឋាននេះបានប្រមូលចំណូលពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យដោយមានសំណុំឯកសារភ្ជាប់មកជាមួយ ដូចជា ដីកាបញ្ជូនរបស់មន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី ព័ត៌មានក្បាលដី លិខិតលក់ផ្តាច់ វិញ្ញាបនប័ត្រសម្គាល់ម្ចាស់អចលនទ្រព្យ ឯកសារបញ្ជាក់អត្តសញ្ញាណអ្នកផ្ទេរសិទ្ធិ ឬអ្នកទទួលសិទ្ធិ លទ្ធផលស្តីពីការចុះត្រួតពិនិត្យទីតាំងដើម្បីគិតពន្ធ គំនូសប្លង់ទីតាំងគណនាប្រាក់ពន្ធ និងលិខិតប្រកាសពន្ធប្រថាប់ត្រាលើការផ្ទេរសិទ្ធិកាន់កាប់អចលនទ្រព្យ។ ប៉ុន្តែឯកសារដែលចាំបាច់សម្រាប់គាំទ្រដល់ការកំណត់មូលដ្ឋានគិតពន្ធប្រថាប់ត្រា ដូចជាឆ្នាំសាងសង់ និងការកំណត់ប្រភេទអចលនទ្រព្យមិនបានបំពេញត្រឹមត្រូវ។ ជាងនេះទៀត ការគណនាប្រាក់ពន្ធប្រថាប់ត្រាលើអចលនទ្រព្យមានករណីខ្លះលើស និងខ្វះ។

ការផ្តល់ព័ត៌មានអំពីអចលនទ្រព្យមិនបានពេញលេញ អាចនាំឱ្យពុំទាន់មានតម្លាភាពក្នុងការប្រមូលពន្ធប្រថាប់ត្រា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុគួរណែនាំអង្គភាពប្រតិបត្តិខាងលើអនុវត្តការងារឱ្យបានស្របតាមខ្លឹមសារនៃលិខិតបទដ្ឋានគតិយុត្តខាងលើ។

ឆ្លើយតបនឹងបញ្ហានេះ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានឯកភាព និងសូមបំភ្លឺបន្ថែមថា ចំណុចខ្វះខាតដែលបានលើកឡើងនេះ ដោយករណីការដាក់លិខិតប្រកាសពន្ធប្រថាប់ត្រាលើការផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យដែលបំពេញព័ត៌មានមួយចំនួននៅមិនទាន់បានពេញលេញ ដូចជាខ្វះឆ្នាំសាងសង់ និងការកំណត់ប្រភេទអចលនទ្រព្យ ករណីនេះអ្នកជាប់ពន្ធជាអ្នកបំពេញបែបបទ និងប្រកាសបង់ពន្ធប្រថាប់ត្រាលើអចលនទ្រព្យដូច្នេះព័ត៌មានខ្លះអ្នកជាប់ពន្ធមិនបានបំពេញគ្រប់គ្រាន់ និងពេញលេញ។ ម្យ៉ាងវិញទៀត ឯកសារមួយចំនួនដែលបានបញ្ជូនមកពីរដ្ឋបាលសុរិយោដី ឬមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីរាជធានីភ្នំពេញ មិនបានភ្ជាប់មកជាមួយនូវព័ត៌មានក្បាលដី ឬទម្រង់បែបបទនៃការប្រមូលទិន្នន័យក្បាលដី ដូច្នេះជាហេតុបណ្តាលឱ្យទម្រង់ប្រកាសប្រថាប់ត្រាលើអចលនទ្រព្យមិនមានព័ត៌មានពេញលេញ។ ក្នុងករណីការគណនាប្រាក់ពន្ធលើស អគ្គនាយកដ្ឋានពន្ធដារបានសម្រេចការគណនាប្រាក់ពន្ធត្រូវបង់ដោយតម្លើងជាខ្ពង់ម៉ឺន ដើម្បីងាយស្រួលក្នុងការធ្វើរបាយការណ៍ស្តិតិពន្ធប្រថាប់ត្រាលើអចលនទ្រព្យ។ ករណីមានប្រាក់ពន្ធខ្វះតិចតួចអាចបណ្តាលមកពីកំហុសអចេតនារបស់មន្ត្រីរដ្ឋបាលសារពើពន្ធក្នុងការគណនាដោយដៃ ហើយបច្ចុប្បន្ន អគ្គនាយកដ្ឋានពន្ធដារបានរៀបចំប្រព័ន្ធកុំព្យូទ័រដែលមានការវាយបញ្ចូលទិន្នន័យក្នុង Data Base ត្រឹមត្រូវ និងមានការគណនាតាមកុំព្យូទ័រពោលគឺដំណើរការដោយប្រព័ន្ធទំនើបកម្មទាំងអស់។ បន្ថែមពីនេះទៀត អគ្គនាយកដ្ឋានពន្ធ

ដារក៏បានចេញសេចក្តីណែនាំស្តីពីការអនុវត្តប្រមូលពន្ធប្រថាប់ត្រាចំពោះការផ្ទេរកម្មសិទ្ធិ ឬ សិទ្ធិកាន់កាប់អចលនទ្រព្យ ព្រមទាំងបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយខ្លឹមសារលិខិតលេខ ១៣៤ ស.ជ.ណ របស់ទីស្តីការគណៈរដ្ឋមន្ត្រី និងសេចក្តីណែនាំលេខ៨៧២៦ អពដ នៅទូទាំង រាជធានីខេត្តទាំងអស់ ដោយមានការចូលរួមពីអាជ្ញាធរមូលដ្ឋាន និងរដ្ឋបាលសុរិយោដីក្នុង គោលបំណងពង្រឹងការគ្រប់គ្រងប្រមូលពន្ធប្រថាប់ត្រា។ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុក៏ មានការផ្ញើលិខិតជូនឯកឧត្តម អភិបាលនៃគណៈអភិបាល រាជធានីខេត្ត ដើម្បីស្នើជំរុញការ ប្រមូលពន្ធប្រថាប់ត្រានេះឱ្យកាន់តែមានប្រសិទ្ធភាពមួយកម្រិតទៀត។

៣.២.២. ការបង្កើតបញ្ជីដីមិនបានប្រើប្រាស់

ចាប់តាំងពីឆ្នាំ២០០៤ ជាបន្តបន្ទាប់គណៈកម្មការដីមិនបានប្រើប្រាស់តែងតែបានចេញលិខិតណែនាំអនុគណៈកម្មការដីមិនបានប្រើប្រាស់តាមខេត្តក្រុងបានតម្រូវឲ្យអនុគណៈកម្មការមានភារកិច្ចបង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងខេត្តក្រុង។ ប៉ុន្តែកន្លងមក ករណីនេះនៅមិនទាន់បានអនុវត្តបានពេញលេញនៅឡើយទេ ជាអាទិ៍ក្នុងឆ្នាំ២០១៥ តាមការធ្វើសវនកម្មនៅសាលាខេត្តតាកែវឃើញថា អនុគណៈកម្មការដីមិនបានប្រើប្រាស់នៅមិនទាន់បានបង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងខេត្ត ដើម្បីឲ្យសាខាពន្ធដារធ្វើជាមូលដ្ឋានក្នុងការប្រមូលពន្ធនៅឡើយ។

ដើម្បីគ្រប់គ្រងដីធ្លីមិនបានប្រើប្រាស់ឲ្យបានច្បាស់លាស់ និងប្រមូលពន្ធឲ្យបានត្រឹមត្រូវ អនុគណៈកម្មការដីមិនបានប្រើប្រាស់ខេត្តតាកែវ គួរបង្កើតបញ្ជីដីត្រូវជាប់ពន្ធតាមតំបន់ក្នុងខេត្តរបស់ខ្លួនឲ្យបានឆាប់រហ័ស និងទាន់ពេលវេលាស្របតាមការណែនាំរបស់គណៈកម្មការដីមិនបានប្រើប្រាស់។

ឆ្លើយតបតាមការលើកឡើងខាងលើ សាលាខេត្តតាកែវ និងសាខាពន្ធដារសូមឯកភាពតាមការលើកឡើងរបស់អាជ្ញាធរសវនកម្មជាតិ។

៣.២.៣.ការបង់ចំណូលឆ្លងឆ្នាំ

ជារៀងរាល់ចុងឆ្នាំ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញសារាចរណែនាំស្តីពីការបិទបញ្ជីចំណូលចំណាយ និងការធ្វើរបាយការណ៍ប្លកសរុបការអនុវត្តចំណូលចំណាយថវិកាថ្នាក់ជាតិ ជាក់ស្តែងក្នុងឆ្នាំ២០១៥ មានសារាចរណែនាំលេខ០១៤ សហវ ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០១៥ ត្រង់ចំណុច**ក** បានចែងថា ចំណូលថវិកាទាំងអស់ ទោះបីស្ថិតក្នុងប្រភេទចំណូលណាក៏ដោយ អាណាប័កគ្មានសិទ្ធិដកចំណូលយកទៅចំណាយ ឬមួយពន្យារពេលបង់ចូលថវិកាថ្នាក់ជាតិ ដើម្បីទុកប្រើប្រាស់ជាផលប្រយោជន៍ណាមួយបានឡើយ..។ ដូចនេះ ប្រាក់ចំណូលទាំងអស់ត្រូវតែប្រមូលបង់ចូលថវិកាថ្នាក់ជាតិយ៉ាងយឺតបំផុតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៥ ជាកំហិត។ តាមរយៈការពិនិត្យសៀវភៅរាយការណ៍ បេឡារបស់មន្ទីររ៉ែ និងថាមពលខេត្តកណ្តាល និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុ ឃើញថា មន្ទីរទាំងពីរបានបង់ចំណូលឆ្លងឆ្នាំ ក្នុងនោះ មន្ទីររ៉ែ និងថាមពលខេត្ត

កណ្តាលមានចំនួន១៩១ ២៩៥ ០០០រៀល និងមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីខេត្តព្រះសីហនុមានចំនួន៩០ ៤០៥ ០០០ រៀល។

សាលាខេត្តគួរណែនាំមន្ទីរជំនាញខាងលើឱ្យខិតខំបង់ចំណូល ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

ឆ្លើយតបនឹងការលើកឡើងនេះ សាលាខេត្តព្រះសីហនុបានទទួលយកអនុសាសន៍សវនកម្ម និងសាលាខេត្តកណ្តាលបានបំភ្លឺថា ការបង់យឺតឆ្លងឆ្នាំនេះ ដោយសារម្ចាស់អាជីវកម្មបានបង់នៅល្ងាចថ្ងៃ៣១ ខែធ្នូ ឆ្នាំ២០១៥ ធ្វើបែបបទបង់ចំណូលមិនទាន់។

៣.២.៤.ការចំណាយមិនសមស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកា

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាខេត្ត ក្រុង និងខណ្ឌ ស្រុក ត្រង់ឧបសម្ព័ន្ធ២ ជំពូក២១ គណនី ២១៣ បានអនុញ្ញាតឲ្យខេត្ត ក៏ដូចជាបណ្តាមន្ទីរជុំវិញអនុវត្តមាតិកាចំណាយថវិការបស់ខ្លួន ឱ្យបានសមស្របតាមការកំណត់របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្នុងនោះអនុគណនី ២១៣១ ស្តីពីសំណង់អគារ អនុគណនី២១៣២ ស្តីពីការរៀបចំកែលម្អអគារ និងអនុគណនី ២១៣៨ ស្តីពីសំណង់ផ្សេងៗទៀត។ រីឯជំពូក៦១ (៦១៥២) កត់ត្រាការចំណាយលើការថែទាំជួសជុលអគារ និងប្រាសាទ។

តាមការធ្វើតេស្តសវនកម្មលើសំណុំឯកសារលទ្ធកម្មនៅខេត្តចំនួន០៤ គឺខេត្តកណ្តាល កោះកុង ព្រះសីហនុ និងខេត្តកំពង់ធំ ឃើញថា អាណាប័កប្រទានសិទ្ធ និងអភិបាលហិរញ្ញវត្ថុខេត្តបានអនុញ្ញាតឱ្យសាលាខេត្ត និងមន្ទីរជុំវិញខេត្តមួយចំនួនប្រើប្រាស់ថវិកាជំពូក៦១ គណនី៦១៥ អនុគណនី៦១៥២ មកចំណាយសម្រាប់ការងារជួសជុល ដូចជាអគារ របង ស្ពាន ផ្លូវ។ល។ ប៉ុន្តែតាមការពិនិត្យលើគំនូសប្លង់ បញ្ជីប៉ាន់តម្លៃ របាយការណ៍លម្អិតលក្ខណៈបច្ចេកទេស គឺសុទ្ធតែបង្ហាញអំពីការងាររៀបចំគ្រឹះនៃការស្តាបនាថ្មី និងការសាងសង់បន្ថែម ក្នុងនោះខេត្តកណ្តាលមានចំនួន០១គម្រោង ខេត្តកោះកុងមានចំនួន១១គម្រោង ខេត្តព្រះសីហនុមានចំនួន០៥គម្រោង និងខេត្តកំពង់ធំមានចំនួន០១គម្រោង។

ដោយសារការចំណាយមិនសមស្របតាមចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានេះ នាំឱ្យប៉ះពាល់ដល់គោលនយោបាយហិរញ្ញវត្ថុ និងតួលេខនៃគណនីចំណាយក្នុងរបាយការណ៍ទូទាត់ថវិកាសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥របស់សាលាខេត្ត និងបណ្តាមន្ទីរពាក់ព័ន្ធ និងការចំណាយនេះឆ្លុះបញ្ចាំងមិនពិតប្រាកដ។

សាលាខេត្ត មន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងមន្ទីរអនុវត្តគម្រោងគួរអនុវត្តឲ្យបានសមស្របតាមប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកាខាងលើ។

ឆ្លើយតបនឹងការលើកឡើងនេះ សាលាខេត្តមួយចំនួនមិនបានឆ្លើយបំភ្លឺឡើយ និងខេត្តមួយចំនួនទៀតបានបំភ្លឺថា បានអនុវត្តតាមផែនការប្រចាំឆ្នាំដោយមានការឯកភាពពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

ផ្អែកតាមការបំភ្លឺនេះ អាជ្ញាធរសវនកម្មជាតិនៅតែទទួចឱ្យអនុវត្តតាមប្រកាសស្តីពីការដាក់ឱ្យអនុវត្តចំណាត់ថ្នាក់សេដ្ឋកិច្ចនៃមាតិកាថវិកានាឆ្នាំបន្តបន្ទាប់ចំពោះគម្រោងចំណាយនៃសំណង់ណាដែលលម្អិតលក្ខណៈបច្ចេកទេសមានរៀបចំជាគ្រឹះមួយរយភាគរយ ទោះបីស្ថិតលើទីតាំងចាស់ក៏ដោយ ហើយស្នើឱ្យញែកឱ្យដាច់នូវគម្រោងចំណាយដែលមានការងារជួសជុលលាយជាមួយការងារសាងសង់ផងដែរ ដើម្បីរំលេចឱ្យច្បាស់ចៀសវាងការភាន់ច្រឡំលើការប្រើប្រាស់ខ្ជង់ថវិកា។

៣.២.៥.ភាពយឺតយ៉ាវក្នុងការធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញលិខិតលេខ ៣៨៥៥ សហវ.ទរ ចុះ ថ្ងៃទី ១៨ ខែកក្កដា ឆ្នាំ២០០៧ ស្តីពីការរំលឹកការធ្វើប្លង់កម្មសិទ្ធិ ដែលស្ថិតនៅក្រោមការគ្រប់គ្រងរបស់បណ្តាក្រសួងស្ថាប័ន និងខេត្តក្រុង ដោយធ្វើការក្រើនរំលឹកដល់គ្រប់ក្រសួងស្ថាប័នរដ្ឋលេខាធិការដ្ឋាន ព្រមទាំងបណ្តាមន្ទីរ និងសាលាខេត្ត ក្រុងទាំងអស់ត្រូវរៀបចំធ្វើប្លង់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋដែលខ្លួនកំពុងកាន់កាប់ឱ្យបានឆាប់រហ័ស ដោយរួមសហការជាមួយមន្ទីររៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដី គ្រប់ខេត្តក្រុងទាំងអស់។

តាមរយៈការធ្វើសវនកម្មនៅខេត្តចំនួន០៤ ឃើញថា ដីធ្លីដែលស្ថិតក្រោមការគ្រប់គ្រងរបស់សាលាខេត្ត និងមន្ទីរជំនាញមួយចំនួនវិញខេត្តពុំទាន់មានប្លង់កម្មសិទ្ធិនៅឡើយជាអាទ៍ ខេត្តបាត់ដំបងមានចំនួន១៦ប្លង់ ខេត្តកណ្តាលមានចំនួន២៧ប្លង់ ខេត្តកោះកុងមានចំនួន១៦៨ប្លង់ ខេត្តកំពង់ធំមានចំនួន៥១២ប្លង់ ។

ដោយសារការយឺតយ៉ាវក្នុងការធ្វើប្លង់កម្មសិទ្ធិលើដីធ្លីរបស់រដ្ឋ និងការគ្រប់គ្រងដីរដ្ឋមិនបានល្អ បណ្តាលឱ្យកើតមានអំពើរំលោភបំពានពីមជ្ឈដ្ឋានខាងក្រៅ និងឈានដល់ការបាត់បង់ទ្រព្យសម្បត្តិរដ្ឋជាយថាហេតុ។

សាលាខេត្ត និងមន្ទីរជុំវិញខេត្តដែលជាអាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវរួសរាន់រៀបចំធ្វើប្លង់កម្មសិទ្ធិឱ្យបានឆាប់រហ័ស។

ឆ្លើយតបនឹងការលើកឡើងនេះ សាលាខេត្តមួយចំនួនបានបញ្ជាក់ថា ដីធ្លីមួយចំនួនបានទទួលប្លង់កម្មសិទ្ធិរួចហើយក្រោយពីការចុះធ្វើសវនកម្ម និងមួយចំនួនទៀតបានបំភ្លឺថា ការយឺតយ៉ាវនេះគឺបណ្តាលមកពីដីមានពាក់ព័ន្ធទំនាស់ និងការរំលោភបំពាន និងដីខ្លះទៀតកំពុងត្រូវបានសមត្ថកិច្ចរៀបចំដែនដី នគរូបនីយកម្ម សំណង់ និងសុរិយោដីកំពុងអនុវត្តដំណើរការការងាររៀបចំឯកសារ។

៣.២.៦.កង្វះខាតក្នុងការរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើងថយចុះ

រាជរដ្ឋាភិបាលកម្ពុជាបានចេញសារាចរណែនាំលេខ០៧ សរ ចុះថ្ងៃ៣០ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ត្រង់ទម្រង់ទី២ បានចែងថា តារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋ ដែលត្រូវធ្វើឡើងក្នុងឆ្នាំនីមួយៗក្នុងចន្លោះរយៈពេល០៥ (ប្រាំ) ឆ្នាំ នៃឆ្នាំគោល។ អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវធ្វើតារាងប្រៀប

ធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋក្នុងឆ្នាំនីមួយៗ ដោយអនុលោមតាមបែបបទ នីតិវិធី និងទម្រង់គំរូរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

តាមរយៈការចុះធ្វើសវនកម្មក្នុងអំឡុងពេលចាប់ពីខែមីនា ដល់ចុងឆ្នាំ២០១៦ នៅខេត្តបាត់ដំបង កោះកុង និងខេត្តកំពង់ធំ ឃើញថា សាលាខេត្ត និងមន្ទីរជំនាញមួយចំនួនក្នុងខេត្តនៅមិនទាន់បានរៀបតារាងប្រៀបធៀបនៃការកើនឡើង ឬថយចុះទ្រព្យសម្បត្តិរដ្ឋឆ្នាំ២០១៥ នៅឡើយ ក្នុងនោះខេត្តបាត់ដំបងមានចំនួន១៤តារាង ខេត្តកោះកុងមានចំនួន ១០តារាង និងខេត្តកំពង់ធំមានចំនួន០៧តារាង។

ដោយសារការមិនបានរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើងថយចុះប្រចាំឆ្នាំនេះ នាំឱ្យការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋមិនបានល្អ និងអាចបាត់បង់ជាយថាហេតុ។ ដូចនេះ សាលាខេត្ត និងមន្ទីរដែលពុំទាន់បានរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើងថយចុះ គួរខិតខំរួសរាន់រៀបចំតារាងខាងលើឱ្យបានឆាប់។

ឆ្លើយតបនឹងការលើកឡើងនេះ សាលាខេត្តមួយចំនួនបានទទួលយកអនុសាសន៍សវនកម្ម និងមួយចំនួនទៀតបញ្ជាក់ថា ក្រោយពីការធ្វើសវនកម្ម អង្គភាពមួយចំនួនបានរៀបចំតារាងប្រៀបធៀបទ្រព្យសម្បត្តិរដ្ឋកើនឡើងថយចុះរបស់ខ្លួនរួចហើយ នៅសល់មួយចំនួនធ្វើមិនទាន់រួចនៅឡើយ។

៤. ការពិនិត្យឡើងវិញលើវឌ្ឍនភាពនៃការអនុវត្តអនុសាសន៍សវនកម្ម

ផ្អែកតាមលទ្ធផលនៃការធ្វើសវនកម្មសម្រាប់ការិយបរិច្ឆេទ២០១៥ និងនាពេលកន្លងមក អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា ចំណុចខ្វះខាត និងអនុសាសន៍សវនកម្មមួយចំនួនដែលអាជ្ញាធរសវនកម្មជាតិបានលើកឡើង ត្រូវបានក្រសួងស្ថាប័ន រដ្ឋបាលរាជធានីខេត្ត រដ្ឋបាលមូលដ្ឋាន និងអង្គភាពពាក់ព័ន្ធនានាខិតខំអនុវត្តកែលម្អគួរឲ្យកត់សម្គាល់ និងកោតសសើរ រីឯចំណុចមួយចំនួនទៀតនៅតែបន្តកើតមាននៅឡើយ ជាអាទិ៍ ៖

៤.១. ការកាន់កាប់កិច្ចបញ្ជីគណនេយ្យរបស់អ្នកជាប់ពន្ធ: ច្បាប់ស្តីពីសារពើពន្ធបានកំណត់ឲ្យអ្នកជាប់ពន្ធត្រូវកាន់កាប់ កត់ត្រា និងថែរក្សាទុកបញ្ជី លិខិតយុត្តិការ និងឯកសារហិរញ្ញវត្ថុផ្សេងៗ ក្នុងករណីដែលអ្នកជាប់ពន្ធមិនបានរក្សាទុកឱ្យបានត្រឹមត្រូវនូវបញ្ជីគណនេយ្យ ឬមិនបានផ្តល់ព័ត៌មានចាំបាច់ជូនរដ្ឋបាលសារពើពន្ធ នោះអ្នកជាប់ពន្ធត្រូវរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ...”។ តាមការធ្វើសវនកម្មសំណុំឯកសារសវនកម្មនៃការកំណត់ពន្ធឡើងវិញរបស់នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារលើអ្នកជាប់ពន្ធចំនួន៨៣ក្រុមហ៊ុន សហគ្រាស ក្នុងការិយបរិច្ឆេទ២០១៥ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អ្នកជាប់ពន្ធចំនួន៥១ក្រុមហ៊ុនសហគ្រាស (ក្រុមហ៊ុនសហគ្រាសស្ថិតនៅក្រោមការគ្រប់គ្រងអ្នកជាប់ពន្ធធំចំនួន១៥ និងស្ថិតនៅក្រោមការគ្រប់គ្រងអ្នកជាប់ពន្ធមធ្យមចំនួន៣៦) មិនបានកាន់កាប់ កត់ត្រា និងថែរក្សាទុកបញ្ជីកាគណនេយ្យ និងលិខិតយុត្តិការឱ្យបានត្រឹមត្រូវតាមការកំណត់របស់ច្បាប់ ដែលជាហេតុនាំឱ្យរងនូវការកំណត់ពន្ធជាឯកតោភាគីពីរដ្ឋបាលសារពើពន្ធ។ ករណីនេះ កន្លងមក អគ្គនាយកដ្ឋានពន្ធដារ

បានរៀបចំផែនការសកម្មភាព ដើម្បីកែលម្អ និងជំរុញឱ្យអ្នកជាប់ពន្ធកាន់កាប់បញ្ជីស្មាមឱ្យបានត្រឹមត្រូវ ដោយបាននិងកំពុងរៀបចំសិក្ខាសាលាផ្សព្វផ្សាយជាច្រើនដល់អ្នកជាប់ពន្ធនានា តាមវិស័យអាជីវកម្មសំខាន់ៗ ដើម្បីពន្យល់ណែនាំពីការកាន់បញ្ជីការគណនេយ្យឲ្យបានត្រឹមត្រូវ លើសពីនេះទៀតក៏បានចេញសេចក្តីជូនដំណឹងលេខ១២១៩ ចុះថ្ងៃទី១៩ ខែមករា ឆ្នាំ២០១៧ ស្តីពីការអនុគ្រោះលើកលែងទោសទណ្ឌានានាក្នុងការកែតម្រូវលិខិតប្រកាសពន្ធដោយស្ម័គ្រចិត្ត និងបានធ្វើការណែនាំដល់មន្ត្រីចាត់ចែងលិខិតប្រកាស និងសវនករគ្រប់រូបឱ្យយកចិត្តទុកដាក់ចំពោះការកាន់បញ្ជីកាគណនេយ្យរបស់អ្នកជាប់ពន្ធនៅពេលប្រកាស និងពេលចុះធ្វើសវនកម្ម និងបាននិងកំពុងរៀបចំនិងបោះពុម្ពសៀវភៅណែនាំស្តីពីការកាន់កាប់កត់ត្រាបញ្ជីគណនេយ្យសាមញ្ញសម្រាប់សហគ្រាសជាអ្នកជាប់ពន្ធតូច។

៤.២. ការបំពេញកាតព្វកិច្ចសារពើពន្ធ: ច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់សារពើពន្ធបានកំណត់ឲ្យអ្នកជាប់ពន្ធ ឬភ្នាក់ងារកាត់ទុកត្រូវដាក់លិខិតប្រកាសសារពើពន្ធទៅតាមទម្រង់ ពេលវេលា និងទីកន្លែងដែលរដ្ឋបាលសារពើពន្ធបានកំណត់។ តាមការធ្វើសវនកម្មលើបញ្ជីឈ្មោះក្រុមហ៊ុនសហគ្រាសដែលបានចុះបញ្ជី និងលិខិតជូនដំណឹងរបស់រដ្ឋបាលសារពើពន្ធចំពោះ លោក លោកស្រី នាយកក្រុមហ៊ុន សហគ្រាសនីមួយៗឲ្យមកដាក់លិខិតប្រកាសពន្ធ និងបង់ប្រាក់ពន្ធប្រចាំខែ ប្រចាំឆ្នាំនៅអង្គភាពពន្ធ។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្នុងឆ្នាំ២០១៥ មានក្រុមហ៊ុនមួយចំនួនមិនបានមកដាក់លិខិតប្រកាសពន្ធប្រចាំខែ និងប្រចាំឆ្នាំ២០១៥ទេ។ ករណីក្រុមហ៊ុនមិនបានមកបំពេញកាតព្វកិច្ចសារពើពន្ធនេះ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងរៀបចំក្រុមការងារ ដើម្បីចុះអង្កេតស្រាវជ្រាវសហគ្រាសតាមដងផ្លូវ (Street Survey) ដើម្បីឲ្យសហគ្រាសដែលមិនបានចុះបញ្ជីត្រឹមត្រូវ ឬលាក់ខ្លួនមិនព្រមមកចុះបញ្ជីពន្ធដារ បានមកចុះបញ្ជីពន្ធដារបានគ្រប់ៗគ្នា។ ទន្ទឹមគ្នានេះដែរ បាននិងកំពុងរៀបចំសិក្ខាសាលាផ្សព្វផ្សាយស្តីពីវប្បធម៌នៃការបង់ពន្ធតាមរយៈកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារណៈ និងតាមរយៈគោលនយោបាយបង្ក្រាបវប្បធម៌បង់ពន្ធរបស់អគ្គនាយកដ្ឋានពន្ធដារដែលតម្រូវឲ្យនាយកដ្ឋានពាក់ព័ន្ធ និងសាខាពន្ធដារខេត្ត ខណ្ឌ រៀបចំសិក្ខាសាលាតាមវិស័យអាជីវកម្មជូនអ្នកជាប់ពន្ធ។

៤.៣. របាយការណ៍សវនកម្មរបស់សវនករឯករាជ្យ: សហគ្រាសវិនិយោគទាំងឡាយដែលបានធ្វើសកម្មភាពអាជីវកម្ម មានកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុប្រចាំការិយបរិច្ឆេទនីមួយៗរបស់ខ្លួនជូនសវនករឯករាជ្យសម្រាប់ធ្វើសវនកម្មស្របទៅតាមច្បាប់ដែលបានកំណត់ចំពោះសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យពីរក្នុងចំណោមលក្ខណៈវិនិច្ឆ័យបីគឺ (១) ផលរបរប្រចាំឆ្នាំសហគ្រាសមានចំនួនចាប់ពីបីពាន់លានរៀលឡើងទៅ (២) ទ្រព្យសកម្មសរុបមានតម្លៃចាប់ពីពីរពាន់លានរៀលឡើងទៅ (៣) និយោជិកបម្រើការងារមានចំនួនចាប់ពីមួយរយនាក់ឡើងទៅ និងរាល់គម្រោងវិនិយោគដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ ហើយបានចុះឈ្មោះនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ពោលគឺសហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យដូចនេះត្រូវមានរបាយការណ៍សវនកម្មរបស់សវនកររឯករាជ្យ។ ក្នុងឆ្នាំ២០១៥ នាយកដ្ឋានសវនកម្មសហគ្រាសនៃអគ្គនាយកដ្ឋានពន្ធដារបានចុះធ្វើ

សវនកម្មលើ សហគ្រាសដែលមានលក្ខណៈវិនិច្ឆ័យ ត្រូវមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យចំនួន៣៧ ឃើញមានសហគ្រាសចំនួន៦ មានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ រីឯក្រុមហ៊ុនសហគ្រាសផ្សេងទៀតនៅពុំឃើញមានរបាយការណ៍សវនកម្មរបស់សវនករឯករាជ្យ ឡើយ។ ករណីនេះ អគ្គនាយកដ្ឋានពន្ធដារបាននិងកំពុងរៀបចំសៀវភៅណែនាំស្តីពីការធ្វើសវនកម្មសហគ្រាស និងកំពុងជំរុញឲ្យអ្នកជាប់ពន្ធតាមវិស័យមួយចំនួនដែលស្ថិតក្រោមគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ គឺតម្រូវឲ្យមានរបាយការណ៍ហិរញ្ញវត្ថុពីស្នងការគណនេយ្យឯករាជ្យ។

៤.៤. ការប្រើប្រាស់វិក្កយបត្រ: តាមច្បាប់ស្តីពីសារពើពន្ធគឺតម្រូវឲ្យមានការប្រើប្រាស់ ឬចេញវិក្កយបត្រចំពោះរាល់កិច្ចការជំនួញរវាងអ្នកជាប់ពន្ធ និងបុគ្គលដទៃទៀត។ ចំពោះវិក្កយបត្រអាករលើតម្លៃបន្ថែម គឺត្រូវមានចុះលេខរៀងត្រឹមត្រូវឲ្យទៅអ្នកទិញ និងត្រូវមានចុះនិទ្ទេស ដូចជា ឈ្មោះ និងលេខចុះបញ្ជីរបស់អ្នកលក់ កាលបរិច្ឆេទចេញវិក្កយបត្រ ឈ្មោះអ្នកទិញ ឬនិយោជិក ឬភ្នាក់ងារអ្នកទិញ បរិមាណ សេចក្តីបរិយាយ និងថ្លៃលក់ទំនិញ ឬសេវា។ ជាងនេះទៅទៀត វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធតាមរបបស្វ័យប្រកាសត្រូវមានអាសយដ្ឋាន លេខអត្តសញ្ញាណកម្ម "អតប" លេខវិក្កយបត្រ ថ្ងៃខែឆ្នាំចេញវិក្កយបត្រ រាយមុខទំនិញ ឬសេវា បរិមាណ ថ្លៃឯកតា ថ្លៃសរុប គោត្តនាម និងនាមអ្នកចេញវិក្កយបត្រ...។ ប៉ុន្តែ អាជីវកម្មរបបស្វ័យប្រកាសមួយចំនួនបានប្រើប្រាស់ និងចេញវិក្កយបត្រពុំទាន់ត្រឹមត្រូវតាមការណែនាំទៅឱ្យអតិថិជនរបស់ខ្លួន ដូចជាវិក្កយបត្រគ្មានលេខអត្តសញ្ញាណកម្ម "អតប" គ្មានលេខវិក្កយបត្រ គ្មានគោត្តនាម និងនាមអ្នកចេញវិក្កយបត្រ..។ ការប្រើប្រាស់ ឬចេញវិក្កយបត្រដោយមិនបានបំពេញព័ត៌មានច្បាស់លាស់អាចពុំបញ្ជាក់បានពីភាពត្រឹមត្រូវ និងអាចជះឥទ្ធិពលដល់ការប្រមូលពន្ធ និងការធ្វើសវនកម្ម។ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំផែនការសកម្មភាពសម្រាប់កែលម្អករណីនេះ បានណែនាំផ្សព្វផ្សាយអំពីការប្រើប្រាស់វិក្កយបត្រឱ្យបានសមស្របតាមបទប្បញ្ញត្តិ ដោយបានចេញសេចក្តីណែនាំថ្មីលេខ ១១២៧ អពដ ចុះថ្ងៃទី២៦ ខែមករា ឆ្នាំ២០១៦ ស្តីពីការប្រើប្រាស់វិក្កយបត្រសម្រាប់អ្នកជាប់ពន្ធដែលបានចុះបញ្ជីពន្ធដារតាមរបបស្វ័យប្រកាស បានបោះពុម្ពការប្រើប្រាស់វិក្កយបត្រចែកជូនម្ចាស់សហគ្រាសទាំងអស់ បានចេញសេចក្តីណែនាំលេខ២១៦០៦ អពដ ចុះថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការប្រើប្រាស់លេខរៀងវិក្កយបត្រ និងកំពុងពង្រឹងយន្តការនៃការប្រើប្រាស់វិក្កយបត្រនេះដល់មន្ត្រីទាំងអស់ និងបានធ្វើសវនកម្មដោយមានទាំងការពិន័យទោសទណ្ឌចំពោះក្រុមហ៊ុនសហគ្រាសមួយចំនួនដែលប្រើប្រាស់វិក្កយបត្រមិនបានត្រឹមត្រូវ។

៤.៥. ការត្រួតពិនិត្យលើលិខិតប្រកាសពន្ធ: ការដាក់លិខិតប្រកាសពន្ធអាករប្រចាំខែ ប្រចាំឆ្នាំនៅរដ្ឋបាលសារពើពន្ធត្រូវធ្វើឡើងដោយភាពត្រឹមត្រូវ និងច្បាស់លាស់ ហើយបណ្ណាធិការសហគ្រាសជាអ្នកទទួលខុសត្រូវទាំងស្រុងចំពោះមុខច្បាប់ ប្រសិនបើព័ត៌មានណាមួយមានការក្លែងបន្លំ រីឯការត្រួតពិនិត្យលិខិតប្រកាសពន្ធ ជាភារកិច្ចរបស់មន្ត្រីពន្ធ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មសង្កេតឃើញថា ក្រុមហ៊ុនសហគ្រាសមួយចំនួនបានប្រកាសពន្ធមិនត្រឹមត្រូវ និងសមស្រប ដូច

ជា មិនបានភ្ជាប់ទិន្នានុប្បវត្តិលក់ទិញ មិនបានបំពេញលើលិខិតប្រកាសគ្រប់ខ្ជង់ គ្រប់និទ្ទេស ផល ដែលបានប្រកាសនៅទាប មិនប្រកាសពន្ធកាត់ទុកថ្លៃឈ្នួល មិនប្រកាសពន្ធកាត់ទុកទូទៅលើសេវា មិនបង្ហាញមូលដ្ឋានគណនាអាករបំភ្លឺសាធារណៈ ពេលខ្លះប្រកាសមូលដ្ឋានគិតអាករបំភ្លឺសាធារណៈ លើស ប្រកាសមូលដ្ឋានគិតអាករពិសេសលើស ប្រកាសពន្ធលើប្រាក់បៀវត្សមិនត្រឹមត្រូវ ការប្រើ ប្រាស់ឥណទានអាករមិនត្រឹមត្រូវ ការប្រកាសឥណទានអាករលើធាតុចូលលើស និងការគណនា មូលដ្ឋានគិតអាករស្មាក់នៅមិនទាន់ត្រឹមត្រូវ។ ករណីនេះ អគ្គនាយកដ្ឋានពន្ធដារបានដាក់ចេញ ផែនការសកម្មភាពសម្រាប់កែលម្អ ដើម្បីពង្រឹងការត្រួតពិនិត្យលើលិខិតប្រកាសពន្ធដោយមានមន្ត្រី ទទួលបន្ទុកពិនិត្យ និងណែនាំចំពោះក្រុមហ៊ុនសហគ្រាសដែលដាក់លិខិតប្រកាសមិនត្រឹមត្រូវ មិន គ្រប់ខ្ជង់ និងមិនគ្រប់និទ្ទេស ថែមទាំងជំរុញការធ្វើសវនកម្មលើលិខិតស្នាមដោយកំណត់ពន្ធឡើង វិញ ចំពោះក្រុមហ៊ុនសហគ្រាសដែលប្រកាសមិនប្រក្រតី និងកំពុងជំរុញការបណ្តុះបណ្តាលបន្ថែម ដល់មន្ត្រីចាត់ចែងលិខិតប្រកាស។

៤.៦. ការបំពេញកាតព្វកិច្ចចុះបញ្ជីសារពើពន្ធសហគ្រាស: ច្បាប់ស្តីពីសារពើពន្ធសហគ្រាស កំណត់ថា ក្រោយពីចុះបញ្ជីនៅក្រសួងពាណិជ្ជកម្មរួចហើយ សហគ្រាសត្រូវរួសរាន់ទៅចុះបញ្ជីនៅ រដ្ឋបាលសារពើពន្ធក្នុងអំឡុង១៥ថ្ងៃ។ ក្នុងករណីមិនបានទៅចុះបញ្ជីទេនោះ រដ្ឋបាលសារពើពន្ធ អាចធ្វើការចុះបញ្ជីចាប់តាំងពីពេលដែលសហគ្រាសត្រូវទៅចុះបញ្ជី ហើយការចុះបញ្ជីបែបនេះ សហគ្រាសត្រូវមានការទទួលខុសត្រូវចំពោះប្រាក់អាករទាំងអស់ចាប់តាំងពីកាលបរិច្ឆេទដែលបាន កំណត់។ ប៉ុន្តែ តាមការធ្វើសវនកម្មលើរបាយការណ៍ស្តីពីសកម្មភាពការងាររបស់នាយកដ្ឋានសេវា អ្នកជាប់ពន្ធ និងបំណុលពន្ធប្រចាំឆ្នាំ២០១៥ ចំពោះក្រុមហ៊ុនសហគ្រាសដែលបានចុះបញ្ជីនៅ ក្រសួងពាណិជ្ជកម្ម។ អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រុមហ៊ុនសហគ្រាសមួយចំនួនធំបាន មកបំពេញកាតព្វកិច្ចចុះបញ្ជីនៅរដ្ឋបាលសារពើពន្ធ ដោយឡែកនៅសល់ក្រុមហ៊ុនសហគ្រាសមួយ ចំនួនតូចមិនមកបំពេញកាតព្វកិច្ចពន្ធឱ្យបានសមស្របតាមបទប្បញ្ញត្តិខាងលើទេ។ សហគ្រាសនៅ សល់ដែលមិនបានចុះបញ្ជីពន្ធ អគ្គនាយកដ្ឋានពន្ធដារបានរៀបចំផែនការសកម្មភាព ដើម្បីកែលម្អ និងការអនុវត្តផែនការសកម្មភាពកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋានពន្ធដារលើ ការចុះបញ្ជីពន្ធដារ និងការធ្វើបច្ចុប្បន្នភាពសហគ្រាសដោយបានចេញនូវលិខិតជូនដំណឹង សេចក្តី ណែនាំអំពីកាតព្វកិច្ចចុះបញ្ជីពន្ធដារ និងមានក្រុមការងារធ្វើការផ្សព្វផ្សាយការចុះបញ្ជីនៅក្រសួងពាណិជ្ជ កម្ម និងនៅពន្ធដារ និងបានចុះស្វែងរកដោយផ្ទាល់ ព្រមទាំងចែកលិខិតជូនដំណឹងដើម្បីមកចុះ បញ្ជីពន្ធដារ និងឋតរូបដើម្បីបញ្ចូលក្នុងប្រព័ន្ធគ្រប់គ្រងរបស់អគ្គនាយកដ្ឋានពន្ធដារ និងការអង្កេត ស្រាវជ្រាវសហគ្រាសតាមដងផ្លូវ (Street Survey) ដើម្បីឲ្យសហគ្រាសដែលមិនបានចុះបញ្ជីត្រឹម ត្រូវ ឬលាក់ខ្លួនមិនព្រមមកចុះបញ្ជីពន្ធដារ បានមកចុះបញ្ជីពន្ធដារបានគ្រប់ៗគ្នា និងតម្រូវឲ្យសហ គ្រាសទាំងអស់មកធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាសឲ្យបានគ្រប់ៗគ្នា។

៤.៧. ការប្រមូលពន្ធអចលនទ្រព្យ: គោលការណ៍នៃការប្រមូលពន្ធលើអចលនទ្រព្យបាន តម្រូវឲ្យម្ចាស់អចលនទ្រព្យបំពេញព័ត៌មានអចលនទ្រព្យ ចុះបញ្ជី ដាក់លិខិតប្រកាស និងបង់ពន្ធ។

ការអនុវត្តប្រមូលពន្ធអចលនទ្រព្យនៅមានកម្រិតនៅឡើយ ដោយសារអ្នកជាប់ពន្ធមួយចំនួនមិនបានផ្តល់ព័ត៌មានអំពីអចលនទ្រព្យ មិនមកចុះបញ្ជីពន្ធអចលនទ្រព្យ មិនមកប្រកាសបង់ពន្ធលើអចលនទ្រព្យ និងអ្នកជាប់ពន្ធមួយចំនួនទៀតបានចុះបញ្ជីពន្ធអចលនទ្រព្យរួចហើយ ប៉ុន្តែមិនព្រមមកបង់ពន្ធ។ អគ្គនាយកដ្ឋានពន្ធដារបន្តពង្រឹងការយកចិត្តទុកដាក់ប្រមូលពន្ធអចលនទ្រព្យ តាមរយៈយន្តការឃាត់ទុក មិនអនុញ្ញាតឲ្យបង់ពន្ធប្រថាប់ត្រាផ្ទេរកម្មសិទ្ធិ ឬសិទ្ធិកាន់កាប់អចលនទ្រព្យ និងមិនអនុញ្ញាតឲ្យចុះបញ្ជីពន្ធដារ ក្នុងករណីកម្មសិទ្ធិករមិនទាន់បានបង់ពន្ធអចលនទ្រព្យ។

៤.៨. ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ: ប្រកាសរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ បានបញ្ជាក់ថា ការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍអចលនវត្ថុមានគោលបំណង ដើម្បីជំរុញឲ្យមានការអភិវឌ្ឍអចលនវត្ថុមួយដែលមានភាពទុកចិត្ត និងទទួលយកបានតាមរយៈការត្រួតពិនិត្យគម្រោងអាជីវកម្មអភិវឌ្ឍអចលនវត្ថុ គ្រប់គ្រងគម្រោងហិរញ្ញវត្ថុ គណនីអភិវឌ្ឍអចលនវត្ថុ និងការធ្វើសវនកម្មលើការអនុវត្តកិច្ចសន្យាទិញ លក់ និងបង្កើនទំនុកចិត្តរបស់អតិថិជនក្នុងការវិនិយោគលើអចលនវត្ថុ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានផ្តល់អាជ្ញាប័ណ្ណអាជីវកម្មអភិវឌ្ឍអចលនវត្ថុឲ្យក្រុមហ៊ុនចំនួន៣៦ ស្មើនឹង៣៨គម្រោង។ ទន្ទឹមនឹងនេះដែរ ក៏នៅមានក្រុមហ៊ុនមួយចំនួនផ្សេងទៀតដែលកំពុងដាក់ពាក្យស្នើសុំអាជ្ញាប័ណ្ណអភិវឌ្ឍអចលនវត្ថុ ប៉ុន្តែក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុពុំទាន់បានចេញអាជ្ញាបណ្ណជូនបានដោយសារខ្វះឯកសារលិខិតអនុញ្ញាតសាង់សង់ និងលិខិតបើកការដ្ឋានសាងសង់ដែលចេញដោយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុសូមឯកភាព និងសូមបញ្ជាក់ថា ការមិនបានផ្តល់អាជ្ញាប័ណ្ណជូនក្រុមហ៊ុនកន្លងមក ដោយសារក្រុមហ៊ុនទាំងនោះគ្មានលិខិតអនុញ្ញាតសាងសង់ពីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ ក៏ប៉ុន្តែក្រសួងបានចេញលិខិតអនុញ្ញាតគោលការណ៍ប្រកាសលក់ជូនក្រុមហ៊ុនដើម្បីគ្រប់គ្រងហានិភ័យផងដែរ។ បច្ចុប្បន្ន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរៀបចំធ្វើប្រកាសថ្មីស្តីពីការគ្រប់គ្រងអាជីវកម្មអភិវឌ្ឍលំនៅឋាន។

៤.៩. ក្រុមហ៊ុនចូលរួមដេញថ្លៃសាងសង់ភ្ជាប់ប្រភេទវិញ្ញាបនបត្រចុះបញ្ជីសាងសង់មិនសមស្រប: ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានចេញគោលការណ៍ណែនាំស្តីពីការបែងចែកតាមប្រភេទ និងការចុះបញ្ជីរបស់អ្នកទទួលការជាប្រភេទផ្សេងៗ ទៅតាមសមត្ថភាពបច្ចេកទេស និងហិរញ្ញវត្ថុ ព្រមទាំងតាមកំណត់ត្រាប្រវត្តិការងារផងដែរ ការបែងចែកនេះផ្អែកលើសមត្ថភាពនៃការដេញថ្លៃទៅតាមតម្លៃនៃកិច្ចសន្យា ដូចជា ទី១ ប្រភេទអ្នកទទួលការតូច ទី២ ប្រភេទអ្នកទទួលការមធ្យម និងទី៣ ប្រភេទអ្នកទទួលការធំ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា ក្រុមហ៊ុនចូលរួមដេញថ្លៃគម្រោងសាងសង់មួយចំនួន បានភ្ជាប់នូវវិញ្ញាបនបត្រចុះបញ្ជីអ្នកទទួលការសាងសង់ប្រភេទតូច និងប្រភេទមធ្យមប៉ុណ្ណោះ ។

៤.១០. ការផ្ញើរបាយការណ៍លទ្ធកម្មមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ: អនុក្រឹត្យរបស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីលទ្ធកម្មសាធារណៈ បានបញ្ជាក់ថា ស្ថាប័នអនុវត្តលទ្ធកម្មត្រូវផ្ញើរបាយការណ៍

លទ្ធកម្មប្រចាំខែមកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ សារាចរណែនាំស្តីពីការរៀបចំផែនការលទ្ធកម្ម ឆ្នាំ២០០៨ និងឆ្នាំបន្តបន្ទាប់ត្រង់ii. កាតព្វកិច្ចរបស់ស្ថាប័នអនុវត្តលទ្ធកម្ម ចែងថា ស្ថាប័នអនុវត្តលទ្ធកម្ម ត្រូវធ្វើរបាយការណ៍ប្រចាំខែ ស្តីពីការអនុវត្តគ្រប់កិច្ចលទ្ធកម្មដោយភ្ជាប់មកជាមួយនូវទិន្នន័យនៃកិច្ចសន្យា និងឯកសារពាក់ព័ន្ធ មកក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុតាមរយៈនាយកដ្ឋានលទ្ធកម្មសាធារណៈឱ្យបានទៀងទាត់រៀងរាល់ខែ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិពិនិត្យឃើញថា នៅក្នុងឆ្នាំ២០១៥ មានក្រសួងស្ថាប័ន រាជធានីខេត្ត និងសហគ្រាសសាធារណៈមួយចំនួននៅមិនទាន់បានផ្ញើ និងផ្ញើយឺតយ៉ាវនូវរបាយការណ៍អំពីការអនុវត្តកិច្ចលទ្ធកម្មប្រចាំខែ ប្រចាំឆ្នាំ មកអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ។

៤.១១. ការកត់ត្រាចំណូលថវិការដ្ឋ: បទបញ្ជាទូទៅនៃគណនេយ្យសាធារណៈកំណត់ថា ការកត់ត្រាចំណូលថវិកាត្រូវផ្អែកលើមូលដ្ឋានសលាកប័ត្រ ឬដីកាចំណូលរបស់អាណាប័កក្រសួងស្ថាប័នរាជធានីខេត្តដែលបានរៀបចំបញ្ជូនទៅឲ្យអគ្គនាយកដ្ឋានរតនាគារជាតិ ដើម្បីធ្វើការផ្ទៀងផ្ទាត់។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ចំណូលមួយចំនួនមិនត្រូវបានកត់ត្រាដោយផ្អែកលើមូលដ្ឋានសលាកប័ត្រ ឬដីកាចំណូលរបស់អាណាប័កនៅឡើយដោយសារក្រសួងស្ថាប័នមួយចំនួនតូចមិនព្រមធ្វើសលាកប័ត្រចំណូលមកឲ្យអគ្គនាយកដ្ឋានរតនាគារជាតិ។ ករណីទាំងនេះពាក់ព័ន្ធនឹងប្រភេទចំណូលមួយចំនួនដែលបានកើតមាននៅពេលកៀកចុងឆ្នាំ ហើយជាប្រភេទចំណូលដែលគ្រាន់តែធ្វើនិយ័តកម្មតួលេខ ដូចជា ចំណូលពីកម្រៃរតនាគារ ចំណូលពីវិសមភាពបេឡា និងខ្វង់ចំណូលមួយចំនួនទៀតនៅកៀកចុងឆ្នាំ និងចំណូលពីឈ្នួលទីតាំងដែលធនាគារជាតិនៃកម្ពុជាបានបញ្ជូនប្រកាសឥណទានមកឲ្យអគ្គនាយកដ្ឋានរតនាគារជាតិហើយ ប៉ុន្តែក្រសួងស្ថាប័នមួយចំនួនតូចមិនព្រមធ្វើសលាកប័ត្រចំណូលមកឲ្យអគ្គនាយកដ្ឋានរតនាគារជាតិ។

៤.១២. ការទូទាត់ និងការកត់ត្រាចំណាយ: ជាគោលការណ៍ ការបញ្ជូនអាណត្តិបើកប្រាក់ទៅអគ្គនាយកដ្ឋានរតនាគារជាតិត្រូវបានកំណត់ឱសានវាទត្រឹមថ្ងៃទី៣១ ខែធ្នូ នៃឆ្នាំសារពើពន្ធ។ តាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា ការបញ្ជូនអាណត្តិបើកប្រាក់មួយចំនួនតូចទៅអគ្គនាយកដ្ឋានរតនាគារជាតិនៅតែមានភាពយឺតយ៉ាវ ពុំទាន់ពេលវេលាដែលបង្កឱ្យមានការលំបាកក្នុងការបូកសរុបបិទបញ្ជីប្រចាំឆ្នាំ។ អាជ្ញាធរសនវកម្មជាតិសង្កេតឃើញថា ជាទូទៅអាណត្តិដែលបានបញ្ជូនចេញពីអគ្គនាយកដ្ឋានថវិកា ក៏ដូចជាពីថ្នាក់ដឹកនាំក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើទៅតាមកាលបរិច្ឆេទកំណត់ (ត្រឹមថ្ងៃទី៣១ ខែធ្នូ នៃការិយបរិច្ឆេទ) ប៉ុន្តែអាណត្តិទាំងនោះត្រូវបានបញ្ជូនទៅអគ្គនាយកដ្ឋានរតនាគារជាតិនៅក្រោយការិយបរិច្ឆេទកំណត់បិទបញ្ជី ដោយមានសក្តីប័ត្រគ្រប់គ្រាន់ និងប្រើប្រាស់ឥណទានដែលនៅសល់ក្នុងឆ្នាំ២០១៥។

៤.១៣. ការធ្វើបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ: រដ្ឋាភិបាលបានចេញសារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋដោយបានបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវទទួលខុសត្រូវចំពោះមុខរាជរដ្ឋាភិបាល ក្នុងការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជារៀងរាល់ឆ្នាំឱ្យបានត្រឹមត្រូវគ្រប់ចំនួន និងចប់សព្វគ្រប់នៅក្នុងត្រីមាសទី១នៃឆ្នាំបន្ទាប់។ ការរៀបចំបញ្ជី

សារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋត្រូវអនុវត្តតាមទម្រង់ដូចជាតារាងកើនឡើង និងថយចុះនូវទ្រព្យសម្បត្តិរដ្ឋដែលត្រូវធ្វើឡើងក្នុងឆ្នាំនីមួយៗ ក្នុងចន្លោះរយៈពេល០៥(ប្រាំ)ឆ្នាំនៃឆ្នាំគោល។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា អង្គភាពប្រើប្រាស់ទ្រព្យសម្បត្តិរដ្ឋមួយចំនួនពុំបានអនុវត្តឲ្យបានពេញលេញតាមការតម្រូវខាងលើនេះទេ ដោយអង្គភាពមួយចំនួននៅតែមានការយឺតយ៉ាវក្នុងការធ្វើបញ្ជីសារពើភណ្ឌឆ្នាំគោល ហើយខ្លះទៀតយឺតយ៉ាវក្នុងការរៀបចំតារាងប្រៀបធៀបការកើនឡើង និងថយចុះនៃទ្រព្យសម្បត្តិរដ្ឋ។

៤.១៤.ការធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិលើទ្រព្យសម្បត្តិរដ្ឋ: រាជរដ្ឋាភិបាលបានចេញសារាចរណែនាំស្តីពីការរៀបចំបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដោយបញ្ជាក់ថា អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋត្រូវរៀបចំធ្វើវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លើទ្រព្យសម្បត្តិរដ្ឋជាអចលនវត្ថុទាំងអស់ ស្ថិតនៅក្រោមការកាន់កាប់ និងប្រើប្រាស់របស់ខ្លួនឱ្យបានឆាប់រហ័ស និងតាមពេលវេលាកំណត់ដោយសហការជាមួយក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។ គ្រប់អាជ្ញាធរកាន់កាប់ទ្រព្យសម្បត្តិរដ្ឋទាំងអស់ត្រូវបញ្ចូលវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ ដែលរៀបចំរួចទៅក្នុងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ ដើម្បីធានាបាននូវភាពគង់វង្ស និងភាពស្របច្បាប់នៃទ្រព្យសម្បត្តិទាំងឡាយនោះ។ ប៉ុន្តែតាមការធ្វើសវនកម្ម អាជ្ញាធរសវនកម្មជាតិសង្កេតឃើញថា រហូតមកដល់ឆ្នាំ២០១៥ ទ្រព្យសម្បត្តិរដ្ឋមួយចំនួននៅតែពុំទាន់បានធ្វើប័ណ្ណសម្គាល់កម្មសិទ្ធិរួចរាល់នៅឡើយ។

៥. សេចក្តីសន្និដ្ឋាន

លទ្ធផលនៃការអនុវត្តច្បាប់ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៥ បានបង្ហាញឲ្យឃើញថា រាជរដ្ឋាភិបាលកម្ពុជាធ្វើឲ្យសម្រេចបាននូវកំណើនសេដ្ឋកិច្ច**៧%** ព្រមទាំងសម្រេចបាននូវការកាត់បន្ថយភាពក្រីក្រក្នុងអត្រាជាង**១%**ក្នុងមួយឆ្នាំ ដែលធ្វើឲ្យគោលដៅកាត់បន្ថយភាពក្រីក្ររបស់រាជរដ្ឋាភិបាលសម្រេចបានមុនគោលដៅអភិវឌ្ឍន៍សហស្សវត្សរ៍។

តាមរយៈការផ្តល់អនុសាសន៍កែលម្អនូវចំណុចខ្វះខាតនានា និងការចេញផ្សាយរបាយការណ៍សវនកម្មជាសាធារណៈជាបន្តបន្ទាប់មកនេះ អាជ្ញាធរសវនកម្មជាតិកត់សម្គាល់ឃើញថា អង្គភាពរងសវនកម្មនានាបានយកចិត្តទុកដាក់ខិតខំអនុវត្តកែលម្អនូវអនុសាសន៍សវនកម្មបានប្រសើរ។ អាជ្ញាធរសវនកម្មជាតិសង្ឃឹមថា អង្គភាពរងសវនកម្មទាំងឡាយនឹងបន្តខិតខំអនុវត្តកែលម្អនូវរាល់កង្វះខាតនានាឱ្យបានល្អប្រសើរ និងទាន់ពេលវេលា ហើយជៀសវាងបាននូវការបន្តកើតមានកង្វះខាតដដែលៗជាបន្តទៅទៀត ដើម្បីចូលរួមចំណែកយ៉ាងសកម្មក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈឲ្យបានកាន់តែរឹងមាំ និងប្រកបដោយប្រសិទ្ធភាពខ្ពស់។

ក្នុងបរិបទនេះដែរ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានធ្វើរបាយការណ៍គោរពជូន **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** លើលទ្ធផលការងារអធិការកិច្ចហិរញ្ញវត្ថុ ដែលបានរកឃើញនូវកំហុសឆ្គងរបស់ក្រសួងស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ និងបានធ្វើលិខិតចាត់វិធានការវិន័យរដ្ឋបាល ដើម្បីកែលម្អកំហុសឆ្គងលើការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ដែលក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានរកឃើញក្នុងការគ្រប់គ្រង ការប្រើប្រាស់

ចំណូលចំណាយថវិការដ្ឋ ចំណូលមិនមែនសារពើពន្ធ កាតព្វកិច្ចបង់ចំណូលចូលថវិការដ្ឋ និងការគ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋរបស់ក្រសួងស្ថាប័ន សហគ្រាសសាធារណៈ និងមន្ទីរជំនាញ ដើម្បីអនុវត្តឲ្យមានប្រសិទ្ធភាពតាមនីតិវិធីហិរញ្ញវត្ថុ ច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ និងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងប្រចាំឆ្នាំ ហើយបានចម្លងជូនក្រសួងស្ថាប័នពាក់ព័ន្ធ ដូចជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច អង្គភាពប្រឆាំងអំពើពុករលួយ និងអាជ្ញាធរសវនកម្មជាតិ ដើម្បីចាត់ការបន្ត។

ទន្ទឹមនឹងនេះដែរ អាជ្ញាធរសវនកម្មជាតិមានជំនឿយ៉ាងមុតមាំថា ក្រសួងស្ថាប័ន អង្គភាពពាក់ព័ន្ធនានា និងសាធារណជនទាំងឡាយនឹងបន្តចូលរួមផ្តល់មតិស្ថាបនាលើរបាយការណ៍នេះ ព្រមទាំងផ្តល់ការលើកទឹកចិត្តចំពោះលទ្ធផលសម្រេចបាន ដែលជាកត្តាជំរុញឲ្យអាជ្ញាធរសវនកម្មជាតិបន្តខិតខំបង្កើនសមត្ថភាពការងាររបស់ខ្លួនប្រកបដោយសីលធម៌វិជ្ជាជីវៈ សំដៅលើកកម្ពស់គុណភាពសវនកម្មឲ្យស្របតាមស្តង់ដារសវនកម្មសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងស្តង់ដារតំបន់ និងអន្តរជាតិ ដើម្បីចូលរួមចំណែកក្នុងការកសាង និងអភិវឌ្ឍប្រទេសជាតិប្រកបដោយចីរភាព។